ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Oct-2016, 10:29
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៤៣២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេសន៍ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ហង់រី ឡូកា (2-TCE-90) | អង់គ្លេស, បារាំង |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅអ្នកជំនាញ៖ លោក ហង់រី ឡូការ** (2-TCE-90)

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី.................................................... ទំព័រ ៣
សួរដោយលោក ពេជ អង្គ ផ្ដើមពី ........................................................................ ទំព័រ ៧៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សីអ្នកជំនាញ ហង់រី ឡូកា។

ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និង បុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយអ្នកជំនាញដែលត្រូវមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺលោក ហង់រី ឡូកា លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ។ សូមអរគុណលោកប្រធាន។

[០៩:០១:៤០]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយសារគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និង មានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំ

ការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចង្កេះ ឈឺខ្នង អង្គុយយូរធេងធោង និងបានផ្តល់អនុសាសន៍ថា សូមឱ្យអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និង យោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជាអាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៣:០៦]

ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីសួរដេញដោលចំពោះអ្នកជំនាញ អង្គជំនុំជម្រះចេញសេចក្តីសម្រេចផ្ទាល់មាត់តាមវិធាន៨៧(៣)និង(៤)។ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ មេធាវីការពារក្តី ខៀវ សំផន បានស្នើសុំឱ្យទទួលយកសៀវភៅ និងនិពន្ធដោយ -- ដែលនិពន្ធដោយលោក ហង់រី ឡូកា មានចំណងជើងថា *"ពួកក្រ ឡៃ ខ្មែរក្រហម"* បោះពុម្ពនៅឆ្នាំ២០១៣ ដោយសារតែមេធាវីការពារក្តីមានបំណងប្រើប្រាស់សៀវភៅនេះ ក៏ដូចជា សៀវភៅបោះពុម្ពនៅក្នុងឆ្នាំ២០១៦ ក្នុងការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ ហង់រី ឡូកា។

នៅថ្ងៃដដែលនេះ អង្គជំនុំជម្រះបានស្តាប់សារណាផ្ទាល់មាត់របស់ភាគីនានា ហើយភាគីផ្សេងទៀតមិនបានជំទាស់ទៅនឹងសំណើសុំនេះទេ។ អង្គជំនុំជម្រះកត់សម្គាល់ពីលក្ខខណ្ឌតម្រូវនៃវិធាន៨៧(៣) និង ៨៧(៤)នៃវិធានផ្ទៃក្នុង ហេតុដូច្នេះសម្រេចតាមសំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន។

បាទ តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរដេញដោលចំពោះអ្នកជំនាញ ហង់រី ឡូកា។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ជម្រាបសួរ

ភាគីទាំងអស់។

[០៩:០៥:៣៩]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** សួស្តីលោកអ្នកជំនាញ។ ថ្ងៃនេះ ខ្ញុំនឹងសួរសំណួរជាច្រើនទៅកាន់លោក សូមលោកឆ្លើយឲ្យបានខ្លីច្បាស់លាស់ ទៅនឹងសំណួររបស់ខ្ញុំ។ ជាពិសេសសូមកុំបើករង្វង់ក្រចកច្រើនពេក បើខ្ញុំចង់បានព័ត៌មានលម្អិតអ្វីបន្ថែមនោះ ខ្ញុំនឹងសួរសំណួរបន្ថែមហើយ លោកមិនបាច់ឆ្លើយវែងឆ្ងាយអីពេកទេ។ ខ្ញុំចង់សួរពាក់ព័ន្ធនឹងសៀវភៅរបស់លោក គឺកូនសៀវភៅក្រហមរបស់ ប៉ុល ពត ដែលមាន E3/2812 ហើយក្នុងសៀវភៅនេះមានការបកប្រែជាភាសាខ្មែរតែបន្តិចបន្តួចប៉ុណ្ណោះ គឺបកប្រែដោយផ្នែកនៅក្នុងសំណុំរឿង។ កាលពីម្សិលមិញលោកបាននិយាយថា ប្រទេសកម្ពុជាហ្នឹង ជាប្រទេសមួយដែលមានវប្បធម៌ផ្សព្វផ្សាយតគ្នាពីមាត់មួយទៅមាត់មួយ ជាពិសេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះខ្ញុំចង់សួរលោកថា តើនៅសម័យខ្មែរក្រហមមានកម្មាភិបាលខ្មែរក្រហមច្រើនទេ ដែលនៅមូលដ្ឋាននោះដែលមានកម្រិតអប់រំតិចតួចនោះ លោកដឹងទេ?

**លោក ហង់រី ឡូកា៖**

**ឆ៖** ជម្រាបសួរលោកសហព្រះរាជអាជ្ញា។ សូមអរគុណដែលបានសួរសំណួរនេះមកកាន់ខ្ញុំ។ ខ្ញុំគិតថា ខ្ញុំមិនអាចបំភ្លឺឲ្យច្បាស់ទៅលើសំណួរនេះទេ។ សាក្សីជាច្រើនដែល<ខ្ញុំបានសម្ភាស គឺ>ជាជនរងគ្រោះ<>។ ហើយក្នុងចំណោមមនុស្សជាច្រើនដែលខ្ញុំសម្ភាសនោះ គឺជាអ្នកដែលបានចូលបដិវត្តន៍ ដូចជាអ្នកថតរូបម្នាក់នៅខេត្តព្រៃវែងជាដើម ឬក៏មានអ្នកផ្សេងទៀត ដែលស្ថិតនៅក្នុងរបបលោក ហេង សំរិន ដែលមានមុខតំណែងទទួលខុសត្រូវ ហើយពួកគាត់សុទ្ធតែអ្នកមានកម្រិតអប់រំខ្ពស់ ហើយខ្ញុំមិនបានសម្ភាសអតីតខ្មែរក្រហមដែលមិនចេះអក្សរទេ។ អ្នកដែលខ្ញុំសម្ភាស ភាគច្រើនហ្នឹង ពួកគាត់មិនចង់និយាយអ្វីទេ។ អ៊ីចឹងហើយខ្ញុំមិនមានព័ត៌មានអីសម្រាប់បំភ្លឺលោកពាក់ព័ន្ធនឹងសំណួរនេះទេ។

[០៩:០៧:១៧]

**ស៖** នៅក្នុងបរិបទនៃវប្បធម៌ដែលផ្សព្វផ្សាយពីមាត់មួយទៅមាត់មួយនោះ តើពាក្យស្លោកសុភាសិតមានសារៈសំខាន់អ្វីខ្លះ នៅក្នុងការផ្សព្វផ្សាយមនោគមន៍វិជ្ជាបក្សកុម្មុយនីស្តកម្ពុជានៅទូទាំងប្រទេសនោះ?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ដូចជានៅក្នុងប្រទេសកុម្មុយនីស្តទាំងអស់ដែរ គេបានប្រើពាក្យស្លោករាប់ពាន់រាប់ម៉ឺន ដូចជានៅចិន មានរាប់ពាន់រាប់ម៉ឺនដែរ ហើយមិនដែលមានអ្នកណាប្រមូលផ្តុំចងក្រងអ្វីទេ។ ហើយ<ខ្ញុំជឿថាមានតែខ្ញុំទេ>ដែល<បាន>ប្រមូលផ្តុំពាក្យស្លោក<ពីរបប>កុម្មុយនីស្ត<>។ ដូច្នេះគំនិតទាំងអស់នោះ គឺជាគំនិតសាមញ្ញ ពីព្រោះនៅក្នុងសង្គមមានការបែងចែករវាងអ្នកស្លូតត្រង់ និងអ្នកកាច មានអ្នកនាយទុន មានវណ្ណៈអធន ខ្មាំង និងមិត្ត។ ដូច្នេះមនោគមន៍វិជ្ជាទាំងអស់នោះ គឺសុទ្ធតែមានលក្ខណៈសាមញ្ញបំផុត មិនមានលក្ខណៈជាអ្វីឲ្យខ្លាំងក្លាទេ។ ពាក្យស្លោកទាំងនេះ គឺជាការបញ្ចូលនូវគោលគំនិតបដិវត្តន៍ទៅឲ្យយុវជន ដោយយកតាមគំរូរបស់ ម៉ៅ។ ម៉ៅ ចាត់ទុកយុវជនជាក្រដាសស ដែលគេអាចសរសេរអ្វីក៏បានពាក់ព័ន្ធទៅនឹងបដិវត្តន៍ និងគំនិតបដិវត្តន៍។ ខ្មែរក្រហម ដោយមានការប្រញាប់ប្រញាល់ពេក ធ្វើឲ្យពួកគាត់ហ្នឹងមិនអាចគិតទៅដល់អ្នកដែលចេះដឹង ជាពិសេសចាស់ទុំ<ទេ ពួកគេគិតតែពីយុវជនបដិវត្តន៍។ មានសង្គមមួយសម្រាប់អ្នកបដិវត្តន៍ក្មេងៗ>។ ដូច្នេះមានទម្រង់នៃការអប់រំយុវជននៅក្នុងឃុំជាច្រើន នៅក្នុងសហករណ៍ជាច្រើន។ <មានវណ្ណៈជាច្រើន។ ពួកគេត្រូវបានបង្រៀនឲ្យ> ចេះសរសេរ ចេះអាន ចេះ<រាប់លេខ។> គេបង្រៀនពាក្យស្លោក គេបង្រៀនចម្រៀងបដិវត្តន៍។ យើងអាចនិយាយបានថា ចម្រៀង និងពាក្យស្លោកបដិវត្តន៍ទាំងអស់នេះ គឺជាវិធីជាមូលដ្ឋានមួយក្នុងការអប់រំទៅដល់យុវជន។ នៅក្នុងពេលប្រជុំ ក្នុងពេលបុណ្យបដិវត្តន៍ គេតែងតែប្រកាសអំពីពាក្យស្លោកទាំងអស់នេះ។

[០៩:១០:១៤]

**សៈ** <តើ>ពាក្យស្លោកទាំងអស់ហ្នឹងសុទ្ធតែខ្លីៗ<សង្ខេបៗ> ហើយមាន<រូបភាពច្រើនទេ>? តើវាអាចឲ្យ<យល់>បានដោយងាយស្រួលទេ?

**ឆ៖** ត្រង់សំណួរនេះ ក៏ខ្ញុំពិបាកក្នុងការឆ្លើយដែរ។ នៅក្នុងសង្គមរបស់យើង ៗធ្លាប់តែមានជំនាញខាងការផ្សព្វផ្សាយ ខាងការប្រើប្រាស់ពាក្យស្លោក ឧទាហរណ៍ ដូចជាអ្នកនយោបាយនៅក្នុងពេលឃោសនាបោះឆ្នោតជាដើម គេប្រើវិធីនេះ។ ឥឡូវនេះលោកសួរថា តើពាក្យស្លោកនេះ វាមានប្រសិទ្ធភាព ឬក៏មិនមានប្រសិទ្ធភាពនោះ ខ្ញុំមិនអាចឆ្លើយបានទេ ខ្ញុំមិនមែនជាអ្នកជំនាញខាងហ្នឹងទេ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលផ្ទុយពីរបបយើងឥឡូវនេះ ប្រជាជនមិនមានសិទ្ធិទទួលបាននូវសារព័ត៌មានទេ មិនមានសៀវភៅ មិនមានវិទ្យុ មានទូរទស្សន៍អីទេ មានតែវិទ្យុកម្ពុជាប្រជាធិបតេយ្យមួយតែប៉ុណ្ណោះ ហើយមានតែកម្មាភិបាលខ្មែរក្រហមទេ ដែលអាចទទួល

បានព័ត៌មានទាំងអស់នេះ។ ដូច្នេះដោយសារតែមិនទទួលបានព័ត៌មានអ្វីនោះ ពាក្យស្លោកទាំងអស់នេះ គឺមានឥទ្ធិពលខ្លាំងទៅលើយុវជន។

**ស៖** ខ្ញុំសូមចាប់ផ្ដើមដោយពាក្យស្លោកមួយដែលគេស្គាល់ច្បាស់ទាំងអស់គ្នា គឺនៅក្នុងសៀវភៅរបស់លោក<ជាភាសាបារាំង>ដែលមានលេខរៀង២២០ ហើយជាភាសាអង់គ្លេសគឺលេខរៀង ពាក្យស្លោកហ្នឹងគឺ២៥៨។ ដូច្នេះលោកប្រធាន ខ្ញុំសូមថាមិនចាំបាច់ឲ្យ ERN រហូតទេ ខ្ញុំអាចឲ្យត្រឹមតែលេខរៀងនៃពាក្យស្លោកទាំងអស់ហ្នឹងបានហើយ។ ក៏ប៉ុន្តែខ្ញុំមាន ERN ដែរ បើសិនជាអង្គជំនុំជម្រះត្រូវការនោះ។ ពាក្យស្លោកនុ៎ងនិយាយថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"។ ដូចដែលពាក្យស្លោកដែលខ្ញុំនឹងរៀបរាប់បន្តទៅទៀតនេះដែរ លោកអាចពន្យល់បានទេថា ពាក្យស្លោក "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត" នេះមានន័យថាយ៉ាងម៉េច តាមការស្រាវជ្រាវរបស់លោក និងតាមការដែលលោកសម្ភាសមនុស្សជាច្រើននោះ?

[០៩:១២:៥០]

**ឆ៖** ពាក្យស្លោកនេះស្ថិតនៅក្នុងពាក្យស្លោកមួយចំនួនដែលខ្ញុំបាន<ផាត់ពណ៌ចំណាំ។ មានពាក្យស្លោកប្រហែល៣០ ទៅ៤០> ដែលគេស្គាល់ច្បាស់នៅក្នុងប្រទេស ហើយមានការនិយាយតៗគ្នាជាច្រើន។ <ខ្ញុំគិតថា នៅក្នុងសក្ខីកម្មបីរបស់ ឌុច>--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*(គ្មានការបកប្រែ)*

**លោក ហង់រី ឡូកា៖**

*(គ្មានការបកប្រែ)*

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគិតថា មានបញ្ហាក្នុងកន្លែងបកប្រែ ខ្ញុំមិនដឹងទេ ព្រោះឃើញមានដូរភាសាទៅមកៗ។ ថាតើមានបញ្ហាអ្វីទេនៅទូបកប្រែ? ម្ដងខ្ញុំឮភាសាអង់គ្លេស ម្ដងខ្ញុំឮភាសាបារាំងនៅទូ នៅៗកាណាល់ភាសាអង់គ្លេសរបស់ខ្ញុំ។ អត់អីទេ ឥឡូវអត់មានបញ្ហាអីទេ។ អរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

លោកស្រីចៅក្រម តើខ្ញុំត្រូវសួរសំណួរឡើងវិញ ឬក៏ម៉េច ឬក៏<ត្រឹមតែ>ចម្លើយ<ដែលមិនបានស្ដាប់ឮនោះ>ទេ?

[០៩:១៣:៤៤]

**ចៅក្រម ក្ដូឌា ហ្វេនស៍៖**

សំណួរមិនអីទេ ប៉ុន្តែសំខាន់គឺចម្លើយ អត់មានបកប្រែ។

**លោក ហង់រី ឡូកា៖**

**ឆ៖** បាទ ពាក្យស្លោកនេះគឺស្ថិតនៅក្នុងចំណោមពាក្យស្លោក៣០, ៤០, ៥០ ដែលខ្ញុំបាន<គូសបន្ទាត់ចំណាំ> ហើយដែលត្រូវបានគេនិយាយនៅទូទាំងប្រទេស ហើយ ឌុច ក៏និយាយពាក្យស្លោកហ្នឹងច្រើនដងដែរ<នៅក្នុងការផ្ដល់សក្ខីកម្មរបស់គាត់>។ ពាក្យស្លោកហ្នឹង គឺគេច្រើនតែប្រើនៅក្នុងគុកជាច្រើននៅពេលដែលគេសួរចម្លើយអ្នកទោស គឺវាដូចជាការចេញសេចក្ដីសម្រេចសម្លាប់អីចឹង ជាការគំរាមកំហែងទៅលើអ្នកណាដែលគេឃើញថាមានការប្រឆាំងទៅនឹងរបបខ្មែរក្រហមនោះ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** មានពាក្យថា “ដកចេញ” ហើយលោកក៏បានធ្វើបទអត្ថាធិប្បាយនៅក្នុងសៀវភៅរបស់លោក គឺឯកសារ E3/2812 ជាភាសាបារាំងគឺទំព័រ១៧៥, ១៧៦ នៅ ERN 00395157 ទៅដល់ 58, ជាភាសាអង់គ្លេសគឺ 00394841។ លោកបានធ្វើដូចតទៅ៖ “ន័យធៀបនៃកិរិយាសព្ទទី២នេះ មានន័យថា ជាការដកស្មៅ ដកចេញ<ពីវាលស្រែ> មុននឹងគេដាក់គ្រាប់ថ្មី <ហេតុដូច្នោះហើយ សង្គមថ្មីមួយត្រូវតែជាកន្លែងស្អាតស្អំ>។ ហើយអ្នកដែលនៅរស់រានមានជីវិតនៅក្នុងរបបនេះ គឺស្ដាប់ឮពាក្យស្លោកហ្នឹងទាំងអស់គ្នា។ <ដូច្នេះមានពាក្យជាច្រើនដែលយើងអាចស្ដាប់ឮ ដើម្បីគាំទ្រដល់ការចោទប្រកាន់អំពីឆន្ទៈនៃការលុបបំបាត់ និងកម្ទេច ដែលត្រូវបានរៀបចំឡើងយ៉ាងឥតធម៌មេត្តា ដោយមជ្ឈិម ហើយត្រូវបានអនុវត្តនៅក្នុងសង្គមទាំងមូល>។” ខ្ញុំអាននេះ <គឺជាអ្វីដែលលោកបានសរសេរ>ឡើងនៅ<ក្នុងទសវត្សរ៍>ឆ្នាំ ៩០។ ដូចនេះ ខ្ញុំចង់ដឹងថាតើលោកនៅតែរក្សាទុកបទអត្ថាធិប្បាយរបស់លោកនេះដដែល ឬក៏យ៉ាងម៉េច ឬក៏នៅពេលដែលលោកធ្វើការស្រាវជ្រាវហើយ លោកមានបំណងចង់កែប្រែនូវអ្វីដែលលោកបានលើកឡើងកាលពីឆ្នាំ៩០នោះ?

[០៩:១៦:១៩]

**ឆ៖** អត់ទេ ខ្ញុំនៅតែនិយាយដដែល ដូចពីមុនដដែល។ ដោយសារតែខ្ញុំដឹងរឿងរ៉ាវច្រើន ជាពិសេសដូចជានៅប្រទេសចិន ដែលនៅទីនោះអ្នកប្រឆាំងមិនត្រូវបានសម្លាប់ជាប្រព័ន្ធទេ គឺគេទុកនៅក្នុងមន្ទីរអប់រំកែប្រែ ដូចជា ចាង ជុងគាវ។ <>ប្រធាននៃជើងកាងទាំងបួន ដែលគេហៅថាជា “ពស់វែក”

ដែលត្រូវបានចាប់ខ្លួនក្រោយពី ម៉ៅ សេទុង ស្លាប់បន្តិចហើយ គេយកទៅដាក់គុក ហើយគាត់នៅក្នុងគុក ១០ទៅ១៥ឆ្នាំ គាត់នៅរស់ គាត់ត្រឡប់ទៅរស់នៅជាប្រជាជនធម្មតាវិញ ហើយគាត់ក៏បានបង្កើតជាអង្គការការពារសិទ្ធិមនុស្សផងដែរ នៅពេលដែលគាត់ចាស់ហ្នឹង។ អ៊ីចឹងខុសពីខ្មែរ នៅស្រុកខ្មែរគឺខុសគ្នាដាច់តែម្តង។

**ស៖** តើពាក្យស្លោកនេះឆ្លុះបញ្ចាំងពីទស្សនទានរបស់របបនោះ ពាក់ព័ន្ធទៅនឹងមនុស្សជាពិសេសគឺពាក់ព័ន្ធទៅនឹងខ្មាំងដែរឬទេ?

**ឆ៖** បាទ ពិតណាស់ មាន<អក្សរសិល្ប៍>និយាយអំពីខ្មាំង។ <>នៅក្នុងសៀវភៅខ្ញុំ<ដែលបោះពុម្ពលើកទី១ និងលើកទី២> *"ឮរត់ ឡេ ខ្មែររូស៍"* ហ្នឹង <មានវាក្យខណ្ឌដ៏ទូលំទូលាយមួយ ដែលខ្ញុំដកស្រង់នូវទំនាក់ទំនង> ស្ទីវ ហេដឌ័រ <បានបង្កើតឡើង គឺពីរបៀបដែល>គេហៅខ្មាំងយ៉ាងម៉េច "ពួក<ព្រួន>"។ <រូបភាពជាច្រើនផ្សេងទៀតត្រូវបានប្រើប្រាស់។> ពួកគាត់ហ្នឹងគេចាត់ទុកដូចជាសំរាម ហើយគឺមិនមែនជាមនុស្សទៀតទេ អ្នកដែលគេចាត់ទុកជាខ្មាំងនោះ គឺអស់តម្លៃជាមនុស្សហើយ។

[០៩:១៨:០៥]

**ស៖** បាទ ខ្ញុំសូមចូលទៅពាក្យស្លោកមួយទៀត ដែលមានលេខរៀងទី២១៧ ជាភាសាបារាំង និង២៥៥ជាភាសាអង់គ្លេស។ ពាក្យស្លោកនេះនិយាយថា៖ "ស្ងួវចាប់ច្រឡំ កុំឱ្យលែងច្រឡំ"។ ឥឡូវនេះយើងនៅក្នុងសវនាការ តុលាការ ហើយពាក្យស្លោកនេះ ចំពោះអ្នកច្បាប់គឺវាមានន័យពិសេសជាក់លាក់ណាស់។ តើលោកអាចពន្យល់ខ្លឹមសារនៃពាក្យស្លោកនេះ ក្នុងបរិបទនៃរបបខ្មែរក្រហមបានទេ? ខ្ញុំសូមនិយាយម្តងទៀត ពាក្យស្លោកហ្នឹងថា "ស្ងួវចាប់ច្រឡំ កុំឱ្យលែងច្រឡំ"។

**ឆ៖** ដូចដែលលោកបានបញ្ជាក់រួចមកហើយ ពាក្យស្លោកនេះ គឺវាផ្ទុយទៅនឹងគោលការណ៍ច្បាប់ដែលមាននៅក្នុងសង្គមប្រជាធិបតេយ្យ ពីព្រោះថាជាធម្មតានោះ គឺវាផ្ទុយពីពាក្យស្លោកនេះ។ ខ្ញុំមិនដឹងថាតើក្នុងភាសាបារាំង ឬភាសាអង់គ្លេសទេ <>ប៉ុន្តែខ្ញុំដូចជាបានអាន<>គំនិតនេះ គឺមាននៅក្នុងខួរក្បាលរបស់ពួកខ្មែរក្រហម។ <មិនមែនតែពួកខ្មែរក្រហមទេនិយាយពាក្យនេះ ប៉ុន្តែវាបានបង្កើតឡើងដោយ>ពួកវៀតមិញ។ ខ្ញុំមិនដឹងថាតើខ្ញុំសរសេរ<នៅកន្លែងណា>ទេ<> ក៏ប៉ុន្តែ<ខ្ញុំជឿថា>នៅក្នុងទស្សនៈរបស់វៀតមិញហ្នឹង គឺវា<ជាគំនិតដាច់ខាត>ដូចគ្នា <ហើយនេះ>គឺ<>ជា<ប្រភេទពាក្យពេចន៍ដែលគេប្រើ>នៅក្នុងគុក<> គេតែងតែប្រើពាក្យស្លោកនេះ។ វាដូចជាអនុសាសន៍មួយដែលប្រាប់ទៅដល់ឆ្មាំគុក ឬក៏មេគុកឱ្យប្រុងប្រយ័ត្ន ជាពិសេស គឺនៅពេលដែលដោះលែងអ្នកណាម្នាក់នោះ កុំឱ្យ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លែងច្រឡំឱ្យសោះ។ ហើយបើចាប់អ្នកណាមកដាក់គុកខុស ទោះបីជាមិនមានទោសអ្វីក៏ដោយ គឺមិនអីទេ ពីព្រោះថា<គោលដៅរបស់>បដិវត្តន៍នោះ គឺមានភាពអស្ចារ្យណាស់។ អ៊ីចឹងសុខចិត្តចាប់អ្នកណាក៏ដោយ ចាប់ចុះ កុំឱ្យតែលែងខុស។

[០៩:២០:២៩]

**ស៖** ជាទូទៅពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះមនុស្សដែលគេចាប់ និងឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំង តើអ្នកទាំងអស់ហ្នឹង ទទួលបាននូវការធានាតាមរយៈដំណើរការតុលាការជាទូទៅទេ? ដូចជាឧទាហរណ៍ថា អ្នកទោសហ្នឹងមានមេធាវីទេ ហើយពួកគេអាចតវ៉ាប្រឆាំងនឹងបទចោទរបស់ខ្លួនបានទេ មានសិទ្ធិក្នុងការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបទេ មានសិទ្ធិតវ៉ានៅចំពោះមុខចៅក្រមទេ មានសិទ្ធិប្តឹងឡើងទៅតុលាការថ្នាក់ខ្ពស់អី ឡើងតទៅទៀត ដូចយើងសព្វថ្ងៃនេះទេ?

**ឆ៖** សំណួរហ្នឹង គឺដូចជាលោកដឹងចម្លើយហើយ គឺមិនមានការធានាផ្លូវច្បាប់អ្វីទេនៅក្នុងសម័យខ្មែរក្រហម ដូចនៅក្នុងប្រទេសប្រជាធិបតេយ្យនោះ គឺមិនមានទេ។ សូមអភ័យទោស ខ្ញុំដូចជាវង្វេងខ្លួនឯង។

**ស៖** មិនអីទេ ឥឡូវខ្ញុំបន្តទៅសំណួរទៀត។ តើលោកពន្យល់យ៉ាងម៉េចបានថា <ហេតុអ្វី>មេដឹកនាំខ្មែរក្រហមបានបង្កើតប្រព័ន្ធមួយដែលនាំឱ្យមានការចាប់ខ្លួន និងសម្លាប់ចោលក្រៅផ្លូវតុលាការដោយ<សារតែ>គ្មានការ<ធានាតាមផ្លូវច្បាប់>? ហេតុអីបានជាមេខ្មែរក្រហម បង្កើតប្រព័ន្ធបែបនេះឡើង?

[០៩:២២:០៥]

**ឆ៖** បាទ វាក្រៅផ្លូវតុលាការមែន មិនដូចប្រទេសប្រជាធិបតេយ្យដែលយើងស្គាល់ទេ។ សម័យនោះ គេលុបចោលហើយប្រព័ន្ធតុលាការ។ ហើយ អៀង សារី ក៏បានប្រកាសផងដែរ នៅពេលដែលគេសម្ភាសគាត់នៅបរទេស គាត់ថា នៅកម្ពុជាប្រជាធិបតេយ្យអត់មានគុកទេ។ អ៊ីចឹង<បើតាមន័យរបស់ពាក្យ គឺវា>ត្រឹមត្រូវណាស់។ មិនមានគុកដូច<ដែលយើងដឹងនៅតាមប្រទេសធម្មតា ឬក៏>នៅក្នុងប្រទេសប្រជាធិបតេយ្យទេ។ តើ<ចំណុចនេះអាចធ្វើយុត្តិកម្មបានដោយរបៀបណា>? ពីព្រោះថា ខ្មែរក្រហមហ្នឹង គាត់ប្រញាប់ប្រញាល់ពេក ហើយភាពសាហាវឃោរឃៅរបស់របបនេះ គឺថាវាមានមូលហេតុពីរ។ នៅក្នុងប្រវត្តិនៃសង្គ្រាមត្រជាក់ ឬនៅក្នុងប្រវត្តិនៃការបង្កើតប្រព័ន្ធកុម្មុយនីស្ត គឺពួកគេក្រោយគេ ពួកគេមកក្រោយគេ។ អ៊ីចឹងហើយបានជាពួកគេមានការព្រួយបារម្ភ ថាទៅមិនទាន់អ្នក

ផ្សេង ដោយសារតែគេបានចាប់ផ្តើម<៤០, ៥០, ៦០, ៧០>ឆ្នាំមុនទៅហើយ។ ដូចជាពួកសូវៀតជាដើម<គឺវាសឹងតែ៧០ឆ្នាំមុនទៅហើយ>។ អ៊ីចឹងគេត្រូវតែផ្តោះជំហានខ្លះ ដើម្បីឲ្យទៅទាន់គេ។

ហើយទី២ ផ្ទុយទៅនឹងប្រទេសភាគច្រើនទៀត ដែល<ក្លាយជា>ប្រទេសកុម្មុយនីស្តនោះ គឺមិនមានជនពួកកុម្មុយនីស្ត<ភាគតិច>ដូចជានៅសូវៀត នៅវៀតណាមទេ។ ជនកុម្មុយនីស្តពិតប្រាកដ នៅប្រទេសកម្ពុជា មិនមានលើសពី១ភាគរយនៃប្រជាជនទេ។ ដូច្នេះដើម្បីឲ្យគេស្តាប់បង្គាប់ពួកគេនុ៎ង គឺខ្មែរក្រហម គេប្រើអំពើហិង្សាខ្លាំងបំផុត។ ជាពិសេស ធ្វើឲ្យពួកគេភ័យខ្លាច ដោយសារតែពួកគេកុម្មុយនីស្ត ជនកុម្មុយនីស្តហ្នឹងមានគ្នាតិចពេក អ៊ីចឹងហើយបានជាគេៗគេបង្កើតនយោបាយហ្នឹង ធ្វើឲ្យប្រជាជនភ័យខ្លាច ហើយពួកគេប្រញាប់ប្រញាល់ ដើម្បីឲ្យទៅទាន់ប្រទេសផ្សេងទៀត ហើយហ្នឹងជាចំណុចមួយ។ ចំណុចទី២ គឺថា ពួកគាត់មានគ្នាតិចពេក អ្នកកុម្មុយនីស្តនៅកម្ពុជាហ្នឹង ហើយពួកគេដូចជាជាតិនិយមជ្រុលពេក។ អ៊ីចឹងហើយពួកគេមើលឃើញអំពីភាពអស្ចារ្យនៅសម័យអង្គរ ហើយគេឃើញសូវៀតដែលមានភាពអស្ចារ្យនោះ ពួកគេចង់ធ្វើបដិវត្តន៍ ដើម្បីឲ្យក្លាយខ្លួនទៅជាបដិវត្តន៍គំរូនៅលើពិភពលោក។ ហើយយើងឃើញថា គំរូហ្នឹង វាចេញពីមូស្គូមកប៉េកាំង បន្ទាប់មកពីប៉េកាំងមកដល់ភ្នំពេញ។

[០៩:២៤:៥៨]

**ស៖** ពាក់ព័ន្ធនឹងប្រធានបទ ពាក់ព័ន្ធទៅនឹងយុត្តិធម៌ ឬក៏សច្ចធារណ៍និរទោស។ តើអ្នកសួរចម្លើយ មានសិទ្ធិសេរីភាពនៅក្នុងការសួរនាំ<អ្នកទោស>អំពីសុពលភាពនៃ<ទស្សនៈ>របស់អង្គការ<ដែលចោទប្រកាន់ពួកគេ>ទេ? នៅពេលដែលពួកគាត់សួរចម្លើយអ្នកទោសហ្នឹង តើគាត់មានសិទ្ធិសម្រេចថា អ្នកទោសហ្នឹងគ្មានទោសទេ អីអ៊ីចឹងទេ អាចប្រឆាំងនឹងអង្គការបានទេ ពីព្រោះអង្គការកំណត់ថាអ្នកហ្នឹងមានទោសរួចទៅហើយ?

**ឆ៖** ដូចដែលខ្ញុំបាននិយាយកាលពីម្សិលមិញហើយ។ នៅក្នុងគុកថ្នាក់ខេត្តទាំងអស់ មានការដោះលែងអ្នកទោស។ នៅដើមរបបមានដោះលែងច្រើន ប៉ុន្តែនៅចុងរបបមិនសូវមានប៉ុន្មានទេ។ ភាគច្រើនអ្នកដែលត្រូវគេចោទប្រកាន់ហ្នឹងជាកម្មករ កសិករនៃវណ្ណៈអធន ដែលជាប្រជាជន ឬក៏ជាកសិករសាមញ្ញ ពួកគាត់អាចតវ៉ាថាពួកគាត់គ្មានកំហុសបាន។ ហើយពេលហ្នឹងគេពិនិត្យផ្ទៀងផ្ទាត់នៅតាមសហករណ៍មើល ថាតើប្រជាជនសាមញ្ញទាំងអស់ហ្នឹងនិយាយហ្នឹងពិត ឬក៏មិនពិត។ ហើយបើសិនជាគេឃើញថា ពិតមែននោះ គេដោះលែង អាហ្នឹងក្នុងករណីជាកសិករក្រីក្រសាមញ្ញធម្មតា។ ដូច្នេះក្នុង

ករណីខ្លះនោះ ក្រោយពីការសួរចម្លើយហើយគេដោះលែង។ ហើយបើឲ្យខ្ញុំប្រាប់ថា តើប៉ុន្មានភាគរយដោះលែងនោះ ខ្ញុំពិបាកនិយាយណាស់។ ខ្ញុំមិនអាចនិយាយជាលក្ខណៈទូទៅទៅលើរបបនេះបានទេ។ ពីព្រោះថានេះវាគឺជាបញ្ហាពិបាកមួយ ព្រោះថានៅសហករណ៍មួយនោះវាមានលក្ខណៈផ្សេង សហ-ករណ៍មួយទៀតទៅក៏ផ្សេង ការប្រព្រឹត្តហ្នឹងគឺវាខុសៗគ្នាពីសហករណ៍មួយទៅសហករណ៍មួយ។ អ៊ីចឹងទៅខ្ញុំមិនអាចនិយាយសរុបជារួមបានទេ។ ក៏ប៉ុន្តែដូចខ្ញុំបានបញ្ជាក់ហើយ ថាពេលដែលខ្ញុំសួរ មឿង សុន នោះគាត់បានប្រាប់ថា ពេលគេដោះលែងគាត់ មានអ្នកមួយចំនួនទៀតក៏ដោះលែងដែរ ប្រហែលជា ៤០, ៥០នាក់ដែរ។ ដូច្នេះចំនួនដោះលែងនេះ គឺយើងមើលទៅឃើញមានច្រើនដែរ។

[០៩:២៧:១៥]

**ស៖** ហើយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នកណាមានអំណាចក្នុងការសម្រេចដោះលែង ឬក៏សម្លាប់អ្នកណាម្នាក់នៅមន្ទីរសន្តិសុខនោះ? តើជាអ្នកសួរចម្លើយ ឬក៏ជាមេគុក ឬក៏ជាថ្នាក់លើនៅពីលើគុកហ្នឹងទៀត ដែលជាអ្នកសម្រេចដោះលែង ឬក៏សម្លាប់អ្នកទោសណាម្នាក់នោះ?

**ឆ៖** សំណួរនេះជាសំណួរពិបាកឆ្លើយបំផុត។ ឌុច និយាយម្តងហើយម្តងទៀត ថាគាត់មិនមែនជាអ្នកសម្រេចទេ។ គាត់គោរពបញ្ជាពី សុន សេន ឬពី នួន ជា។ ខ្ញុំនៅចាំថា នៅពេលដែលខ្ញុំពិនិត្យមើលឯកសារចាស់ៗនៅក្រាំងតាចាន់ <តែងតែ>មានចំណារ ហើយនិងមានការឯកភាពឲ្យសម្លាប់ ឬដោះលែងអ្នក<ណា>ម្នាក់ គឺមានការស្នើសុំពីថ្នាក់លើ។ ខ្ញុំគិតថាមិនមែនជាអ្នកសួរចម្លើយ ហើយក៏មិនមែនជាមេគុកដែរ ដែលជាអ្នកសម្រេចដោះលែង ឬសម្លាប់អ្នកណាម្នាក់នោះ។ ខ្ញុំគិតថាជាស្នងការនយោបាយថ្នាក់ស្រុក ពីព្រោះថាគុកភាគច្រើនជាគុកថ្នាក់ស្រុក។ អ៊ីចឹងខ្ញុំគិតថាមានតែស្នងការនយោបាយហ្នឹងហើយជាអ្នកសម្រេចដោះលែង ឬក៏សម្លាប់នោះ។ ក៏ប៉ុន្តែខ្ញុំអត់មានព័ត៌មានអីជាក់លាក់ត្រង់ចំណុចហ្នឹងទេ ព្រោះថាខ្ញុំមិនដែលបានសម្ភាសស្នងការនយោបាយស្រុកទេ មិនដឹងថាតើដំណើរការហ្នឹងវាយ៉ាងម៉េចទេ។

**ស៖** ចំណុចពីរពាក់ព័ន្ធនឹងការដោះលែង។ នៅពេលលោកនិយាយអំពីការដោះលែង លោកថាលោកនិយាយអំពីអ្នកទោសសាមញ្ញ និងកសិករធម្មតា។ តើអ្នកទាំងអស់ហ្នឹងគេចោទថាប្រព្រឹត្តកំហុសស្រាលមែនទេ? ចុះប្រជាជនថ្មីនោះមានការដោះលែងទេ? លោកនិយាយអំពីកសិករ កម្មករវណ្ណៈអធនអ៊ីចឹងខ្ញុំចង់សួរលោកពីប្រជាជនថ្មីវិញម្តង តើមានការដោះលែងប្រជាជនថ្មីទេ? ហើយការដោះលែងនេះគេដោះលែងតែអ្នកទោសស្រាលទេមែនទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:២៩:៣២]

**ធ៖** បាទ លោកដូចជាមានឧទាហរណ៍មួយចំនួនហើយ។ ឥឡូវខ្ញុំត្រលប់មកនិយាយអំពី មឿង សុន ហើយនិង<ប្រពន្ធគាត់ឈ្មោះ> ផល្លី ដែលត្រូវបានចាត់ទុកជាប្រជាជនថ្មី ពីព្រោះថាគាត់ជាប្រជាជននៅកំពង់សោម។ គាត់ធ្វើការនៅរោងចក្រចម្រាញ់ប្រេងកាត គាត់មានការអប់រំ។ គាត់ទៅធ្វើកម្មសិក្សានៅប្រទេសបារាំង អ៊ីចឹងជាអ្នកចេះដឹងហើយ។ ក៏ប៉ុន្តែគាត់ត្រូវបានគេដោះលែង។ ហើយចំពោះទោសស្រាល ទោសធ្ងន់នោះ គេថាអ្នកឯងត្រូវបានគេដាក់គុកដោយសារតែលួចចេក ឬក៏លួចក្ដួរស្រូវ។ ដូច្នេះ<ច្បាប់>ទូទៅ<>ដែល<យើងឮ>គេនិយាយនៅក្នុងសុន្ទរកថាហ្នឹងគឺថា<នៅ>ពេល<មានទោសកំហុសស្រាលទាំងអស់នេះ ដូចជា>អ្នកខ្លះដេក លួចដេកពេលធ្វើការ។ អ៊ីចឹងអ្នក<ហ្នឹង>ត្រូវតែសារភាពនៅក្នុងពេលប្រជុំទិតៀន ស្វ័យទិតៀននៅពេលល្ងាច។ អ៊ីចឹងអ្នកដែលប្រព្រឹត្តហ្នឹងគេព្រមាន។ ហើយបើសិនជាប្រព្រឹត្តដដែលៗ លួចរបស់កំប៉ិកកំប៉ុកដដែលហ្នឹងទៀត គេចាប់ដាក់គុកហើយ។ ក៏ប៉ុន្តែជាថ្មីម្ដងទៀតគឺអត់មានច្បាប់ អត់មានវិធានអីច្បាស់លាស់ទេត្រង់ចំណុចនេះ។ <ដូច្នេះហើយវាច្របូកច្របល់មែនទែន ហើយវាអាចអ៊ីចឹងដែរ> ជួនកាលទៅនៅកន្លែងខ្លះទៅ អ្នកខ្លះប្រព្រឹត្តកំហុសធ្ងន់ផងដូចជារំលោភសេពសន្ថវៈជាដើម ដោយថាពីសម័យនោះ គេហាមមិនឲ្យមានការរួមភេទ<ដោយគ្មានការអនុញ្ញាត>ទេ។ ហើយបើអ្នកណាប្រព្រឹត្តហ្នឹងគេសម្លាប់។ ក៏ប៉ុន្តែជួនកាលទៅ គេលើកលែងដែរចំពោះខ្មែរក្រហមខ្លះគេអត់សម្លាប់ទេនៅពេលដែលរំលោភអីអ៊ីចឹងនោះ។ អ៊ីចឹង<វាពិបាកឆ្លើយឲ្យបានច្បាស់លាស់ទៅនឹងសំណួរលោក ព្រោះថា> អត់មានវិធានច្បាប់អីច្បាស់លាស់ទេ។

[០៩:៣១:២៣]

**ស៖** លោកថាមានអ្នកគេដោះលែងដែរ អ៊ីចឹងលោកបូកបញ្ចូលទាំងអ្នកដែលគេដោះលែងនៅគុកដើម្បីឲ្យទៅធ្វើការ ឬក៏លោកសំដៅតែលើអ្នកដែលត្រូវបានដោះលែងតែម្ដង គឺថាឲ្យទៅផ្ទះ ឬក៏ទៅសហករណ៍របស់ខ្លួនវិញ ឬក៏ទៅឃុំរបស់ខ្លួន ឬក៏ទៅកងវិញ? កាលពីម្សិលមិញហ្នឹងលោកនិយាយថាអ្នកខ្លះហ្នឹងមិនមែនដោះលែងឲ្យមានសេរីភាពតែម្ដងទេ គឺគេបញ្ជូនទៅជំរំអប់រំទៀត។ អ៊ីចឹងខ្ញុំចង់សួរលោកឲ្យបានច្បាស់នោះ ថានៅពេលដែលលោកនិយាយអំពីការដោះលែងហ្នឹង លោកសំដៅយ៉ាងម៉េច? ដោះលែងឲ្យមានសេរីភាពទាំងស្រុង ឬក៏ដោះលែងហើយ យកបញ្ជូនទៅណាទៀត?

**ធ៖** ឥឡូវយើងបែងចែកឲ្យបានច្បាស់ រវាងការដោះលែងឲ្យមានសេរីភាពទាំងស្រុង ហើយនិង<អ្នកដែលគេបានទុកនៅក្នុង ស-២១ ដើម្បី>ឲ្យធ្វើការ ដូចជា វ៉ាន់ ណាត នៅស-២១អ៊ីចឹង គេដោះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លែងគាត់ គេទុកឲ្យគាត់ធ្វើការនៅគុកស-២១។ អ្នកហ្នឹងខ្ញុំអត់ចាត់ទុកដូចជាត្រូវបានគេដោះលែងទេ ព្រោះថានៅជាប់គុកដដែល។ ដូចជានៅកោះខ្យង មឿង សុន ដែលគេឃុំអ៊ីចឹង គេដោះលែងគាត់ ប៉ុន្តែគេឲ្យគាត់ជួសជុលម៉ាស៊ីនកប៉ាល់ ម៉ាស៊ីនទូកដែលគេបាញ់លិចអីជាដើមនោះ។ អ៊ីចឹងអាហ្នឹងមិនមែនមានន័យថា ដោះលែងទេ គាត់នៅតែជាអ្នកគុកដដែលហ្នឹង អ្នកទោសនៅក្នុងគុកដដែល។ ដូច វ៉ាន់ ណាត អីជាដើមនៅស-២១ហ្នឹង អាហ្នឹងមិនមែនជាការដោះលែងទេ។ វាមានការដោះលែងពីរប្រភេទ។ ទី១ គេដោះលែង ហើយ គេឲ្យទៅធ្វើនៅជំរំអប់រំកែប្រែ ហើយមួយទៀតទៅសហករណ៍។ ការត្រឡប់ទៅសហករណ៍នោះ គេមិនបញ្ជូនទៅឃុំដើមទេ គេទៅឲ្យទៅសហករណ៍ផ្សេងណាទៀត ពីព្រោះថាគុកហ្នឹងគឺជាគុកសម្ងាត់ អ៊ីចឹងគេចង់លាក់ការណ៍ណាស់ គេមិនឲ្យប្រជាជនដឹងថានៅកន្លែងហ្នឹងមានគុកទេ។ ពេលគេដោះលែងពីគុកហ្នឹង គេបញ្ជូនទៅសហករណ៍ផ្សេង ហើយគេប្រាប់អ្នកហ្នឹងថា កុំឲ្យនិយាយអីឲ្យសោះនៅពេលដែលអ្នកឯងនៅមន្ទីរសន្តិបាលហ្នឹង កុំនិយាយរឿងរ៉ាវនៅក្នុងហ្នឹងប្រាប់គេឲ្យដឹងឲ្យសោះ។

[០៩:៣៣:៣៦]

**ស៖** ឥឡូវខ្ញុំចង់ឲ្យលោកពិនិត្យមើលសក្ខីកម្មពាក់ព័ន្ធនឹងស-២១ ដែលហាក់ដូចជាខុសពីអ្វីដែលលោកបាននិយាយគឺ ប្រាក់ ខន គាត់ជាអ្នកសួរចម្លើយនៅទីនោះ។ នៅពេលដែលគាត់ផ្តល់សក្ខីកម្មនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ គឺឯកសារ E1/423.1 គឺ E1/423.1 នៅម៉ោង១៤:៣០:៥៦វិនាទី។ ពេលនោះខ្ញុំសួរគាត់ដូចតទៅ ខ្ញុំសូមដកស្រង់៖ "ខ្មាំងដែលចូលស-២១ តើ ឌុច មានប្រាប់លោកទេថាអង្គការច្រឡំ ចាប់មនុស្សច្រឡំ? ពេលនោះគាត់ ប្រាក់ ខន គាត់ឆ្លើយដូចតទៅ៖ ខ្ញុំមិនដែលឮគេនិយាយអំពីការចាប់ច្រឡំបែបនេះទេ។ ពាក្យច្រឡំនេះគេមិនដែលប្រើទេ អ្នកណាក៏ដោយ ដែលគេចាប់ហើយនាំខ្លួនយកមក ស-២១ ហ្នឹងគឺសុទ្ធតែត្រូវបានគេចាត់ទុកថាជាខ្មាំងទាំងអស់។" សូមបញ្ចប់ការដកស្រង់។ ហើយ ឌុច ហ្នឹងក៏បាននិយាយអ៊ីចឹងដែរ ថាមិនមានការដោះលែងទេ នៅស-២១។

អ៊ីចឹងលោកមានការភ្ញាក់ផ្អើលទេ នៅពេលដែលអតីតអ្នកសួរចម្លើយនៅស-២១ និយាយថាមនុស្សណាក៏ដោយ ដែលគេយកមកចូល ស-២១ ហើយ សុទ្ធតែត្រូវបានគេចាត់ទុកជាខ្មាំងទាំងអស់មុនពេលសួរចម្លើយទៅទៀត?

[០៩:៣៥:២២]

**ឆ៖** បាទ ខ្ញុំបានពិចារណាដូចលោកដែរ គឺថារយៈពេលវែង ទម្រាំតែជឿជាក់។ <ហើយខ្ញុំមិន

ច្បាស់ទាំងស្រុងទេ>ថា ឌុច ហ្នឹង<>និយាយការពិត<នោះ>ទេ។ ក៏ប៉ុន្តែទន្ទឹមនឹងនោះ យើងត្រូវតែដឹងថា មន្ទីរស-២១ ជាកន្លែងដែលខ្ពស់ជាងគេនៃគុកផ្សេងៗ ក៏ប៉ុន្តែជាគុកពិសេសទេ។ ទី១ គឺថាជាគុកមួយដែលមានសិទ្ធិអំណាចទូទាំងប្រទេស ខុសពីគុកផ្សេងៗទៀត ដែលមានសិទ្ធិអំណាចនៅតែកន្លែងខ្លួនទេ។ ហើយបើយើងមើលទៅ នៅពេលចាប់ផ្តើមដំណើរការដំបូងនៃមន្ទីរស-២១ គឺជាគុកសម្រាប់កម្មាភិបាលខ្មែរក្រហម ស៊ីវិលហើយនិងយោធា។ ហើយបន្ទាប់មកទៀត គឺអ្នកដែលគេបញ្ជូនទៅមន្ទីរស-២១នោះ បើយើងជឿតាមពាក្យសម្តី ឌុច នោះ គឺអ្នកដឹកនាំប្រទេសជាអ្នកបញ្ជូនទៅ គឺដោយ ម-៨៧០។ អ៊ីចឹងគឺជា -- បើយើងមើលទៅ ប៉ុល ពត និង នួន ជា ជាអ្នកត្រូវរហូត។ អ៊ីចឹងមិនត្រូវសង្ស័យអំពីសេចក្តីសម្រេចរបស់ពួកគាត់ និងមនោគមន៍វិជ្ជារបស់ពួកគាត់ទេ។ ប៉ុន្តែម្យ៉ាងទៀត ដូចដែលខ្ញុំលើកឡើងកាលពីម្សិលមិញនោះ ខ្ញុំបានរកឃើញគុកពីរបីទៀត នៅខេត្តនោះ ដែលគេទុកសម្រាប់ឃុំឃាំងខ្លួនកម្មាភិបាលខ្មែរក្រហមដែរ គឺថានៅអូរវាំងឌី នៅក្នុងសំណុំឯកសារខ្ញុំ ខ្ញុំមានព័ត៌មានលម្អិតច្រើន។

ហើយគុកនៅអូរវាំងឌីនោះ គឺទុកសម្រាប់ដាក់កម្មាភិបាលយោធាខ្មែរក្រហម។ អេម៉ៃតេ គាត់និយាយប្រាប់ខ្ញុំថា ពួកអ្នកទោសទាំងអស់នោះ ត្រូវបានគេសម្លាប់ទាំងអស់ មិនមានករណីលើកលែងទេ។ ឥឡូវនេះវាលើគុកហ្នឹង យើងលែងមានឃើញហើយ ក៏ប៉ុន្តែមានផ្លូវនៅឡើយ មានរណ្តៅដដែល។ ហើយរបប ហ៊ុន សែន បានធ្វើកន្លែងបូជនីយស្ថានមួយនៅទីនោះ។ របប ហេង សំរិន នោះ គាត់គិតថាជាកន្លែងសំខាន់ដែលគួរតែ ដែលចាំបាច់ត្រូវធ្វើបូជនីយស្ថាននោះ។ <នេះប្រហែលជាដោយសារតែ> មានអ្នកដឹកនាំនៃរបបបន្ទាប់មកទៀតនោះ <និងអ្នកដែលដឹងឮពីរបបបន្ទាប់ទៀត>ក៏ត្រូវបានសម្លាប់នៅទីនោះដែរ។ ក៏ប៉ុន្តែខ្ញុំសូមធានាថា នៅកន្លែងនោះអ្នកទោសទាំងអស់សុទ្ធតែត្រូវបានសម្លាប់ទាំងអស់។ អ៊ីចឹង ប្រាក់ ខន នេះ និង ឌុច នេះប្រហែលជានិយាយការពិតហើយ ពីព្រោះកន្លែងមន្ទីរស-២១នេះ ជាកន្លែងមួយមានតួនាទីចាំបាច់។

[០៩:៣៨:០៧]

**ស៖** នៅលេខរៀងទី៤២ ជាភាសាបារាំង, ៥០ ជាភាសាអង់គ្លេស គឺឯកសារ E3/2812។ គេនិយាយថា "នៅពេលដែលយើង<ដក>ស្មៅ <ដក>ទាំងឫស"។ អ៊ីចឹងយើងឃើញពាក្យ "<ដក>" នេះទៀតហើយ។ អ៊ីចឹងខ្ញុំសួរលោក ថាតើគេអនុវត្តពាក្យស្លោកនេះ ក្នុងស្ថានភាពណាដែរ?

**ឆ៖** បាទ ដូចពាក្យស្លោកមុនដែរ ដែលលោកឲ្យខ្ញុំអត្ថាធិប្បាយនេះ គឺថាវាជាទស្សនៈមួយ លទ្ធិមួយ ដែលផ្សាយផ្សព្វទៅជនកុម្មុយនីស្តអាស៊ីទាំងអស់ ហើយមានពាក្យស្លោកនេះដែរ នៅក្នុងក្រោម

របប ម៉ៅ សេទុង។ នៅក្រោមរបបកុម្មុយនីស្ត ម៉ៅ សេទុង ហ្នឹង កាលណាគេចាប់ប្ដី គេចាប់ប្រពន្ធដែរ ហើយកូនដែរ។ តើពួកគាត់ទាំងអស់នោះ ត្រូវគេសម្លាប់ដាច់ខាត ឬក៏ជាស្វ័យប្រវត្តិ ឬក៏យ៉ាងណា? <ប្រហែលជា>មិន<>ទេ ក៏ប៉ុន្តែដឹងតែថាប្រពន្ធកូន ក៏គេធ្វើបាបដែរ។ <យើងក៏ដឹងដែរថា នៅក្នុង> របបកុម្មុយនីស្ត<វៀតណាម កូនចៅរបស់>អ្នកជំទាស់ប្រឆាំងនឹងរបបនុ៎ង វាជាការលំបាកណាស់ ដែលក្នុងការទទួលការអប់រំនៅវិទ្យាល័យ ឬមហាវិទ្យាល័យជាដើមនោះ។ <ដូច្នេះ ការបង្ក្រាបមួយចំនួន ត្រូវបានគេធ្វើទៅលើគ្រួសារទាំងមូលតែម្ដង។> ដូចកន្លែងផ្សេងដែរ គឺថាខ្មែរក្រហមគាត់យកគំនិតពីគេមក ហើយគាត់ធ្វើ យកមកអនុវត្តឱ្យជ្រុលនិយមហួសហេតុ។ អ៊ីចឹងអង្គាល់នៅខែមិថុនាដែលតុលាការសម្ភាស ឌុច នេះ សួរ ឌុច នេះទាក់ទងនឹងការសម្លាប់កុមារនៅមន្ទីរស-២១ ជាដើមនោះ អ៊ីចឹងគឺថា នៅស្រុកខ្មែរហ្នឹងគឺថា នៅគុកផ្សេងៗទៀតក៏មានសម្លាប់អ៊ីចឹងដែរ។ ឧទាហរណ៍ដូច មឿង សុន ពេលដែលគេចាប់គាត់នោះ គេបានកុហកគាត់ថា គេហៅគាត់ទៅធ្វើការនៅរោងចក្រចម្រាញ់ប្រេង នៅកំពង់សោម ហើយក៏ប្រពន្ធគាត់កាលនោះមានទម្ងន់ ហើយកូនគាត់នោះក៏គេយកទៅដែរ។ អ៊ីចឹងកូនគាត់ទាំងពីរនាក់នោះ ស្លាប់ដោយអត់ឃ្លាន ហើយប្រពន្ធគាត់នោះ កើតកូនមកបីអាទិត្យក្រោយមកកូននោះក៏ស្លាប់ដែរ ដោយសារម្ដាយគ្មានទឹកដោះឱ្យកូនបៅ។ អ៊ីចឹងនេះជាឧទាហរណ៍មួយ ដែលថាគេមិនចាប់ត្រឹមតែឪពុកម្ដាយទេ គេថែមទាំងចាប់កូនចៅទៀតផង។

[០៩:៤១:០២]

**សៈ** តើខ្មែរក្រហមមានហេតុផលអីដែលអះអាងថា កាលណាចាប់ប្ដីហើយ គេត្រូវចាប់ប្រពន្ធកូនទៀតនោះ? តើខ្មែរក្រហមគេមានហេតុផលអីដែរ បានគេចាប់ទៅដល់ប្រពន្ធ ហើយកូនទៀតនោះ? ពីព្រោះថា ជួនកាលពួកគាត់ហ្នឹងមិនបានប្រព្រឹត្តកំហុសអីទេ ហើយក៏គាត់ត្រូវទទួលជោគវាសនាដូចឪពុក ឬក៏ប្ដីដែរនោះ តើខ្មែរក្រហម គាត់មានមូលហេតុអីដែរនៅពីក្រោយ?

**ឆៈ** លោកសហព្រះរាជអាជ្ញា ខ្ញុំគិតថាលោកដឹងចម្លើយហើយៗ។ ខ្មែរក្រហមគេប្រាកដប្រជាជាពិសេសហ្នឹង នួន ជា តែម្ដងគឺគិតថា អាទិភាពនៃអាទិភាពទាំងអស់នោះ គឺត្រូវការពារមេដឹកនាំពីរបីនាក់ហ្នឹង <>គឺថាអ្នកទាំងបីនាក់ធំៗហ្នឹង ដែលដឹកនាំប្រទេសហ្នឹង ប៉ុល ពត, នួន ជា, ខៀវ សំផន ហ្នឹងត្រូវតែការពារពួកគាត់ទាំងបីនាក់ហ្នឹង ដើម្បីធានាអនាគតនៃបដិវត្តន៍<ឱ្យមានអាយុកាលដល់ ១០.០០០>ឆ្នាំ<ដូច នួន ជា និយាយអ៊ីចឹង>។ <ដូច្នេះគេត្រូវតែសម្លាប់កូនៗរបស់ពួកក្បត់> ព្រោះគាត់គិតថា ថ្ងៃណាមួយ <កុមារទាំង>អស់ហ្នឹងនឹងសងសឹក។ អ៊ីចឹងនឹងក្លាយជាខ្មាំង ហើយទៅសងសឹក

នឹងអ្នកដឹកនាំរបស់បដិវត្តន៍។ អ៊ីចឹងបំផ្លាញបដិវត្តន៍។ <ដូច្នេះហើយគេត្រូវតែការពារមេដឹកនាំ និងបដិវត្តន៍ជាដាច់ខាត។>

**ស៖** <នៅក្នុងការស្រាវជ្រាវរបស់លោក>ទាក់ទងនឹងមន្ទីរសន្តិសុខនោះ តើលោកមានដឹងដែរឬទេ ថាកុមារ ហើយនិងស្ត្រីដែលគេនាំយកទៅចូលមន្ទីរឃុំឃាំង ឬក៏គុកហ្នឹង គេមានចុះឈ្មោះពួកគាត់ទេ?

[០៩:៤៣:០៥]

**ឆ៖** បាទ ខ្ញុំគិតថា ដូចនៅមន្ទីរស-២១ ដែរ។ ករណី មឿង សុន ហើយនិង ផល្លី ជាប្រពន្ធគាត់នេះ នៅក្នុងសៀវភៅសរសេរ នៃការចងចាំរបស់ខ្ញុំនោះ មានរូបគំនូរមួយ<អំពីគុក។> គឺថាកុមារហើយនិងប្រពន្ធអីនេះ ម្ដាយហើយនិងកូននេះ គេមិនដាក់ខ្នោះទេ។ ហើយអ្នកទោសជាច្រើនដែលយើងមានសាក្សី ហ្នឹង រិទ្ធី ប៉ាន់ នោះក៏កំពុងតែថតកុនដែរ។ យើងឃើញមានកុមារជាច្រើនដែលនៅរស់រានមានជីវិត ក្នុងខណៈដែលឪពុកម្ដាយរបស់គាត់ត្រូវជាប់គុកនោះ ហើយកុមារៗនោះ គេមិនដាក់ខ្នោះទេ។ ភាគច្រើនហ្នឹងគេសម្លាប់មែន ក៏ប៉ុន្តែ ឧទាហរណ៍មួយដូចជា សេង ធារី ហ្នឹងសរសេរសារណាការចងចាំរបស់គាត់នោះ នៅពេល<នោះ>គាត់<នៅ>ស្វាយរៀង ព្រៃវែងនោះ សេង ធារី នោះបានរស់រានមានជីវិតដែរ។ អ៊ីចឹងកុមារនោះ គេមិនសម្លាប់ភ្លាមដូចនៅមន្ទីរស-២១ នោះទេ។ អ្នកខ្លះគេគាត់នៅរស់បាន គេឲ្យការងារបន្តិចបន្តួចធ្វើការទៅ ធ្វើការស្រាលៗទៅ <ឬក៏សែងលាមកអីជាដើម>។ ហើយនៅគុក នៅសៀមរាបនោះ យើងមើល ស្រមើស្រមៃមើលតែពីជោគវាសនារបស់ពួកកុមារទាំងអស់នោះទៅ ស្ថានភាពពួកគាត់ហ្នឹងយ៉ាងម៉េច នៅឯណោះ ហើយយើងចង់ស្រក់ទឹកភ្នែក។

**ស៖** សំណួររបស់ខ្ញុំ សំណួរៗខ្ញុំអម្បាញ់មិញ គឺខ្ញុំសួរថាតើគេមានចុះឈ្មោះកុមារ ឬក៏ម្ដាយដែលគេយកទៅឃុំឃាំងហ្នឹងដែរឬទេ ទៅក្នុងគុកដែរឬទេ? សំណួរខ្ញុំនោះ។

**ឆ៖** ខ្ញុំគិតថា គេមិនចុះឈ្មោះទេ។ ម្សិលមិញខ្ញុំបានអានអត្ថបទរបស់ខ្ញុំដែលទាក់ទងនឹងក្រាំងតាចាន់នោះ ព្រោះខ្ញុំបានទៅក្រាំងតាចាន់ ខ្ញុំកត់សម្គាល់ឃើញថា មានចន្លោះពីប្រាំមួយទៅ<១០>នាក់ក្មេងជំទង់ <ដែលមានអាយុក្មេងជាង១៨ឆ្នាំ អ៊ីចឹងយើងអាចចាត់ទុកថាជាកុមារ>។ អ៊ីចឹងក្នុងចំណោមអ្នកទោសជាង៤០០នាក់ហ្នឹង ៤៧៧ហ្នឹង <នៅក្រាំងតាចាន់>គឺថាមានក្មេងជំទង់ប្រាំមួយ<ឬ>ប្រាំ<ពីរ>នាក់ហ្នឹងដែលគេចុះឈ្មោះ ហើយ<ពួក>គេ<ត្រូវបាន>សម្លាប់ដែរ<>។

[០៩:៤៥:៣៨]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សះ** ខ្ញុំសូមបំភ្លឺចំណុចមួយ លោកនិយាយថា មានចំនួនស្ត្រី ហើយនិងបុរសហ្នឹង ដែលគេចាប់ខ្លួនហ្នឹងខុសគ្នាច្រើន មានគម្លាតឆ្ងាយ។ អ៊ីចឹងវាខុសគ្នា វាមានភាពផ្ទុយគ្នាអំពីពាក្យស្លោកដែលនិយាយថា តែគេ<>ចាប់ប្រពន្ធ ចាប់កូន<ដែរ>។ អ៊ីចឹងហេតុអីបានជាលោកនិយាយថា នៅក្នុងមន្ទីរសន្តិសុខហ្នឹង គឺមានអ្នកទោសស្រីតិចបំផុត តិចជាងប្រុសនុ៎ង?

**ឆះ** បាទ លោកនិយាយត្រឹមត្រូវហើយ។ បើសិនត្រូវចាប់<>ប្រពន្ធ ចាប់កូននោះ<ដោយស្វ័យប្រវត្តិ នោះ>ត្រូវតែចំនួនស្មើគ្នា<រវាងបុរស និងស្ត្រី> ហើយ<ក្មេងៗត្រូវមានចំនួនច្រើនជាងប្អូនដង។> វាដូចនៅមន្ទីរស-២១ ដែរ អាចចោទសំណួរនេះទៅស្នូរ ឌុច<>។ ដោយសំណាងល្អនៅពេលដែលគេចាប់បុរសនុ៎ង គេមិន<ចាប់>ស្ត្រីជាស្វ័យប្រវត្តិទេ។ ឧទាហរណ៍ចំពោះយោធាក៏អ៊ីចឹងដែរ។ បញ្ហានេះតុលាការបានពិចារណាច្រើនហើយ ការសម្លាប់កងទ័ព លន់ នល់ ទាហាន លន់ នល់ គិតចាប់ពីនាយទាហានជាន់ខ្ពស់ នាយទាហានថ្នាក់កណ្តាល ហើយដល់មកកូនទាហានទៀតនោះ។ <ការពិនិត្យមើលកំណត់ត្រារបស់ខ្ញុំឡើងវិញ ខ្ញុំកត់សម្គាល់ឃើញថា>នៅ<>ឆ្នាំ៧៦, ៧៧<>ហ្នឹង នៅភូមិភាគបូព៌ា គេនៅបន្តចាប់ កាប់សម្លាប់ទាហាន លន់ នល់ ដែរ។ ហើយ<>ពេល<ខ្លះ -- ខ្ញុំឃើញករណីនេះ>នៅពោធិ៍សាត់<> គឺកាលពេលដែលគេសម្លាប់ទាហានទាំងអស់នោះហើយ ក្រោយមកគេទៅធ្វើបាបដល់ប្រពន្ធកូនពួកគាត់ទៀត។ នេះគឺជាការសំខាន់ណាស់ដែលយើងត្រូវដឹងថា យ៉ាងហោចណាស់ក៏មានអ្នកទោស<៨០>ភាគរយ<ជា>អ្នកទោស<>បុរសនៅតាមគុកទាំងអស់<នៅប្រទេសកម្ពុជា>។ ហើយដោយហេតុអ៊ីចឹងហើយ បានជាពេលដែលរបបខ្មែរក្រហមចប់ទៅ នៅសល់ស្ត្រីមេម៉ាយច្រើន។ ហើយក៏គាត់ហ្នឹងក្លាយជាមេគ្រួសារទៅ អ៊ីចឹងជីវភាពពួកគាត់ពិបាកណាស់ក្រោយពីរបបខ្មែរក្រហមចប់ទៅ។

[០៩:៤៨:០០]

**សះ** <ដោយមិនមានការចាប់ប្រពន្ធរបស់>អ្នកទោសបុរស<ទាំងអស់នោះជាស្វ័យប្រវត្តិ> តើពេលដែលប្តីគេចាប់ខ្លួនហើយហ្នឹង គេមានធ្វើការតាមដានគាត់យ៉ាងប្រកិតទេ ថាហ្មត់ចត់ទេ?

**ឆះ** ការស្រាវជ្រាវរបស់ខ្ញុំមិនបានផ្តោតស៊ីជម្រៅដល់ថ្នាក់ហ្នឹងទេ។

**សះ** ពាក្យស្លោកបន្ទាប់ហ្នឹងមាន គឺមានលេខ៨៧ ភាសាបារាំង, ៩៩ ជាភាសាអង់គ្លេស គឺពាក្យស្លោកដែលថា "អង្គការភ្នែកម្នាស់"។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើពាក្យស្លោកនេះ ជាពាក្យស្លោកដែលគេស្គាល់គ្រប់គ្នាដែរឬទេ? តើនៅពេលដែលលោកទៅសម្ភាសគេហ្នឹង គេ

ភាគច្រើន គេសុទ្ធតែស្គាល់ពាក្យស្លោកហ្នឹងទេ? គេមានពន្យល់អីខ្លះដល់លោកទេ?

**ឆ៖** សំណួររបស់លោកហ្នឹង គឺថាមានចម្លើយហើយស្រេចហើយ គឺជាពាក្យស្លោកដែលអ្នកណាក៏ស្គាល់ដែរ។ ហើយនៅក្នុងការសិក្សាស្រាវជ្រាវទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យនោះ អ្នកណាក៏យកពាក្យស្លោកនេះមកសិក្សាដែរ។ <វាជា>ចំណងជើងមួយ<ដែលត្រូវបានគេប្រើ។> ខ្ញុំសូមរំឭកថា ដោយសារពាក្យស្លោកនេះ គេស្គាល់គ្រប់គ្នាទៅ គេបង្កើតពាក្យស្លោកមួយទៀត មកប្រឆាំងនឹងពាក្យស្លោកនេះ។ ឥឡូវខ្ញុំមើលពាក្យស្លោកហ្នឹង គឺថាអង្គការភ្នែកម្នាស់ ក៏ប៉ុន្តែភ្នែកទុំងខ្វាក់ មើលមិនឃើញទុក្ខវិក្ខរបស់ប្រជាជនក្រីក្រទេ។ អ៊ីចឹងគឺថាមានពាក្យស្លោក <ផ្ទុយគ្នាដូចអាមួយនេះអ៊ីចឹង> គឺថាមានពាក្យស្លោក<ផ្ទុយគ្នាគ្រប់ទម្រង់> ដែលគេនិយាយមកឌឺវិញ។ អ៊ីចឹងគឺថានៅពេលសម័យខ្មែរក្រហមដ៏តឹងរ៉ឹងប៉ុណ្ណឹងហើយហ្នឹង ក៏នៅតែប្រជាជនមួយចំនួនបង្កើតពាក្យស្លោកមក ដើម្បីឌឺទៅដល់អាពាក្យស្លោកកម្ពុជាប្រជាធិបតេយ្យដែរ។

[០៩:៥០:៣៣]

**ស៖** *(គ្មានការបកប្រែ)*

**អ្នកបកប្រែ៖**

លោកប្រធានសូមឱ្យព្រះរាជអាជ្ញា គាត់សួរម្តងទៀត ព្រោះអីគាត់សួរដេញដោលគ្នាលឿនពេក អត់មានចន្លោះពេលអ៊ីចឹង ខ្ញុំស្តាប់អត់ទាន់។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងតាំងសំណួរចុងក្រោយរបស់លោកសាជាថ្មីម្តងទៀត ហើយកុំអាលប្រញាប់ពេក អ្នកបកប្រែបកមិនទាន់ទេណា។ ឱ្យមានការឃ្លាតគ្នារវាងការសួរ ហើយនិងឆ្លើយ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ ខ្ញុំសូមអភ័យទោសលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** តើពាក្យស្លោកនេះៗ ប្រជាជនដែលសាមញ្ញទូទៅ ពេលដែលស្តាប់ឮពាក្យស្លោកហ្នឹង គាត់មានអារម្មណ៍យ៉ាងម៉េចដែរ?

**លោក ហង់រី ឡូកា៖**

**ឆ៖** បាទ ពាក្យស្លោកនេះ គឺគេបង្កើតមក ដើម្បីបំភ័យប្រជាជន។ មានមធ្យោបាយពីរ<ក្នុង

ការបំភ័យប្រជាជន> គឺថាទី១ គឺថាប្រើពាក្យសម្ដីគំរាមកំហែង ហើយទី២ ប្រើកាំភ្លើងគំរាមតែម្ដង។ អ៊ីចឹងដែលថាមានមធ្យោបាយពីរហ្នឹង ពីថ្នាក់ដឹកនាំខ្មែរក្រហម ធ្វើយ៉ាងម៉េចដាក់ប្រជាជននៅក្រោមនឹមរបស់ខ្លួន។

[០៩:៥១:៥៧]

**ស៖** ពាក្យស្លោកបន្ទាប់ទៀត គឺថាមានលេខ៧៦ ជាភាសាបារាំង, ៨៨ ជាភាសាអង់គ្លេស គឺគាត់និយាយអំពីពូជ<សាសន៍> ហើយមាននិយាយ<ដូចត>ទៅ <"តើអ្នក>ស្រឡាញ់វណ្ណៈ<សង្គម> របស់ខ្លួន ស្រឡាញ់ពូជរបស់ខ្លួន <>ស្រឡាញ់អង្គការ<ទេ?"> អ៊ីចឹងសូមឲ្យលោកជួយពន្យល់ពីខ្លឹមសារនៃពាក្យស្លោកនេះ ហើយជាពិសេសហ្នឹងគឺពាក្យថា "វណ្ណភាព" នៅក្នុងក្រោមរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង មានន័យយ៉ាងម៉េចដែរ? តើមានវណ្ណភាពច្រើន ឬក៏យ៉ាងណា? ហើយបើសិនជាមាន មានវណ្ណភាពអ្វីខ្លះ?

**ឆ៖** បាទ ឥឡូវនេះ លោកកំពុងតែចូលនិយាយអំពីបញ្ហាសំខាន់មែនទែនហើយ។ ខ្ញុំមើលឃើញថា ពាក្យ "ពូជ" នៅទីនេះហ្នឹង ពូជៗសាសន៍។ ពូជសាសន៍ តាមទម្លាប់យើងប្រើនៅក្នុងការបកជាភាសាបារាំង ឬអង់គ្លេសហ្នឹង គេប្រើពាក្យ "ជាតិ" ស្រឡាញ់ជាតិ។ ក៏ប៉ុន្តែ "ជាតិ" នេះមានន័យពីរ។ មានន័យមួយថា ជាតិយើងហ្នឹង ជាតិជនជាតិហ្នឹង ប្រទេសជាតិ ប្រជាជាតិ។ ហើយមួយទៀតបកថាជនជាតិ ពូជសាសន៍។ អ្នកប្រវត្តិវិទូដែលចង់បង្ហាញថា ខ្មែរក្រហមប្រកាន់ពូជសាសន៍និយមនោះ ខ្ញុំមិនជឿទេ ដោយសារបកប្រែពាក្យថា "ជាតិ" នេះមក<ជា> "ពូជសាសន៍" <ជំនួសឲ្យការបកប្រែជា "ជាតិ">។

[០៩:៥៣:៥៤]

<ពួកគេជាអ្នកជាតិនិយម។ ពួកគេស្រឡាញ់ជាតិហួសហេតុ ហើយស្អប់ជនបរទេស។ យើងអាចយល់ស្របទាំងអស់គ្នាថា>អ៊ីចឹង <ប៉ុន្តែថាតើពួកគេជា>អ្នក<>រើសអើងពូជសាសន៍<ឬអត់នោះគឺជាប្រធានបទដែលត្រូវ>ពិភាក្សា<>។ ពាក្យវណ្ណៈអធនហ្នឹង មិនមានពាក្យទេ ជាភាសាខ្មែរ គឺមានពាក្យពីរ គេដាក់ "កម្មករ កសិករ"។ <វាគួរឲ្យចាប់អារម្មណ៍ ដែលពួកគេដាក់ពាក្យ>ថា<> "កម្មករ" មុនហើយ "កសិករ" ក្រោយ, កម្មករ កសិករ។ ឬក៏មានការបកប្រែជាភាសាបញ្ញវន្តមួយទៀត គេបកថា "វណ្ណៈអធន" ជាភាសាបាលី គឺ<បានន័យ>ថាមិនមានថ្នាក់ទេ មិនមានវណ្ណៈទេ ដោយសារក្រពេកទៅ អត់មានថ្នាក់ អត់មានវណ្ណៈ។ វណ្ណៈអធនហ្នឹង គឺមកពីបាលីទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<វាគួរឲ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់ថា គេ>មិនប្រើ<ពាក្យថា> "ជាតិ" <ទេ គឺ>គេមិនប្រើពាក្យ<ថា> "ពូជសាសន៍"។ អ៊ីចឹងយើងត្រូវមើលក្នុងវចនានុក្រមមើល តើមានន័យថាយ៉ាងម៉េចដែរ "ពូជសាសន៍"។ <ខ្ញុំគិតថា>ជាពាក្យបញ្ញវន្ត<> ចេញពីបាលី សំស្ក្រឹត ប្រហែលជាមនុស្សទូទៅមិនស្គាល់<ខ្លឹមសារ>ពាក្យនេះទេ។ មានពាក្យបញ្ញវន្តជាច្រើនដែលខ្មែរក្រហមប្រើ ឧទាហរណ៍ដូចជា "ចក្រពត្តិ" <ឬក៏ពាក្យថា "មូលនិធិនិយម">អីជាដើម ដែលពាក្យហ្នឹងមិនសូវ មនុស្សសាមញ្ញទូទៅមិនស្គាល់ទេ។ <នៅពេលបច្ចុប្បន្ននេះ បើ>សួរខ្មែរទូទៅថា "ចក្រពត្តិ" មានន័យម៉េចនោះមិនស្រួលមិនស្គាល់ផងទេ។

**ស៖** លោកបាននិយាយអំពីសញ្ញាណនៃពាក្យ "ប្រជាជាតិ" ហើយនិង "ពូជសាសន៍" <នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងន័យថា> "ជាតិខ្មែរ" ឬក៏ "ពូជខ្មែរ" "ពូជសាសន៍ខ្មែរ"?

[០៩:៥៦:០៣]

**ឆ៖** នេះសំណួរនេះពិបាកណាស់ ខ្ញុំមិនដឹងថាឆ្លើយយ៉ាងម៉េចដែរ។ ខ្ញុំគិតដែរថា<ពាក្យថា> "ជាតិ" នេះជាគេប្រើទូទៅហើយ គឺថា "<ជន>ជាតិ" <ដែលមានន័យថា ជនជាតិភាគតិច>។ <> ពាក្យ "ជាតិ" នេះ<ជាភាសាដែលគេប្រើ>រាល់ថ្ងៃទៅហើយ។

ខ្មែរក្រហមហ្នឹង<ជាអ្នកស្នេហាជាតិហួសហេតុ ហើយគេមានពាក្យនេះប្រើរួចហើយ>។ ក៏ប៉ុន្តែពាក្យ "ពូជសាសន៍" នេះខ្ញុំមិនដឹងថា ខ្មែរក្រហមប្រើពាក្យនេះញឹកញាប់ដែរឬក៏អត់ទេ "ពូជសាសន៍"។ ខ្ញុំគិតថា បើយកលួសួរ ខៀវ សំផន តែម្តងទៅ <ព្រោះថា>គាត់<គួរតែអាចឆ្លើយបានពាក់ព័ន្ធនឹងការប្រើពាក្យនេះជាភាសាខ្មែរ។ ខ្ញុំមិនអាចឆ្លើយបានទេ។>

**ស៖** ទាក់ទងទៅនឹងពាក្យ "ប្រជាជាតិ" ឬក៏"ពូជសាសន៍" នេះនៅរបបកម្ពុជាប្រជាធិបតេយ្យនោះ តើជនជាតិភាគតិចហ្នឹងមានសិទ្ធិនិយាយភាសា ក្រៅភាសារបស់ខ្លួនដែរឬទេ? ឬក៏ត្រូវតែនិយាយភាសាខ្មែរទាំងអស់គ្នាតែម្តង?

**ឆ៖** បាទ នេះជាសំណួរគួរឲ្យចាប់អារម្មណ៍។ ខ្ញុំសូមអរគុណ។ ប្រហែលខ្ញុំអាចឆ្លើយនឹងសំណួរនេះបាន ដោយសារខ្ញុំបានពិភាក្សាជាច្រើនជាមួយ ភី ភួន ហើយនិងដោយសារតែខ្ញុំបានទៅលេងនៅរតនគិរី ខ្ញុំទៅនោះតាំងពីឆ្នាំ៦៤នោះ លើកទី១ ទៅរតនគិរីនោះ។ អ៊ីចឹងខ្ញុំស្គាល់ប្រវត្តិនៃតំបន់ហ្នឹង។ បាទ ជាការពិតណាស់ដែលជនជាតិចារាយ ទំពួន ព្នង ទ្រឹង អីជាដើមនោះ...។ល។ សុទ្ធតែជាអ្នកដែលរបបខ្មែរក្រហមស្រឡាញ់ជាងគេ កូនសំណប់របស់ខ្មែរក្រហម។ <នៅពេលដែល ប៉ែន យៀរនិន

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

សរសេរថា ៤០ភាគរយនៃជនជាតិភាគតិចទាំងអស់ត្រូវបានគេសម្លាប់ចោលនោះ ខ្ញុំគិតថានេះជាការប៉ាន់ស្មាន ហើយមិនសមហេតុផល។> ខ្ញុំឃើញថា ប៉ែន យៀវនិន មិនដែលទៅមណ្ឌលគិរី រតនគិរីទេ <>។ អ្នកស្រាវជ្រាវច្បាស់លាស់ដូចជា សេរ៉ាខន អ៊ីហ្នឹង គាត់បានវាយតម្លៃទៅកម្រិតការកាប់សម្លាប់ទៅលើជនជាតិភាគតិចហ្នឹង គឺថាពី៥ទៅ ៧ភាគរយទេ បានន័យថា តិចជាងប្រជាជនខ្មែរទេ។ <ដូច្នេះបើយើងមានសមាជិក>ជនជាតិភាគតិចនោះ<មួយចំនួនត្រូវបានគេឃុំឃាំងនៅទួលស្លែង នៅ>ស-២១ <ខ្ញុំគិតថា ចំនួន>នោះគឺតិចបំផុត។ ដោយសារពួកគាត់ហ្នឹងជាកូនសំណប់របស់អង្គការ។ ហើយខ្មែរក្រហមនេះដាក់ឲ្យជនជាតិភាគតិចនោះ មានឋានៈខ្ពស់នៅសម័យនោះ។ <ហេតុអ្វីបានជាខ្មែរក្រហមធ្វើដូច្នោះ? វាពន្យល់ថា ហេតុអ្វីបានជាគេជម្លៀសមនុស្ស>ទៅចូលក្នុងព្រៃ។ <ពួកគេអាចដោះស្រាយអ្វីទាំងអស់គ្រប់ចំណុច។ ពួកគេឯករាជ្យ។ ពួកគេមិន>ចាយលុយកាក់អី<ជាដើម>។

[០៩:៥៨:៥០]

ហើយខ្ញុំ<បានដឹងតាមរយៈការ>ពិភាក្សាជាមួយ ភី ភួន នោះថា <សៀវភៅដំបូងរបស់> ប៉ុល ពត <គឺជាសៀវភៅតូចមួយអំពីជីវិតរស់នៅរបស់>ជនជាតិភាគតិចនៅរតនគិរី ហើយឯកសារនុ៎ងបាត់ទៅហើយ។ ហើយខ្មែរកណ្ដាលយើងដែលទៅរតនគិរីនេះ គឺគេបានឲ្យគាត់អានសៀវភៅ ប៉ុល ពត ដែលសរសេរពីរបៀបរស់នៅរបស់ជនជាតិភាគតិចនៅទីនោះ ដែលថាយកគំរូតាមពួកជនជាតិភាគតិចនោះទៅ។ អ៊ីចឹងត្រូវយល់ពីប្រវត្តិយើង ប្រវត្តិកុម្មុយនីស្តតាមលក្ខណៈបុរេប្រវត្តិ។ អ៊ីចឹងចេញពីសក្តិភូមិមូលធននិយមនោះ ទៅប្រកាន់យកកុម្មុយនីស្តលក្ខណៈបុរេប្រវត្តិ ឬក៏កុម្មុយនីស្តទំនើបជាដើម។

អ៊ីចឹងទាក់ទងនឹងការប្រើភាសានេះ ខ្ញុំឃើញថាមានភាពផ្ទុយគ្នា ព្រោះថា<មូលហេតុ>របស់ ប៉ុល ពត ហើយនិងគ្នាគាត់នោះ គឺសុទ្ធតែជាអ្នកពូកែប្រែ ពូកែកុហក <ព្រោះគេនិយាយពីបញ្ហាមួយហើយមានន័យមួយទៀត>។ អ៊ីចឹង<គេ>និយាយថា <ជីវិតរបស់នៅរបស់មនុស្សទាំងអស់នេះ គឺជាគំរូ ប៉ុន្តែក្នុងការអនុវត្តវិញ បើមិនមែនជាការប្រល័យពូជាសាសន៍ទេ យ៉ាងហោចណាស់ក៏ជាការបោសសម្អាតជនជាតិភាគតិចដែរ>។ អ៊ីចឹងគឺថា ក្រោមរបបខ្មែរក្រហមហ្នឹងគឺថា មានការសម្លាប់ មិនត្រឹមតែប្រជាជនទូទៅទេ គឺថាសម្លាប់ដល់ប្រពៃណីជនជាតិភាគតិចហ្នឹងទៀត គឺថាពួកគាត់ទាំងអស់ ត្រូវបង្ខំរស់នៅជាមួយប្រជាជនខ្មែរកណ្ដាលយើង ជាមួយឡាវ ជាមួយអី ទាំងអស់គ្នាហ្នឹង។ ហើយពួកគាត់ត្រូវបង្ខំរៀនភាសាខ្មែរ យើងកណ្ដាលហ្នឹង ដូចយើង ដូចស្គាល់ ទីវ អុល អ៊ីចឹងហើយ ថាគាត់ជាគ្រូខ្មែរ ហើយគាត់ហ្នឹងបង្រៀនភាសាខ្មែរ ទៅជនជាតិភាគតិចហ្នឹង ហើយ ភី ភួន កាលហ្នឹង អត់ចេះសរសេរ

ភាសាចារ៉ាយទេ។ ហើយគេមាន គេអក្ខរាវិរុទ្ធជាភាសាវៀតណាមក្នុងភាសាចារ៉ាយនេះ ក៏ប៉ុន្តែ ភី ភួននេះត្រូវមករៀនភាសាខ្មែរកណ្ដាលនេះ។ អ៊ីចឹងនៅតាមសហករណ៍នោះ ពួកជនជាតិភាគតិច មិនអាចប្រើភាសាជនជាតិភាគតិចរបស់ខ្លួនទេ។ ក៏ប៉ុន្តែនៅពេលដែលខ្ញុំអានកំណត់ត្រារបស់ខ្ញុំឡើងវិញហ្នឹង ខ្ញុំឃើញថានៅតាមភូមិមួយចំនួនហ្នឹង គេបានប្រមូលផ្ដុំចូលគ្នា<ឱ្យរស់នៅជាមួយខ្មែរកណ្ដាល ឬជនជាតិឡាវ ហើយគេអនុញ្ញាតឱ្យប្រើ>ភាសា<របស់ពួកគេផ្ទាល់>។ មានភូមិពីរបីដែរ ដែលថាជនជាតិភាគតិចហ្នឹងគាត់អាចនិយាយភាសាខ្លួនគាត់បានដែរ ក៏ប៉ុន្តែជាទូទៅ គឺខ្មែរក្រហមបានសម្លាប់ប្រពៃណីវប្បធម៌របស់ជនជាតិភាគតិចនេះហើយ។

[១០:០១:៣២]

**ស៖** ខ្ញុំមិនសំដៅលើតែជនជាតិភាគតិចនៅភូមិភាគឦសាននោះទេ ខ្ញុំសំដៅទៅដល់ចាម ហើយនិងវៀតណាមផងដែរ។ អ៊ីចឹងខ្ញុំសូមឱ្យលោកឆ្លើយខ្លី ថាតើចាមហើយនិងវៀតណាមនោះ ដែលរស់នៅប្រទេសកម្ពុជាកាលសម័យនោះៗ ដែលនៅប្រទេសខ្មែរទោះបីជាគេ ក្រោយពេលដែលគេជម្លៀសទៅហ្នឹង តើពួកគាត់ហ្នឹង ដូចជនជាតិភាគតិចផ្សេងដែរហ្នឹង គឺត្រូវតែប្រើភាសាខ្មែរ ហើយមិនអនុញ្ញាតឱ្យប្រើប្រាស់ភាសាកំណើតរបស់ខ្លួន ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំអត់មានប្រភពសំខាន់ទេ។ ខ្ញុំអត់បានចោទសំណួរបែបនេះទៅអ្នកដែលខ្ញុំសម្ភាសទេ ក៏ប៉ុន្តែក្រៅពីភាសាខ្មែរ គេមិនឱ្យនិយាយទេ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក្ដី វណ្ណៈបញ្ញាជនត្រូវបានសិក្សាជាភាសាបារាំង ហើយភាសាខ្មែរភាគច្រើនហ្នឹងនិយាយភាសាបារាំងយ៉ាងស្រួល គ្រួសារមួយចំនួនហ្នឹងនិយាយបារាំងនៅតាមផ្ទះខ្លួនឯងទៀតផង ឧទាហរណ៍ដូចជា ញ៉ឹក ជូឡុង អីជាដើមនេះ។ អ៊ីចឹងកាលណោះមានខ្មែរច្រើន បញ្ញវន្តខ្មែរច្រើនដែលចេះភាសាបារាំង ហើយពួកគាត់ទាំងអស់ហ្នឹង គាត់លាក់ភាសា អត់ហ៊ានប្រាប់ថាគាត់ចេះភាសាបារាំងទេ។ <ហើយ ពិន យ៉ាថៃ ពន្យល់ពីបញ្ហានេះដែរ ព្រោះវាមានន័យថាអ្នកនោះជានាយទុន។> អ៊ីចឹងតែកាលណាគេដឹងថាយើងជាគហបតី ជាអនុធនអីជាដើមនោះ គឺគេសម្លាប់ចោល។ អ៊ីចឹងគាត់មិនហ៊ាននិយាយភាសាបារាំងអីនោះទេ ក៏ប៉ុន្តែ ទាក់ទងភាសាចាម ហើយវៀតណាមនេះ ខ្ញុំមិនដឹងដែរព្រោះខ្ញុំអត់មានព័ត៌មាន។

**ស៖** ពាក្យស្លោកបន្ទាប់នោះ មានលេខ៨៩ ជាភាសាអង់គ្លេស, ជាភាសាបារាំង៧៧។ ពាក្យស្លោកនេះ គេនិយាយថា "អង្គការជាឪពុកម្ដាយ ជាម៉ែឪរបស់ក្មេងៗទាំងអស់ ជាកុមារទាំងអស់ និងក្មេងជំទង់ទាំងអស់"។ អ៊ីចឹងលោកអាចពន្យល់បានដែរឬទេ ថាពាក្យស្លោកនេះ វាធ្វើឱ្យសង្គមហ្នឹងយ៉ាង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ម៉េចដែរ សង្គមដែលថា អង្គការជាឪពុកម្ដាយ ជាម៉ែឪរបស់កុមារ ហើយនិងក្មេងជំទង់ទាំងអស់ហ្នឹង?

[១០:០៤:១៧]

**ឆ៖** អ្នកដឹកនាំខ្មែរក្រហមហ្នឹងដើមតាមលទ្ធិម៉ៅ គឺថា ដែលនិយាយថាក្មេងជាក្រដាសស ដែលលើក្រដាសហ្នឹងយើងសរសេរអីក៏បានដែរ។ អ្នកណាក៏ដឹងដែរថា កុមារត្រូវបានចាត់ទុកថា តាំងពីកើតមកហ្នឹង ថាមិនមែនជាកូនរបស់ឪពុកម្ដាយរបស់ខ្លួនទេ ជាកូនរបស់បដិវត្តន៍ របស់អង្គការបដិវត្តន៍។ ហើយចាប់ពីអាយុប្រាំ<មួយ>ប្រាំ<ពីរ>ឆ្នាំទៅ គេយកដាក់ទៅក្នុងមណ្ឌលកុមារហើយ ហើយគេដាក់បំបែកចេញពីឪពុកម្ដាយ ហើយទៅឲ្យយាយចាស់ៗមើល ហើយកូនង៉ាតូចៗនោះ ក៏គេបង្ខំឲ្យឪពុកម្ដាយទៅធ្វើការដែរ ហើយឲ្យយាយចាស់ៗមើលកូនង៉ែតទាំងអស់នោះ។ អ៊ីចឹងគេយកទៅដាក់ក្នុងមណ្ឌលកុមារ។ ហើយនៅពេលដែលឡើងដល់អាយុជំទង់ហើយ ឧទាហរណ៍ដូចជា<១១>, <១២>ឆ្នាំហ្នឹង គេបញ្ជូនទៅកងចល័តបាត់ទៅហើយ។ អ៊ីចឹងបានន័យថា ជាពិសេសទៅ ខ្មែរក្រហមមិនមែនបំបាត់គ្រួសារទេ គឺបំបែកគ្រួសារ គឺថាឪពុកម្ដាយហ្នឹង មិនឲ្យធ្វើការការដ្ឋានជាមួយគ្នាទេ បំបែកពីគ្នាទៀត។ អ៊ីចឹងអ្នកដឹកនាំខ្មែរក្រហមនោះ យល់ឃើញថា កុមារទាំងអស់ហ្នឹងជាទ្រព្យសម្បត្តិរបស់ខ្លួន អ៊ីចឹងអង្គការជាអ្នកអប់រំក្មេងៗទាំងអស់នោះ។

**ស៖** តើអង្គការដែលធ្លាប់ប្រើឲ្យកុមារៗទាំងអស់នុំងឃ្លាំ ឬក៏តាមដានឪពុកម្ដាយរបស់ខ្លួនទេ ព្រោះអង្គការចាត់ទុកថា កុមារៗទាំងអស់ហ្នឹង ជាកូនរបស់ខ្លួនទៅហើយនោះ?

[១០:០៦:១៧]

**ឆ៖** ខ្ញុំ<គិតថា គេ>មានពាក្យស្លោកមួយ <ដែលនិយាយអំពីរឿងនេះ> គេថា "បើចង់ដឹងអីសួរកុមារទៅដឹងហើយ"។ អ៊ីចឹងក្នុងន័យនេះគឺបានន័យថា កុមារនេះ គឺតាមដានឪពុកម្ដាយខ្លួនឯងហើយទៅរាយការណ៍។ <និយាយពីកុមារនេះ គឺ>នៅទំព័រ២៦៦ ជាភាសាបារាំង -- ជាភាសាអង់គ្លេស <> មានការដកស្រង់<មួយអំពីកុមារ ដែលសរសេរដោយ> លោក ខៀវ សំផន <ឬកុមាររបស់លោក> ខៀវ សំផន <ព្រោះពួកគេ>ហ្នឹង<ចិត្តល្អ ស្លូតបូត>ស្រួលប្រដៅ ហើយគោរពបដិវត្តន៍។

**ស៖** <ខ្ញុំនឹងត្រឡប់មកនិយាយអំពីសម្រង់នេះវិញនៅពេលបន្តិចទៀត>។ លោកប្រធាន មានពាក្យស្លោកលេខ៨០ ជាភាសាបារាំង ហើយនិង៩២ជាភាសាអង់គ្លេស ដែលលើកឡើងដូតតទៅនេះ "មិនបាច់គិតទេ ពីព្រោះថាអង្គការមានចេតនាល្អ"។ អ៊ីចឹងខ្ញុំសូមសួរលោក ថាតើទស្សនទាននៃសង្គមនេះ នៅពេលដែលបង្កើតពាក្យស្លោកយ៉ាងដូច្នេះថា ស្ដាប់តែអង្គការទៅ មិនបាច់ឆ្ងល់ទេ ពីព្រោះអង្គការ

ស្អាតស្អំ អង្គការមានចេតនាល្អទេ។ លោកអាចពន្យល់បានទេ?

**ឆ៖** បាទ នេះពាក្យស្លោកនេះ គឺវាឆ្លុះបញ្ចាំងអំពី គេហៅថាធ្វើយ៉ាងម៉េចធ្វើទៅ ឲ្យតែបានសម្រេចនៅពេលចុងក្រោយ។ អ៊ីចឹងថា ប្រើមធ្យោបាយអីប្រើទៅ ឲ្យតែបានទទួលជោគជ័យនៅពេលក្រោយ។ ពាក្យថា “បរិសុទ្ធ” នេះមានន័យយ៉ាងម៉េចភាសាខ្មែរ? បានន័យថា ស្អាតស្អំ ឬក៏នៅមានព្រហ្មចារីអីជាដើម ចំពោះស្ត្រី។ ក៏ប៉ុន្តែពាក្យដែលកើតចេញពីមាត់ខ្មែរក្រហមនេះ ពាក្យថា ស្អាតស្អំនេះ យើងឮគ្រប់កាលៈទេសៈនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ <គំនិតអំពីភាពបរិសុទ្ធនេះកើតឡើងជាថ្មីទៀតនៅក្នុងអក្សរសិល្ប៍បក្ស ដូច>នៅក្នុងសៀវភៅ<ដែលបកប្រែដោយ> ដេវីដ ឆេនដ្លឺរ <ហើយនេះជា>មនោគមន៍វិជ្ជា<បរិសុទ្ធ។ ហើយវាមាន>ន័យថា ត្រូវបោសសម្អាតខ្លាំងចេញពីសង្គមទាំងអស់។ <>អ្នកណាដែលមិនជឿជាក់<ពិតប្រាកដ --> ដូច ឌុច គាត់និយាយអ៊ីចឹង គាត់ធ្លាប់ប្រាប់ហ្នឹង គាត់ថាគាត់អ្នកជឿជាក់មិនងាករេទៅលើបក្ស គ្មាននរណាជឿជាក់ជាងគាត់ទេ។ អ៊ីចឹងអ្នកណាដែលមិនមានគោលជំហររឹងមាំ ជឿជាក់ <លើបដិវត្តន៍នេះ ត្រូវបានគេចាត់ទុកថាមិនបរិសុទ្ធ ហើយ>ត្រូវតែបោសសម្អាតចោល<ពីសង្គម។ នេះជាអ្វីដែលចាំបាច់ត្រូវធ្វើឲ្យបានសម្រេចទៅលើអ្នកទាំងអស់នោះ>។ អ៊ីចឹងពាក្យ “បរិសុទ្ធ” ហ្នឹងគឺថាជាពាក្យមួយដ៏សំខាន់ណាស់ ពាក្យគន្លឹះនៃរបបខ្មែរក្រហម។

[១០:០៩:២៥]

**ស៖** <លោកបានបញ្ចេញមតិមួយ>នៅក្នុងសៀវភៅរបស់លោក នៅជាភាសាបារាំង គឺទំព័រ 00395067, ជាភាសាអង់គ្លេស គឺ00394740។ <លោកបាននិយាយដូចតទៅ៖> “នៅក្រោមការគ្រប់គ្រងរបស់អង្គការ មិនត្រូវគិតវែងឆ្ងាយពេកទេ ត្រូវកុំឲ្យគិតទាល់តែសោះម្តងកាន់តែល្អ។ ប្រជាជនទាំងអស់ ត្រូវតែទុកចិត្តលើបក្សទាំងស្រុង។ ពាក្យគន្លឹះនៃពាក្យស្លោកហ្នឹងគឺពាក្យ “បរិសុទ្ធ”។ គំនិតនៃជនបដិវត្តន៍ហ្នឹងគឺពាក្យ “បរិសុទ្ធ” ហ្នឹងហើយ គឺបរិសុទ្ធភេទ ហើយនិងបរិសុទ្ធពូជសាសន៍ ហើយនិងបរិសុទ្ធផ្នែកមនោគមន៍វិជ្ជា។ យើងត្រូវតែចងចាំថាអ្វីដែល ខៀវ សំផន <ប្រមុខរដ្ឋនៃរបបនោះ>ចង់ធ្វើជាងគេបំផុតនោះគឺថា ត្រូវតែសម្អាតសង្គមខ្មែរឲ្យស្អាត។ <វាជាចំណង់មួយ ដែលបានក្លាយជាចំណង់របស់មេដឹកនាំទាំងអស់>ហើយ<វាបានក្លាយទៅជាអ្វីដែល>យើង<ហៅថាជាសហករណ៍ត្រូដេវរិច” >។ អ៊ីចឹងសូមឲ្យលោកពន្យល់ថា មូលហេតុអីបានជា ខៀវ សំផន គាត់ចេះតែមានគំនិតមួយរក់រីនៅហ្នឹង គិតថាធ្វើយ៉ាងម៉េចបោសសម្អាតសង្គមខ្មែរហ្នឹងឲ្យស្អាតហ្នឹង? តើ<រោគគិតមមៃចង់បោសសម្អាតសង្គមខ្មែរនេះចេញមកពីណា តើលោកមានប្រភពអ្វីដើម្បីបញ្ជាក់បញ្ហា>នេះ?

**ឆ៖** ខ្ញុំបោះពុម្ពសៀវភៅនេះនៅឆ្នាំ១៩៩៦ រហូតដល់ពេលនេះហ្នឹង ខ្ញុំប្រកាន់យកនូវអ្វីដែលខ្ញុំបានសរសេរ<នៅពេលនោះ>។ ខ្ញុំសោកស្ដាយណាស់ដែលខ្ញុំបានសរសេរពាក្យថា“ស្អាតស្អំពូជសាសន៍”នេះ។ <ខ្ញុំសូមនិយាយពីរឿងនោះបន្តិច។> ខ្ញុំអត់<>សរសេរ<បែប>ហ្នឹងទេ<នៅ>ថ្ងៃនេះ។ ខ្ញុំមិនគិតថា <វាជាកង្វល់ជាក់លាក់របស់>អ្នកបដិវត្តន៍ខ្មែរក្រហម <>ឬក៏អ្នកបដិវត្តន៍នៅអាស៊ីខាងបូព៌ាយើងនេះទេ។ ក៏ប៉ុន្តែពាក្យដែល “សម្អាតសង្គម” ដែលចេញពីមាត់របស់លោក ខៀវ សំផន នេះគឺថានៅក្នុងទសវត្សរ៍ទី៦០ ខ្ញុំជាគ្រូបង្រៀននៅសាលាបារាំងលីសេដេកាត ខ្ញុំមានមិត្តភក្តិម្នាក់ដែលមកពីបង្រៀននៅវិទ្យាល័យហ្នឹងដែរ មកពី ប៉ុនឌីឆេរី គាត់ឈ្មោះ ហ្សាគ្លីន ហ្វីលីច។ គាត់កាលនោះគាត់ជាគ្រូបង្រៀន<>។ គាត់បានសិក្សាសាលាច្បាប់ឆ្នាំ ទី១ នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ហើយកាលនោះគ្រូបង្រៀនគាត់គឺ ខៀវ សំផន។ ខៀវ សំផន គាត់និយាយថា គាត់នេះជាជនជាតិឥណ្ឌាមកពី ប៉ុនឌីឆេរី គាត់ស្អាត ហើយសម្បុរស្រអែម គាត់ស្លៀកពាក់បែបឥណ្ឌា។ ហើយកាលនោះខៀវ សំផន និយាយទៅកាន់មិត្តភក្តិខ្ញុំនោះ ជនជាតិឥណ្ឌាមកពី ប៉ុនឌីឆេរី ហ្នឹង គាត់និយាយថា ហើយអ្នកមកទីនេះធ្វើអី អ្នកឯជនជាតិបារាំងហ្នឹង ព្រោះអង្កាល់នោះនៅប៉ុនឌីឆេរី គេមានរដ្ឋបាលបារាំង អ៊ីចឹងមានសញ្ជាតិបារាំង។ លោក ខៀវ សំផន គាត់សួរថាម៉េចបានមករៀននៅឧត្តមវិទ្យាល័យនៅប្រទេសខ្មែរ ម៉េចមិនទៅរៀននៅប្រទេស<បារាំង>? កាលនោះ ខៀវ សំផន គាត់បង្រៀន នៅពេលដែលកំពុងបង្រៀនហ្នឹង គាត់និយាយអំពីអំពើពុករលួយនៃរបប<សីហនុ> ហើយ ខៀវ សំផន កាលនោះគាត់ក្លាហានណាស់។ គាត់កាន់កាសែតមួយឈ្មោះ ឡូបស៊ែវ៉ាទ័រ គាត់មិនអាចឃាត់ខ្លួនឯងបាន មិនអាចទប់ខ្លួនមិនរិះគន់របប សីហនុ បានទេ។ <នេះជាការដែលនាំឲ្យការបោះពុម្ពផ្សាយត្រូវបានហាមឃាត់។> ក៏ប៉ុន្តែគាត់និយាយកាលនោះ គាត់និយាយថា សង្គមរបបសង្គមនិយមនេះត្រូវតែបោសសម្អាតឲ្យស្អាត ត្រូវលាងឲ្យស្អាត ព្រោះសង្គមនេះសង្គមពុក រលួយ។ អ៊ីចឹងខ្ញុំសូមឲ្យលោក ខៀវ សំផន បើគាត់ចង់ឆ្លើយតបក៏ឆ្លើយតប បើសិនជាអ្នកដែលនិយាយប្រាប់ខ្ញុំនោះគាត់កុហក ព្រោះថាខ្ញុំបានព័ត៌មាននេះវាមិនមែនផ្ទាល់ទេ គឺដោយសារមិត្តភក្តិខ្ញុំហ្នឹងគាត់ប្រាប់ខ្ញុំអ៊ីចឹង ប្រភពទី២ទៅហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់និងសាមសិបប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់អ្នក

ជំនាញរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់ និងសាមសិបប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤នាទី ដល់ម៉ោង ១០:៣៤នាទី)*

[១០:៣៤:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយផ្តល់វេទិការជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

**សួរដោយលោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** សូមអរគុណលោកប្រធាន។ ខ្ញុំនៅមានពាក្យស្លោកមួយចំនួនទៀត ដែលឲ្យលោកអ្នកជំនាញបញ្ជាក់ពីអត្ថន័យមុនចូលទៅប្រធានបទផ្សេង។ ពាក្យស្លោកបន្តទៅនេះគឺលេខ១៤៨ ជាភាសាបារាំង និងលេខ១៦៩ ជាភាសាអង់គ្លេស។ ពាក្យស្លោកនេះនិយាយថា "ដៃម្ខាងបង្កបង្កើនផល ដៃម្ខាងវាយខ្មាំង"។ តើពាក្យស្លោកនេះអនុវត្តចំពោះខ្មាំងគ្រប់ប្រភេទមែនទេ ទាំងខ្មាំងខាងក្រៅ និងខ្មាំងស៊ីរូងផ្ទៃក្នុងនោះ?

[១០:៣៥:៥៣]

**លោក ហង់រី ឡូកា៖**

**ឆ៖** សូមអរគុណលោកតំណាងសហព្រះរាជអាជ្ញាដែលបានសួរសំណួរនេះមកកាន់ខ្ញុំ។ ខ្ញុំមិនដែលបានសួរសំណួរនេះមកកាន់ខ្លួនឯងទេ ពីព្រោះថាខ្ញុំគិតថា<វាសំដៅទៅលើ>ខ្មាំងផ្ទៃក្នុង។ ជាទូទៅគឺសំដៅទៅលើប្រជាជនទាំងមូល ហើយនិងកងទ័ព។ វាបង្ហាញអំពីគោលនយោបាយពីររបស់កម្ពុជាប្រជាធិបតេយ្យ គឺបង្កើនការបង្កបង្កើនផលឲ្យបានមួយហិកតាបីតោន និងកង្វល់មួយទៀត គឺការវែកមុខរកខ្មាំង។ អ៊ីចឹងហើយបានជាមានការចាប់ខ្លួនទាហាន និងសម្លាប់ចោល។ ហើយមានការរាយការណ៍ទៅឲ្យអង្គការហ្នឹងថាមានខ្មាំង មានជនក្បត់នៅក្នុងចំណោមប្រជាជន។

**ស៖** ពាក្យស្លោកបន្តទៅទៀតគឺលេខរៀងទី១៥៩ជាភាសាបារាំង និង១៩៧ជាភាសាអង់គ្លេស។ <ពាក្យស្លោកនិយាយដូចតទៅ៖> “ត្រូវកម្ទេចឲ្យអស់អាខ្មាំងយួនលេបទឹកដី”។ នៅក្នុងបរិបទឆ្នាំ៧៧ និងឆ្នាំ៧៨ តើពាក្យស្លោកនេះត្រូវបានអនុវត្តចំពោះវៀតណាមទាំងអស់មែនទេ ទាំងអ្នកវៀតណាមដែលរស់នៅកម្ពុជា ទាំងជនជាតិវៀតណាមនៅប្រទេសវៀតណាម ទោះជាវៀតណាមនៅក្នុងព្រំដែន ឬក៏វៀតណាមដែលធ្វើដំណើរតាមដែនសមុទ្រកម្ពុជា? តើគេសំដៅលើវៀតណាមទាំងមូលទាំងអស់គ្រប់ប្រភេទតែម្តង ឬក៏គេសំដៅទៅលើប្រភេទជនជាតិវៀតណាមណាមួយជាក់លាក់?

[១០:៣៨:១៧]

**ឆ៖** វាជាប្រភេទខ្មាំងដែលអាចកំណត់អត្តសញ្ញាណបានយ៉ាងច្បាស់។ ក្នុងនេះខ្មាំងយួនលេបទឹកដីនេះ គឺជាវៀតណាមនៅប្រទេសវៀតណាមហើយ។ ជាទូទៅក្នុងអំឡុងរបបនោះទាំងមូល តាំងពីថ្ងៃទី១៧ មេសា ៧៥មក មានការវាយប្រយុទ្ធគ្នានៅតាមព្រំដែន ហើយគេតែងតែនិយាយថាខ្មែរក្រហមវាយវៀតណាម ហើយនិងកម្ទេចភូមិនៅវៀតណាម ជាពិសេសនៅពេលដែលខ្ញុំសម្ភាសមនុស្សមួយចំនួននៅខេត្តរតនគិរី ហើយនៅពេលដែលយើងអានឯកសារខ្មែរក្រហមមួយចំនួននោះ យើងឃើញហើយថា<មានជនជាតិ>វៀតណាម<ដែលបានចាកចេញពី>កម្ពុជា ឬក៏វៀតណាមខ្លះមិនព្រមចេញពីកម្ពុជា។ <ដូច្នេះទាំងសងខាងមានបញ្ហា>នៅតាមព្រំដែន <ទាក់ទងទៅនឹងការវាយប្រហារគ្នាទាំងសងខាង>។ ដូច្នេះពាក្យស្លោកនេះគឺសំដៅលើយុទ្ធជនវៀតណាមនៅប្រទេសវៀតណាម។ ហើយពាក្យថា “លេបទឹកដី” នេះយើងដឹងហើយថាពាក្យនេះមានរាប់សតវត្សរ៍មកហើយ។ ដូចដែលខ្ញុំបានបញ្ជាក់រួចមកហើយ ជនភាគតិចនៅ<ជួរភ្នំអណ្ណាម>ហ្នឹង <គឺនៅវៀតណាមកណ្តាល> ក៏ចោទជនជាតិវៀតណាម<>ថា<>លេបទឹកដីដែរ ដូចជានៅដាឡាត់នៅអីជាដើមនោះ។ ដូច្នេះនេះគឺជាចក្រពត្តិនិយមរបស់វៀតណាម។ នេះមិនសំដៅទៅលើវៀតណាមនៅក្នុងទឹកដីកម្ពុជាទេ ព្រោះថាមិនមានច្រើនទេពេលនុ៎ង គឺគេដេញចេញអស់ហើយ នៅសល់តែអ្នកដែលមានប្តី ឬក៏ប្រពន្ធខ្មែរមួយចំនួនតូចតែប៉ុណ្ណោះ ពួកហ្នឹងមិន<ត្រូវបានគេចោទប្រកាន់ថា>លេបទឹកដី<>កម្ពុជា<>ទេ។

[១០:៤០:១៣]

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីបញ្ហាជនជាតិវៀតណាម នៅកម្ពុជាប្រទេសកម្ពុជានៅពេលបន្តិចទៀតនេះ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីពាក្យស្លោកមួយទៀតដែលសំដៅទៅលើជនជាតិខ្មែរ គឺលេខរៀងទី១៦៣ ជាភាសាបារាំង និង២០២ ជាភាសាអង់គ្លេស គឺ “ក្បាលយួន ខ្លួនខ្មែរ”។ តើគេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រើពាក្យស្លោកនេះ នៅក្នុងបរិបទជាក់លាក់ណា ហើយគេសំដៅទៅលើអ្នកណា ដែលជាជនជាតិខ្មែរ ហ្នឹង ប្រភេទជនជាតិខ្មែរណា ដែលគេហៅថាជា “ក្បាលយួន ខ្លួនខ្មែរ” នោះ?

ឆ៖ ពាក្យស្លោកនេះ ក្លាយជាល្បីល្បាញនៅពេលដែលមានការវាយប្រយុទ្ធបង្ហូរឈាមគ្នារវាង <ឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ ពាក់ព័ន្ធនឹងការវាយប្រហារដោយ>ទ័ពពិសេស ដែលបង្កើតឡើងនៅព្រំដែនវៀតណាម ដោយអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ នៅចំពោះមុខការគំរាមកំហែងពីវៀតណាម ដែលចង់គ្រប់គ្រងបដិវត្តន៍កម្ពុជា។ មានតិចនិច មានយុទ្ធវិធីពីរ គឺការទូត និងការ<ពិភាក្សា ហើយក៏មានការ> វាយប្រហារ <និងការធ្វើភេរវកម្ម។ វិធីសាស្ត្ររឹងមាំ។ ចំពោះកម្ពុជា គឺគេបានប្រើវិធីសាស្ត្ររឹងមាំ>។ ដូច្នេះ ថ្នាក់ដឹកនាំកម្ពុជាសម្រេចបង្កើតកងទ័ពពិសេស<នៅតាមព្រំដែន ដែលអាចធ្វើការឈ្លានពានប្រហែល១០គីឡូម៉ែត្រចូលទៅក្នុងប្រទេស> ដើម្បីសម្លាប់ជនជាតិវៀតណាមដែល<នៅតាមផ្លូវរបស់ពួកគេ>។ បន្ទាប់មកទៀត វៀតណាមមិនអាចផ្លាស់ប្តូរថ្នាក់ដឹកនាំកម្ពុជា ដូច្នេះនៅឆ្នាំ៧៧ ពួកគេប្តូរយុទ្ធវិធី គឺវាយលុកឈ្លានពានជាទ្រង់ទ្រាយធំតែម្តង ចូលមកដល់ស្វាយរៀង ព្រៃវែង។ ពួកគេបានលុកលុយចូលកម្ពុជារហូតទៅដល់ខេត្តមណ្ឌលគិរី គឺទៅដល់ស្រុកកោះញែក គឺមានចម្ងាយប្រហែលជា៥០គីឡូម៉ែត្រពីព្រំដែន។ ដូច្នេះនេះជាការវាយលុកទ្រង់ទ្រាយធំរបស់<វៀតណាម> ដើម្បីផ្តល់មេរៀនមកឱ្យថ្នាក់ដឹកនាំកម្ពុជា ដោយបញ្ជាក់ថា ឈប់ចូលមកវៀតណាម យើងខ្លាំងជាងពួកឯង។ ហើយ<ពួកគេបានដកទៅវិញ>នៅដើមខែមករា ឆ្នាំ៧៨។ <នៅពេលនោះ> ប៉ុល ពត ហើយនិងថ្នាក់ដឹកនាំខ្មែរក្រហម ប្រកាសអំពីមហាជ័យជម្នះ។ ដូច្នេះថ្ងៃទី០៦ មករា ហ្នឹងគឺជាមហាជ័យជម្នះរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យទៅលើកងទ័ពវៀតណាម។ ក៏ប៉ុន្តែតាមពិតទៅ មិនមែនជាការវ៉ៃឈ្នះកងទ័ពវៀតណាមទេ គឺពួកវៀតណាមដកទ័ពទៅវិញទេ ព្រោះថា គេផ្តល់មេរៀនឱ្យខ្មែរហើយ គេដកខ្លួន ដកទ័ពទៅវិញ។ ហើយនៅពេលដែល<ទ័ព>ខាងបូព៌ា នៅពេលនោះគឺថាមានការដឹកនាំដោយ សុន សេន បានឱ្យវៀតណាមចូលមកដល់ក្នុងកម្ពុជា ក្នុងជម្រៅឆ្ងាយ ឧទាហរណ៍ដូចជានៅខេត្តតាកែវ <មានចម្ងាយតែ៥០គីឡូម៉ែត្រពី>ព្រំដែន គឺកងទ័ពវៀតណាមចូលមក<សឹងតែពាក់កណ្តាលទៅហើយ ហើយចូលមកយ៉ាងជ្រៅក្នុងកម្ពុជាប្រជាធិបតេយ្យ>។ ដូច្នេះគេចាត់ទុកថា កងទ័ពដែលឈរជើងនៅខាង<បូព៌ា>ហ្នឹងជាខ្មាំង ជាជនក្បត់ ដោយសារតែបណ្តោយឱ្យវៀតណាមវ៉ៃចូលមកបានឆ្ងាយ។ អ៊ីចឹងហើយបានជាគេបង្កើតពាក្យស្លោកហ្នឹងមកនេះ “ក្បាលយួន ខ្លួនខ្មែរ” ហ្នឹង គឺគេសំដៅទៅលើជនជាតិខ្មែរតែម្តង ពាក្យស្លោកហ្នឹង។

[១០:៤៤:១៦]

ពាក្យស្លោកហ្នឹង ដូចជាប្រឆាំងវៀតណាមដែរ។ អ៊ីចឹងហើយបានជាគេសម្លាប់ជនជាតិវៀត-ណាមជាច្រើន។ ហើយខ្ញុំបានពិនិត្យផ្ទៀងផ្ទាត់ក្នុងកំណត់ត្រារបស់ខ្ញុំដែរ ផ្ទុយពីការបោសសម្អាតពីមុនដែល<ពាក់ព័ន្ធខ្លាំងនឹង>មន្ទីរឃុំឃាំង <ក្នុងករណីនេះ យើងកំពុងតែនិយាយអំពីការ>សម្លាប់ចោលតែម្តង គឺការសម្លាប់រង្គាលតែម្តង ដូចជាការសម្លាប់ សោ ភឹម ជាដើម ដែលគេដឹងគ្រប់គ្នាហើយ។ <ដូច្នេះនេះគឺយើងកំពុងតែនិយាយអំពីការ>សម្លាប់<ជនស៊ីវិលក្នុងទ្រង់ទ្រាយធំ ជាមួយនឹង>កម្មាភិបាលភូមិភាគបូព៌ា ទាហាននៅភូមិភាគបូព៌ាជាដើម។ <ហើយយើងដឹងថា ពួកគេខ្លះ>ត្រូវបានគេចាប់យកមក ស-២១ ហើយគេសម្លាប់ចោលភ្លាមៗតែម្តង។ ហើយចំពោះប្រជាជនស៊ីវិលដែលនៅតាមព្រំដែននោះត្រូវបានជម្លៀសទៅខេត្តពោធិ៍សាត់ បាត់ដំបង ដូចដែលលោកដឹងហើយ។ ដូច្នេះនៅពីក្រោយពាក្យស្លោកហ្នឹង គឺមានការសម្លាប់បង្ហូរឈាម។

**ស៖** ខ្ញុំមានសំណួរបន្តទៅទៀតពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានលើកឡើងនេះ គឺកងទ័ពវៀត-ណាមបានលុកលុយចូលមកក្នុងទឹកដីកម្ពុជា ក្នុងចម្ងាយឆ្ងាយ ហើយកងទ័ពបូព៌ាហ្នឹង គឺដឹកនាំដោយ សុន សេន លោកបាននិយាយហើយ។ កងកម្លាំង<មួយចំនួន>មកដល់តាកែវ។ អ៊ីចឹងហេតុអីបានជា សុន សេន និង តាម៉ុក មិនព្រួយបារម្ភអំពី<ពាក្យស្លោកនេះ? ហេតុអ្វីបានជា>មិនអនុវត្តពាក្យស្លោកហ្នឹង<ទៅលើពួកគេ គឺពាក្យថា "ក្បាលយួន ខ្លួនខ្មែរនោះ">?

**ឆ៖** *(គ្មានការបកប្រែ)*

**ស៖** សូមលោកឆ្លើយម្តងទៀត ព្រោះអីមិញនេះ មីក្រូមិនទាន់ភ្លឺ។

[១០:៤៦:០២]

**ឆ៖** សុន សេន គាត់ជាអ្នកទទួលខុសត្រូវលើកងទ័ពទាំងមូល។ តាម៉ុក គាត់ទទួលខុសត្រូវតែនៅនិរតីទេ <មិនមែនកងទ័ពទាំងមូលទេ>។ គឺ សោ ភឹម ដែលជាអ្នកទទួលខុសត្រូវភូមិភាគបូព៌ា ហើយគេចោទ សោ ភឹម ហ្នឹងថា "ក្បាលយួន ខ្លួនខ្មែរ"។ អ៊ីចឹងតើគាត់ធ្វើអត្តឃាត ឬក៏គាត់ត្រូវបានគេសម្លាប់នោះ។ <មានការបកស្រាយពីរបែបពីអ្វីដែលបានកើតឡើងនោះ។> គឺយើងមិនច្បាស់ទេ <ប៉ុន្តែក្នុងករណីណាក៏ដោយ គាត់ចង់តវ៉ាពីរឿងនោះ>។ គាត់នៅអរិយក្សត្រនៅត្រើយម្ខាងទន្លេមេគង្គ គាត់ចង់និយាយជាមួយ ប៉ុល ពត។ ជាពិសេសគាត់ចង់និយាយថា គាត់បានធ្វើអ្វីគ្រប់បែបយ៉ាង ពលិកម្មគ្រប់យ៉ាងដើម្បីប្រយុទ្ធជាមួយកងទ័ពវៀតណាម។ <ខ្ញុំគិតអ៊ីចឹង។ ហើយនៅ>ពេល<នោះ មានការ

គិតថា កងកម្លាំងក្បត់ គឺកងកម្លាំងតាម៉ុក ឬកងកម្លាំងនិរតី ហើយ>មានការវាយប្រយុទ្ធគ្នា រវាងកងទ័ពនិរតី និងកងទ័ពបូព៌ា។ <ជាការពិតទៅ ការប្រយុទ្ធគ្នានោះមិនបានកើតឡើងទេ ព្រោះថាខាង>បូព៌ា <ត្រូវបានគេ>ចាប់<>សម្លាប់<ចោល>។ អ៊ីចឹងហើយគឺនៅពេលនុ៎ង នៅពេលដែលគេចាប់ សោ ភឹម ហើយគឺមានការសម្លាប់មនុស្សច្រើន។ យើងដឹងហើយថា សោ ភឹម ជាមនុស្សស្និទ្ធនឹង ប៉ុល ពត។ គាត់ជាអតីតខ្មែរវៀតមិញ។ សាឡុត បាន ឬ សូរ ហុង <ដែលជាក្មួយប្រុសរបស់ប៉ុល ពត> បាននិយាយហើយថា សោ ភឹម ក៏ដូចជា វស់ ញឹម គឺជាជាង<ឈើ> ហើយពួកគាត់ធ្វើផ្ទះឱ្យ ប៉ុល ពត កាលពីពេលមុនហ្នឹង អ៊ីចឹង ហើយបានជាអ្នកទាំងហ្នឹងស្និទ្ធនឹង ប៉ុល ពត នោះ។

**ស៖** ខ្ញុំនឹងត្រឡប់មកចំណុចនេះ នៅពេលក្រោយ។ អ៊ីចឹងខ្ញុំចង់សួរថា តើ សោ ភឹម នៅតែស្មោះត្រង់នឹង ប៉ុល ពត, នួន ជា រហូតដល់ខ្លួនអស់ជីវិត មែនទេ?

**ឆ៖** យើងត្រូវអានចម្លើយសារភាពរបស់គាត់។ ចម្លើយសារភាពគាត់ ខ្ញុំមិនបានអានទេ។ ខ្ញុំគិតថា ដូច វន វ៉េត ដូចជាអ្នកផ្សេងដែរ មេដឹកនាំជាន់ខ្ពស់ ដូចជា កុយ ធួន ជាដើម ពួកគាត់មិនបានប្រឆាំងនឹងរបបខ្មែរក្រហមទេ ពួកគាត់ជាអ្នកស្មោះត្រង់នឹង ប៉ុល ពត ណាស់។ យើងត្រូវតែដឹងថា នៅក្នុងជួរថ្នាក់ដឹកនាំនោះ ដូចជា ឌុច បានពន្យល់ហើយថា មានបញ្ញាជន និងមានមេភូមិភាគ។ អ៊ីចឹងយើងត្រូវយល់ថា ប្រធានភូមិភាគទាំងអស់ត្រូវបានគេបោសសម្អាតចោល លើកលែងតែ តាម៉ុក មួយដែលគាត់ មិនត្រូវបានបោសសម្អាត។

[១០:៤៨:៥៨]

**ស៖** ដើម្បីបញ្ចប់ពាក់ព័ន្ធទៅនឹងពាក្យស្លោកនេះ ខ្ញុំនឹងអានពាក្យស្លោកមួយចំនួន ពាក់ព័ន្ធទៅនឹងពុទ្ធសាសនិក គឺពាក្យស្លោកលេខរៀង១៧៥, ១៧៦ និង ១៧៨ ជាភាសាបារាំង, ជាភាសាអង់គ្លេស លេខរៀងទី១៨៥, ១៨៦ និង ១៨៨ គឺនៅក្នុងសៀវភៅរបស់លោកដដែល កូនសៀវភៅខ្មែរក្រហម។ ខ្ញុំនឹងអានរួមសរុប បីតែម្តង។ ពាក្យស្លោកទី១ ថា “លោកសង្ឃជាបញ្ញើក្អែក”។ ទី២ “លោកសង្ឃជាព្រូនសង្គម” និងពាក្យស្លោកទី៣ “ថ្វាយបង្គំព្រះដូចថ្វាយបង្គំស៊ីម៉ង់ត៍”។ លោកអាចពន្យល់បានទេ ថាហេតុអ្វីបានជាលោកសង្ឃត្រូវបានគេចាត់ទុកថាជាបញ្ញើក្អែក និងជាព្រូនស៊ីរូងក្នុងសង្គម?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយដោយខ្លី។ <ខ្មែរក្រហមមិនបានកែប្រែអ្វីទាំងអស់។> នេះមិនមែនជាលក្ខណៈពិសេសនៃបដិវត្តន៍របស់កម្ពុជាប្រជាធិបតេយ្យទេ។ <នេះគឺមកពីម៉ាក្ស ដូច្នេះហើយ-->

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<សូមចាំបន្តិច។>

**ប្រធានអង្គជំនុំ៖**

មានបញ្ហាការបកប្រែភាសាទៀតហើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកព្រះរាជអាជ្ញា សូមលោកសួរសំណួរឡើងវិញម្តងទៀត។

[១០:៥០:៣៨]

**សួរដោយលោក វ៉ាំងសង់ វ៉ាយ៍ ដេស្វាងល៖**

**ស៖** បាទ លោកស្រីចៅក្រម។ លោកស្រីស្តាប់ឮហើយឬនៅ? លោកអ្នកជំនាញ លោកអាចពន្យល់បានទេថា ហេតុអ្វីបានជាព្រះសង្ឃត្រូវបានគេចាត់ទុកជាបញ្ញើក្អែក និងជាពួនសង្គម? សូមលោកឆ្លើយខ្លីៗទៅបានហើយ។

**លោក ហង់រី ឡូកា៖**

**ឆ៖** នេះមិនមែនជាលក្ខណៈពិសេសនៃបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យទេ។ វាជាលទ្ធិមួយពាក់-ព័ន្ធទៅនឹងជំនឿនៃលទ្ធិម៉ាក្ស-ឡេនីន គឺម៉ាក្ស-ឡេនីន នេះហើយជាអ្នកប្រកាសថា សាសនាហ្នឹងវាជាអ្នកបំផ្លាញប្រជាជននោះ។ ដូច្នេះនៅក្នុងវោហារសាស្ត្រកម្ពុជាពាក់ព័ន្ធទៅនឹងលទ្ធិ ម៉ាក្ស-ឡេនីន នេះវាបង្ហាញបែបហ្នឹងគឺថា យើងថ្វាយបង្គំហ្នឹងដូចជាថ្វាយបង្គំស៊ីម៉ង់ត៍។ ខ្ញុំបានពន្យល់រួមមកហើយ នៅក្នុងកំណត់ត្រារបស់ខ្ញុំពាក់ព័ន្ធទៅនឹងពាក្យស្លោកនេះ។ យើងឃើញហើយថា នៅក្នុងសម័យសង្គមរាស្ត្រនិយមមានការសាងសង់វត្តជាច្រើន។ ហើយនៅក្នុងសម័យខ្មែរក្រហម -- សុំទោស នៅសម័យសង្គមរាស្ត្រនិយមហ្នឹងគឺ គេបានកម្ទេចវត្តចាស់ៗ<>ធ្វើ<ពីឈើ>ដែលមានគូររូប គូរអីស្អាតណាស់ <ដែលនៅសល់ពីសតវត្សរ៍ទី១៩ និងទី២០មក ហើយសង់វត្តថ្មីអំ>ពីស៊ីម៉ង់ត៍ <ហើយគេធ្វើ>ព្រះជារូបស៊ីម៉ង់ត៍។ <គេលែងធ្វើរូបព្រះអំពីឈើ ទង់ដែង សម្ភារៈថ្លៃៗ ឬថ្មទៀតហើយ ប៉ុន្តែគេសាងសង់រូបព្រះសឹងតែទាំងអស់អំពីស៊ីម៉ង់ត៍។> អ៊ីចឹងហើយបានជានៅក្នុងសម័យខ្មែរក្រហមហ្នឹងគេថា ថ្វាយបង្គំព្រះហ្នឹងដូចជាថ្វាយបង្គំស៊ីម៉ង់ត៍។

[១០:៥២:១៩]

**ស៖** ឥឡូវខ្ញុំចូលទៅនិយាយអំពីពាក្យស្លោកពាក់ព័ន្ធទៅនឹងអ្នកឈឺ គឺអ្នកធ្វើពុតជាឈឺជាដើម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដូចជានៅលេខរៀងទី១៩០, ១៩១ ហើយនិង១៩៧ ជាភាសាបារាំង និងភាសាអង់គ្លេស លេខរៀងទី ២១៦, ២១៧ និង២២៣។ ខ្ញុំសូមអានពាក្យស្លោកទាំងបីនេះរួមគ្នាតែម្តង "ឈឺសតិអារម្មណ៍"។ ពាក្យស្លោកទី២ "ត្រូវបំបាត់ឲ្យអស់ជំងឺសតិអារម្មណ៍<ហើយបោះចេញពី>សង្គម"។ ពាក្យស្លោកទី៣ "អ្នកមានជំងឺមិនបាច់ស៊ីទេ ពីព្រោះជំងឺវាធ្វើឲ្យបាត់ការស្រេកឃ្លាន ឯការអត់អាហារបណ្តាលឲ្យជាសះស្បើយ។" សូមបញ្ចប់ការដកស្រង់។ តើការសង្ស័យថា មានការពុត ធ្វើពុតជាឈឺពីសំណាក់<អ្នក>ធ្វើការហ្នឹង កើតចេញមកពីណា <ក្នុងចំណោម>អ្នកធ្វើការនៅតាមសហករណ៍ ឬក៏នៅតាមការដ្ឋានធំៗនោះ?

**ឆ៖** ចម្លើយខ្ញុំដូចជាផ្ទុយទៅនឹងចម្លើយមុនបន្តិច <គោលជំហរប្រឆាំងសាសនា គឺជាមូលដ្ឋានរបស់ពួកកុម្មុយនីស្ត>។ <ទោះជាយ៉ាងណា ការវាយប្រហារទៅលើអ្នកជំងឺ គឺច្បាស់លាស់ណាស់នៅក្នុង>បដិវត្តន៍ខ្មែរក្រហម<>។ <ខ្ញុំមិនដឹងថាតើ>របបកុម្មុយនីស្ត<>ផ្សេងទៀតនោះ <អ្នកជំងឺត្រូវគេកំណត់គោលដៅដែរឬយ៉ាងណា។ អំពើនេះសាហាវណាស់>។ ពាក្យស្លោកហ្នឹងគឺមានន័យមិនច្បាស់ទេ យើងអាចមានន័យពីរ ឈឺសតិអារម្មណ៍នេះ។ ដូចដែលខ្ញុំបានសរសេរហើយគឺថា អ្នកឯងមិនមែនឈឺទេ តាមពិតធ្វើពុតជាឈឺ។ ខ្មែរក្រហមគេគិតអ៊ីចឹង។ <ហើយក៏អាច>បានន័យថា យើងអ្នកឈឺហ្នឹងគឺថាមានន័យថាមានមនោគមន៍វិជ្ជាមិនល្អ។ <នេះជាអ្វីដែលខ្ញុំបានរកឃើញនៅពេលក្រោយមកទៀត។ ផលប្រយោជន៍របស់ពាក្យស្លោកទាំងនេះ គឺដូចជាកំណាព្យអ៊ីចឹង។> ពាក្យស្លោកហ្នឹង វាអាចមានន័យច្រើន។ ក៏ប៉ុន្តែដើម្បីឆ្លើយដោយខ្លីទៅនឹងសំណួររបស់លោកនោះគឺ ខ្ញុំអាចបង្ហាញឧទាហរណ៍ ដូចជានៅក្នុងសៀវភៅរបស់ មឿង សុន គឺថាក្មួយរបស់គាត់ ឬក៏ប្អូនថ្លៃរបស់គាត់ហ្នឹងគឺស្លាប់នៅការដ្ឋានតែម្តង។ អ៊ីចឹងហើយនៅការដ្ឋានហ្នឹង គេចង់ឲ្យធ្វើការរហូត មិនឲ្យឈឺទេ ចង់ធ្វើការទាល់តែស្លាប់តែម្តង។ អ៊ីចឹងហើយ គឺថាត្រូវតែធ្វើយ៉ាងម៉េចបង្កបង្កើនផលឲ្យមហាអស្ចារ្យ មហាលោតផ្លោះ។ <ពួកគេមិនចង់ចំណាយពេលឥតប្រយោជន៍ជាមួយអ្នកឡើយហត់ ឬ>អ្នកឈឺ<នោះទេ។ ពួកគេ>ត្រូវតែធ្វើការ។ <នេះជាអ្វីមួយដែលជាក់លាក់សម្រាប់បដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ>។

[១០:៥៥:៣០]

**ស៖** ហើយចំពោះដែលពាក្យស្លោកចុងក្រោយដែលគេនិយាយថា "អ្នកជំងឺមិនបាច់ស៊ីទេ ព្រោះថាជំងឺហ្នឹង វាធ្វើឲ្យបាត់ការស្រេកឃ្លាន ហើយការអត់អាហារហ្នឹង វាឲ្យជាសះស្បើយ"។ អ៊ីចឹងវាមិនមែនជារឿងគ្មានន័យអីទេ មែនទេ ក្នុងការគិតថាអ្នកជំងឺ<ដែលបានចុះខ្សោយហើយនោះ គឺថា>អាចជា

សះស្បើយ<ដោយ>ទទួលអាហារបានតិចតួចនោះ? <តើនោះមិនមែនជាការមិនសមទំនងមួយទៀតនៃរបបនោះ>ទេ មែនទេ?

**ឆះ** ខ្ញុំមិនច្បាស់ដែរ ត្រង់ចំណុចហ្នឹង។ បើអ្នកណាម្នាក់ឈឺខាំងដោយសារអត់អាហារនុំង គឺអាហ្នឹងជារឿងឧក្រិដ្ឋហើយ។ ហើយជាពិសេសហ្នឹង អ្នកដែលឈឺហ្នឹង គេឲ្យសម្រាក ឲ្យគេងឲ្យបានច្រើនទៅ អាហ្នឹងវាជារូបមន្តរបស់គ្រូពេទ្យហើយ ដែលគេប្រើសម្រាប់ព្យាបាលជំងឺហ្នឹង ក៏ប៉ុន្តែនៅក្នុងបរិបទខ្មែរក្រហម វាជារឿងឧក្រិដ្ឋទៅវិញ។ អ្នកឈឺហ្នឹង គឺទៅជាអត់អាហារ ទៅជាគេមិនឲ្យអាហារទៅវិញ។

**សះ** ហើយខ្ញុំសូមនិយាយពាក្យស្លោកចុងក្រោយមួយទៀត គឺជាភាសាបារាំងលេខរៀងទី២១០ និងជាភាសាអង់គ្លេស២៤៥ គឺពាក្យស្លោកនេះពាក់ព័ន្ធ និយាយពាក់ព័ន្ធទៅនឹងខ្មាំង។ សូមលោកផ្ដល់តែនិយមន័យខ្លីទៅបានហើយ។ ពាក្យស្លោកនេះនិយាយថា "តវ៉ាខ្មាំង ប្រឆាំងខ្មោច"។

[១០:៥៧:២៥]

**ឆះ** ពាក្យស្លោកហ្នឹងពិតជាត្រូវបានគេនិយាយមែន ហើយមិនដឹងថាតើថ្នាក់ដឹកនាំជាអ្នកបង្កើតឡើងមកឬក៏យ៉ាងម៉េច ឬក៏ថ្នាក់ដឹកនាំមូលដ្ឋានជាអ្នកបង្កើតទេ។ យើងគិតលើពាក្យពីរ ខ្មាំង ហើយនិងខ្មោច គឺវាជារឿងគួរឲ្យស្អប់ខ្ពើមណាស់។ វាបង្ហាញអំពីគោលនយោបាយជិះជាន់នៅទូទាំងប្រទេស។ <យើងនឹងសម្លាប់អ្នកឯងដោយការបង្ក្រាបដ៏តិចតួចបំផុត។>

**សះ** តើពាក្យស្លោកហ្នឹង ជាពាក្យស្លោកដែលលោកបានស្ដាប់ឮជាច្រើនដងនៅក្នុងប្រទេសដែរឬទេ? លោកស្ដាប់ឮជាញឹកញាប់ទេ លោកចាំទេថា មានតែមនុស្សម្នាក់ ឬក៏មនុស្សមួយក្ដាប់តូចទេដែលនិយាយអំពីពាក្យស្លោកនេះ ឬក៏យ៉ាងម៉េច?

**ឆះ** ខ្ញុំបានកត់ត្រានៅក្នុងកំណត់ត្រារបស់ខ្ញុំពាក់ព័ន្ធនឹងពាក្យ -- ប្រភពដើមនៃពាក្យស្លោកហ្នឹង។ <ប៉ុន្តែជាថ្មីម្ដងទៀត ដូចលោកដឹងហើយថា ខ្ញុំប្រមូលពាក្យស្លោកទាំងនេះដើម្បីជាការកម្សាន្តសប្បាយ> ខ្ញុំមិនគិតថានឹងបោះពុម្ពផ្សាយនូវពាក្យស្លោកដែលខ្ញុំប្រមូលហ្នឹងទេ។ <ដូច្នេះខ្ញុំពិតជាមិនអាចឆ្លើយនឹងសំណួរនេះបានទេ>។ ក៏ប៉ុន្តែតាមលក្ខណៈវោហារសាស្ត្រហ្នឹង គឺមានន័យអស្ចារ្យណាស់ វាខ្លីមែនទែនពាក្យស្លោកហ្នឹង គឺវាមើលទៅដូចជាកំណាព្យអ៊ីចឹង។ ហើយខ្លីតែប៉ុណ្ណឹង គឺមានពាក្យតែបួនតែប៉ុណ្ណោះ តែវាមានន័យច្រើនណាស់ បើយើងពិនិត្យមើលទៅ។

**សះ** ខ្ញុំចូលទៅប្រធានបទផ្សេង។ នៅក្នុងសៀវភៅរបស់លោក លោកបានសរសេរជាច្រើនអំពី

រដ្ឋផ្ដាច់ការនៃកម្ពុជាប្រជាធិបតេយ្យ។ តើលោកអាចពន្យល់បានទេថា ពាក្យធាតុផ្សំអ្វីខ្លះដែលបង្ហាញថា របបកម្ពុជាប្រជាធិបតេយ្យនេះជារបបផ្ដាច់ការ?

[១០:៥៩:៣៨]

**ឆ៖** បាទ លោកចោទសំណួរទូលំទូលាយណាស់។ <>អ្នកស្រាវជ្រាវ<>អាចធ្វើសន្និសីទជាច្រើន<បន្តគ្នាអំពីរឿងនេះ។ ខ្ញុំច្បាស់ណាស់ថា>នៅក្នុងការសិក្សានយោបាយ<> គេនិយាយពីលទ្ធិផ្ដាច់ការជាច្រើន ដូចជាមានណាហ្ស៊ី ហើយនិងលទ្ធិផ្ដាច់ការរបស់ផ្ដាច់ការបែបកុម្មុយនីស្ដជាដើម។ ឥឡូវខ្ញុំចង់និយាយអំពីចំណុចតូចមួយរបស់ការងាររបស់ ចនមីល ដែល<សរសេរសៀវភៅអំពី សេរីភាព នៅប្រមាណឆ្នាំ១៨៦០ ហើយ>គាត់បែងចែកអំពីកន្លែងឯកជន ហើយនិងកន្លែងសាធារណៈ។ នេះគួរឲ្យចាប់អារម្មណ៍ណាស់។ អ្វីដែលទាក់ទងនឹងរដ្ឋ និងរដ្ឋបាលហ្នឹង និងអ្វីដែលស្ថិតនៅក្នុងវិស័យឯកជន ឧទាហរណ៍គ្រួសារជាដើម។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈពិសេស គឺលក្ខណៈសម្គាល់មួយនៃរបបដាច់ខាតនេះ គឺថាអង្គការនោះបំបាត់វិស័យឯកជនទាំងស្រុងតែម្ដង គឺអ្វីទាំងអស់សុទ្ធតែជានយោបាយ ដោយសារទាំងអស់សុទ្ធតែជារបស់រដ្ឋ។ ទោះបីគ្រាន់តែជាកួរស្រូវមួយហ្នឹងក៏ជារបស់រដ្ឋដែរ ចេកមួយផ្លែហ្នឹងក៏ជារបស់រដ្ឋដែរ បើយើងលួចចេក ឬក៏កួរស្រូវមួយដែលគ្មានការអនុញ្ញាតពីរដ្ឋហ្នឹង គឺបើអ្នកឯងជាជនល្មើសហើយ ហើយអ៊ីចឹងអ្នកឯងអាចទទួលទណ្ឌកម្មហើយ។ មានតឹងរ៉ឹងជាងហ្នឹងទៀត តាំងពីទាក់ទងផ្លូវភេទជាដើម គឺថាមិនដែលមានប្រទេសណាដែលគេតឹងដល់ថ្នាក់<ហ្នឹង>ទេ។ ខ្ញុំសូមអភ័យទោសដល់មិត្តភក្តិខ្មែរខ្ញុំ គឺថាគេយកប្រទេសខ្មែរធ្វើជាមន្ទីរពិសោធន៍មួយ គឺថាមន្ទីរពិសោធន៍នៃរបបដាច់ខាត។ អ៊ីចឹងយើងដឹងហើយ យើងមើលរបបកម្ពុជាប្រជាធិបតេយ្យនេះ គឺជារបបមួយដែលមានមនុស្សតែមួយក្ដាប់តូចទេ នៅប្រទេសកម្ពុជាមិនមែនមនុស្សម្នាក់ទេ មិនមែនដូចគេ ស្តាលីន ដូច ម៉ៅ សេទុង ឬ គីម អ៊ីលស៊ុង <ឬហ្វូ ជីមិញ> ដូចប្រទេសផ្សេងទេ ក៏ប៉ុន្តែជាមនុស្សមួយក្ដាប់តូចដែលថាជាអង្គការនោះ។ <វាជាសូវៀតពិតប្រាកដ។> នៅស្រុកខ្មែរយើងគឺអ៊ីចឹង។ ខ្ញុំអានហ្នឹង ឃើញថា ប៉ុល ពត មិនដែលសម្រេចដោយគ្មានយោបល់របស់ នួន ជា ទេ។ នួន ជា ក្រោយពីពេល ទូ សាមុត ស្លាប់ទៅហ្នឹង <>គាត់<គួរតែ>ក្លាយជាលេខាបក្ស<>។

[១១:០២:៣០]

<សម្រាប់មូលហេតុផ្ទាល់ខ្លួន> ខ្ញុំគិតថា នួន ជា គាត់មិនសូវពូកែនិយាយទេ ហើយមុខគាត់ហ្នឹងគឺមុខកាច ដូចយើងឃើញនៅតុលាការនេះស្រាប់ហើយ គាត់ញញឹមមិនស្រស់<ដូច ប៉ុល ពត> ទេ

<ហើយ> ប៉ុល ពត ហ្នឹងគឺគាត់ពូកែនិយាយជាង។ អ៊ីចឹង នួន ជា ជាស្រមោលរបស់ ប៉ុល ពត ហើយគាត់ផ្តល់យោបល់ទៅឲ្យ ប៉ុល ពត ទៅហើយកែលម្អទាំងអស់គ្នា ហើយខ្ញុំគិតថា ខៀវ សំផន ក៏មានតួនាទីសំខាន់ដែរ។ ពីព្រោះថានៅពេលដែលវគ្គអប់រំអីហ្នឹងគឺ ប៉ុល ពត និយាយមុនគេ ហើយនិយាយរាប់ថ្ងៃ ហើយបន្ទាប់មក នួន ជា និយាយ ហើយក្រោយមក ខៀវ សំផន និយាយ។ ហើយ ខៀវ សំផន នេះនៅពេលដែលអ្នកដែលមកពីបរទេសវិញមកសាលាតិចណូនេះ ហើយមានវគ្គអប់រំនោះ អ្នកវាគ្មិនសំខាន់ជាងគេគឺ ខៀវ សំផន នៅពេលនោះ។ អ៊ីចឹងបុគ្គលទាំងប៉ុន្មាននាក់ហ្នឹងគឺជាអ្នក<មានគំនិតដូចគ្នាមានគំនិតធ្វើជាតួបនីយកម្ម។ មិនមាននរណាម្នាក់ត្រូវបានអនុញ្ញាតឲ្យមានគំនិតជាលក្ខណៈបុគ្គលទេ។ ពួកគេត្រូវតែប្រគល់បុគ្គលភាពទាំងអស់ជូនអង្គការ>។ អ៊ីចឹងឲ្យប្រគល់មកឲ្យសមូហភាពទាំងអស់មកឲ្យរដ្ឋ ហើយប្រគល់ទាំងខួរក្បាលខ្លួនឯងមករដ្ឋផងដែរ។ អ៊ីចឹងមិនដែលមានបដិវត្តន៍ណាដែលស៊ីជម្រៅដល់ថ្នាក់ហ្នឹងទេ។

**ស៖** ឥឡូវខ្ញុំសូមត្រឡប់មកនិយាយពីលទ្ធិផ្តាច់ការវិញម្តង។ ហើយខ្ញុំដកស្រង់អ្វីដែលលោកនិយាយថា លោកបានអានក្នុងសៀវភៅរបស់លោក *"ពួត់ ឡេ ខ្មែររូស"* ដែលមានលេខឯកសារ E3/10640 មានចំណងជើងថា "អង្គការ" ជាភាសាបារាំងទំព័រ៩៤ ហើយនិង៩៥ ហើយ ERN គឺ <01303581>--

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យលោកព្រះរាជអាជ្ញាឲ្យលោក ERN ម្តងទៀត។

[១១:០៤:៤៤]

**ប្រធានអង្គជំនុំ៖**

សូមឲ្យលេខ ERN ម្តងលោកសហព្រះរាជអាជ្ញារងអន្តរជាតិ អ្នកបកប្រែបកមិនទាន់ទេ ឲ្យយឺតៗ។

**សួរដោយលោក វ៉ាំងសង់ ដឺ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ ERN ជាភាសាបារាំងគឺ មិនមានការបកប្រែទំព័រនេះទេ គឺ01303581 ទៅដល់82។ ទំព័រទី២នៃសម្រង់នេះ គឺលោកនិយាយដូចតទៅនេះលោកអ្នកជំនាញ ឥស្សរជនសំខាន់នោះគឺ ប៉ុល ពត, នួន ជានេះ គាត់ជាមនុស្សពីរ ប៉ុន្តែខួរក្បាលតែមួយទេ។ នួន ជា ពន្យល់ទៅ ថេត សម្បត្តិ អង្គាល់ទសវត្សរ៍ឆ្នាំ២០០០ហ្នឹង ដែល ថេត សម្បត្តិ នេះជាអ្នកដែលគាត់ទុកចិត្តជាងគេ។ <នួន ជា និយាយ

ថា> “ខ្ញុំមិនមែនដៃស្តាំ <>ឬក៏ដៃ<ឆ្វេងរបស់> ប៉ុល ពត ទេ គឺយើងឋានៈស្មើគ្នា។ ប៉ុល ពត ក៏មិនបម្រើខ្ញុំ ខ្ញុំក៏មិនបម្រើ ប៉ុល ពត ដែរ។ យើងទាំងអស់គ្នា គឺយើងបម្រើមាគ៌ាបក្សទាំងអស់គ្នា។” សូមបញ្ចប់ការដកស្រង់។ តើត្រង់ចំណុចនេះហើយឬ ដែលលោកហ៊ានអះអាងថា ប៉ុល ពត និង នួន ជា នេះធ្វើសេចក្តីសម្រេចរួមគ្នារាល់ដង?

**លោក ហង់រី ឡូកា៖**

**ឆ៖** បាទ ហ្នឹងហើយ។ នេះជាប្រភព ជាមូលដ្ឋានរបស់ខ្ញុំ។ ខ្ញុំមានទំព័រ ខ្ញុំមានឯកសារច្រើនទំព័រដែរ ខ្ញុំសប្បាយចិត្តដែលលោកដកស្រង់ចំណុចនេះមក។ ខ្ញុំជឿជាក់ថា ជាការត្រឹមត្រូវ។ យើងមានសាក្សីសក្ខីកម្មរបស់ ឌុច ដែរ។ ខ្ញុំជឿថា ឌុច នេះ បាននិយាយការពិតនៅពេលដែលគាត់និយាយថា អ្នកទាំងពីរហ្នឹង ពូអ៊ំទាំងពីរហ្នឹង គាត់និយាយថា អង្គការនេះ អង្គការហ្នឹងគឺសំដៅទៅ ប៉ុល ពត ហើយនិង នួន ជា។ អ៊ីចឹងយើងមានភស្តុតាងជាច្រើន ហើយយើងមាននៅក្នុងកំណត់ត្រារបស់ខ្ញុំនោះ គឺថាមានចម្លើយសេចក្តីប្រកាសរបស់ នួន ជា ខ្លួនឯងហ្នឹង នៅឆ្នាំ<១៩៦៧> អ្វីដែលគាត់និយាយទៅកាន់បក្សកុម្មុយនីស្តដាណឺម៉ាកនោះ។ ខ្ញុំមានសម្រង់ជាច្រើនដែលបង្ហាញថា នួន ជា គាត់ជាអ្នកបញ្ជាអង្គការហើយ។ ហើយគោលការណ៍ដាច់ខាតហ្នឹង គឺគោលការណ៍សម្ងាត់ នៅឯរាបណាថ្នាក់ដឹកនាំសម្ងាត់ហ្នឹងគឺមិនមានអ្នកណាចាប់បានហ្នឹង គឺបដិវត្តន៍រស់។ អ៊ីចឹង នួន ជា គាត់<បានអនុវត្តភាពសម្ងាត់នេះក្នុងកម្រិតគួរឲ្យកត់សម្គាល់។> កាលណោះ នួន ជា គាត់ស្រួលទេ គាត់មិនចាំបាច់ទៅចូលព្រៃម៉ាគីអីនឹងគេទេ។ គាត់អ្នកជំនួញ។ <ខ្ញុំគិតថា> គាត់លក់គ្រឿងសំណង់ សម្ភារៈសំណង់ គាត់នៅភ្នំពេញរហូតដល់ឆ្នាំ១៩៧០ រហូតដល់សម្តេច សីហនុ ធ្លាក់ពីអំណាចឯណោះ។

[១១:០៨:២០]

អ៊ីចឹងគាត់ ប៉ូលិសនគរបាល សីហនុ នោះ មិនអាចចាប់គាត់បានទេ ព្រោះគាត់ថា គាត់អាចលាក់ខ្លួនបានកាលនៅរបបសង្គមរាស្ត្រនិយមនោះ <ដោយសារតែ>វៀតណាមគេនិយាយថា <> “បនប៉ុល ពត, អៀង សារី” វៀតណាមគេប្រកាសអ៊ីចឹងថា “បនប៉ុល ពត, អៀង សារី”។ ហេតុអីបានវៀតណាមនិយាយអ៊ីចឹង? ពីព្រោះថា<> គេយល់ឃើញថា អៀង សារី ខ្សែខាងប៉េកាំង ព្រោះថាគាត់នៅប៉េកាំង ពី៧១ ទៅដល់៧៥ ហើយគាត់តាមដាន សីហនុ <គ្រប់ពេល>ហើយ<រារាំងមិនឲ្យ> សីហនុ ហ្នឹង <>ទៅចរចាជាមួយ<ឡុង បូរ៉េត និង សិរិមៈតៈ និងអ្នកផ្សេងទៀត ដែលដឹកនាំរបបសាធារណរដ្ឋ>។ អ៊ីចឹងចិន អៀង សារី ហ្នឹងគឺគាត់នៅតាមដាន សីហនុ។ ហើយគាត់ហ្នឹងក៏កាត់ចិនដែរ។ ហើយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្រោយមកទៀត របបខ្មែរក្រហមធ្លាក់ទៅហ្នឹង ចិន អៀង សារី ហ្នឹងមានប៉ាស្ព័រជនជាតិចិនផង <គេហៅឈ្មោះគាត់ថា ស៊ូ ហៅ។ ឈ្មោះនេះសឹងតែដូចនឹងឈ្មោះរបស់អគ្គរដ្ឋទូតចិន។ គាត់ស្លៀកពាក់ដូចជាជនជាតិចិន។> អ៊ីចឹងគឺជាមនុស្សរបស់ប៉េកាំងហើយ។ ហើយតាមរយៈ អៀង សារី នេះគឺលុយរាប់លានដុល្លារហ្នឹង គេផ្ញើមកឲ្យកម្ពុជាប្រជាធិបតេយ្យ គឺចូលមក<តាម> អៀង សារី។ អង្កាល់សម័យនោះៗ គឺមានការផ្តាច់ខ្លួនពីគ្នារវាងអ្នកគាំទ្រចិន ហើយនិងគាំទ្រសូវៀត។ អ៊ីចឹងវៀតណាមនោះ ក៏ប្រឆាំងនឹងចិន ប្រឆាំងនឹងលទ្ធិម៉ៅ ហើយក៏បានចុះហត្ថលេខាជាមួយនឹងសភាពសូវៀត។ ហើយ អៀង សារី នេះជាមនុស្សដែលវៀតណាមស្អប់ណាស់ ហើយវៀតណាមនោះបានប្រកាសថា មានតែ បនប៉ុល ពត, អៀង សារី។ ហើយអ្នកផ្សេងទៀតនោះ ដូចជា នួន ជា ហើយនិង សុន សេន នោះអាចក្លាយជាមិត្តភក្តិវៀតណាមបាន។ អ៊ីចឹងវៀតណាម គេដឹងច្បាស់ណាស់ហើយថាមនុស្សទី២ មិនមែន អៀង សារី ទេ គេដឹងថា នួន ជា ទៅហើយ ក៏ប៉ុន្តែការដែលគេប្រកាសយ៉ាងដូច្នេះនេះ គឺគេកាលសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជានេះ គេគិតថា គេអាចបញ្ចុះបញ្ចូល នួន ជា បាន។ អ៊ីចឹងហើយបានតុលាការប្រជាជនកាលសម័យនោះ មិនបានកាត់ទោស នួន ជា ទេ។ ហើយ ហេង សំរិន នោះជាមនុស្សបន្ទាប់បន្សំទេ។ ហើយកាលនោះ ឡេ យន់ ដែលជានាយករដ្ឋមន្ត្រី ទី១ នៃប្រទេសវៀតណាមកុម្មុយនីស្តនោះ គាត់ចាត់ទុកថា គាត់ជាមិត្តភក្តិ នួន ជា ព្រោះថា នួន ជា ក៏បានទទួលការបណ្តុះបណ្តាលពីវៀតណាមដែរ។ គាត់ចេះវៀតណាមទៀតផង។ ហើយគាត់ហ្នឹងហើយ ដែលតែងតែចរចារវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម។ ហើយ ឌុច ក៏ធ្លាប់បាននិយាយនៅទីនេះដែរថា គឺ ហេង សំរិន នេះគ្រាន់តែជាអ្នកជូន នួន ជា ទៅចរចាជាមួយវៀតណាមទេ។ អ៊ីចឹង នួន ជា ជាមិត្តភក្តិរបស់វៀតណាម។

[១១:១១:៤៣]

**សៈ** ខ្ញុំសូមអរគុណ។ យើងនិយាយពីលទ្ធិផ្តាច់ការវិញម្តង។ លោកបាននិយាយថា រដ្ឋហ្នឹងឈ្លានពានទៅវិស័យឯកជន ពិនិត្យលើជីវិតឯកជនរបស់គេ។ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យនេះ តើការត្រួតពិនិត្យលើជីវិតឯកជនរបស់គេនេះ គេធ្វើហ្នឹងក្នុងនាមជាប្រជាជន ឬក៏យ៉ាងម៉េច?

**ឆៈ** បាទ នេះជាវោហារសាស្ត្រនៃប្រទេសកុម្មុយនីស្តទាំងអស់ ឡេនីន, ស្តាលីន អីហ្នឹង គាត់មិនមែនជាវណ្ណៈអធនទេ ប៉ុន្តែប្រកាសខ្លួនឯងនោះថា ឡេនីន -- កាល់ម៉ាក្ស នោះគាត់ថា អ្នកវណ្ណៈអធនត្រូវឡើងកាន់អំណាច។ ហើយ ឡេនីន នេះគាត់និយាយថា មានតែយើងទេ ពួកអនុធននោះ ឬក៏បញ្ញវន្ត

នោះ យើងនឹងជាអ្នកតំណាងឲ្យវណ្ណៈអធន។ ហើយ ប៉ុល ពត ខ្លួនឯងនោះ ទៅបង្កើតប្រវត្តិរូប<ថ្មីនៅប្រទេសយូហ្គោស្លាវី។ គាត់មិនធ្លាប់ជាកម្មករទេ។ ដៃរបស់គាត់មិនដែលបានធ្វើអ្វីទាំងអស់>។ គាត់មានជីវភាពធូរធារនោះ។ គាត់មានបងប្អូនធ្វើការនៅវាំង គាត់រៀននៅសាលាល្អជាងគេនៃប្រទេសខ្មែរទៀតផង។ គាត់មិនមែនជាវណ្ណៈអធនអីទេ។ ក៏ប៉ុន្តែដោយសារមនោគមន៍វិជ្ជាហ្នឹង គឺគាត់ត្រូវប្រាប់គេថា គាត់ជាវណ្ណៈអធនដែរ ក៏ប៉ុន្តែនេះជាការកុហកទាំងស្រុងតែម្តង។ ម៉ៅ សេទុង នោះ ក៏មិនមែនជាអ្នកវណ្ណៈអធនអីដែរ។

**ស៖** តើលទ្ធិផ្តាច់ការដែលលោកបានពណ៌នានេះ បានត្រូវបានបង្កើតឡើងភ្លាមៗតែម្តង ឬក៏បន្តិចម្តងៗ? <>ហើយតើ<អ្នកដែលក្លាយជាជនរងគ្រោះនោះ តើនៅពេលខុសគ្នាឬ មិនថា>ប្រជាជនចាស់ ប្រជាជនថ្មី<ទេ>?

[១១:១៤:១០]

**ឆ៖** លទ្ធិផ្តាច់ការនេះ បានបង្កើតឡើងហ្នឹង គឺនៅសម័យសង្គ្រាមស៊ីវិល ដែលមានតំបន់មួយចំនួនស្ថិតនៅក្រោមការត្រួតត្រារបស់ជនបដិវត្តន៍<>។ សេរីភាពទី១នោះ គឺថាដែលគេដកហូតនៅតំបន់រំដោះនោះ គឺគេដកហូតសិទ្ធិដើរហើរ។ ហើយបន្ទាប់មកទៀត ការជម្លៀសប្រជាជនទ្រង់ទ្រាយធំនោះបានចាប់ផ្តើមឡើងតាំងពីឆ្នាំ៧០, ៧១។ ឧទាហរណ៍ ប្រជាជនក្រចេះនោះត្រូវបានជម្លៀស។ គេថាអាមេរិកាំងទម្លាក់គ្រាប់បែកនៅក្រចេះនុ៎ង កាលនោះខ្ញុំនៅក្រចេះដែរ ខ្ញុំគិតថា <ខ្ញុំនឹងអាចរកឃើញការសម្លាប់រង្គាល>។ ក៏ប៉ុន្តែ<ពួកគេនិយាយថា "ទេៗ មានមនុស្សតិចតួចប៉ុណ្ណោះត្រូវបានគេសម្លាប់ ហើយទីក្រុងអត់មានមនុស្សនៅទេ"។> ហើយអង្គតាសោមក៏ជម្លៀសដែរ យើងនៅឧដុង្គនោះក៏ជម្លៀសដែរ។ ហើយ ភី ភួន បានពន្យល់នៅតុលាការយើងនេះដែរ ថាគេជម្លៀសដើម្បីការពារប្រជាជន។ មាននៅក្រុងកំពង់ចាមហ្នឹង ក៏គេជម្លៀសមួយផ្នែកដែរ។ ហើយ<បន្ទាប់មកគេបានអនុញ្ញាតឲ្យ>ប្រជាជន<>ត្រលប់មកវិញ<>។ អ៊ីចឹងជំហានដំបូងចូលទៅលទ្ធិផ្តាច់ការហ្នឹងគឺ <គេហាមឃាត់មិនឲ្យប្រជាជនធ្វើដំណើរ ហើយបន្ទាប់មកគឺ>ការជម្លៀសហ្នឹង ហើយបន្ទាប់មកទៀតគឺគេរៀបចំកងសាមគ្គី។ យើងមើលទៅវាមិនសូវជាកាចឃោរឃៅអីពេកទេ។ <ពួកគេមិនបានធ្វើការលើដីទេ គេគ្រាន់តែគ្រប់គ្រងតំបន់កសិកម្មនៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិល>។ អ៊ីចឹងកាលនោះខ្មែរក្រហម<មិនបានគ្រប់គ្រងទីក្រុងណាមួយទេ លើកលែងតែក្រចេះ ដែលត្រូវបានជម្លៀសចេញ។ ពួកគេមិនបានគ្រប់គ្រងទីក្រុងណាមួយ>ទេ។ អ៊ីចឹងកាលនោះក៏នៅតាមជនបទហ្នឹង គេបង្កើតក្រុមសាមគ្គី ហើយរោងបាយរួមមិន

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទាន់ធ្វើនៅឡើយទេ។ ហើយនៅកន្លែងខ្លះប្រហែលជាអាចមានហើយ ក៏ប៉ុន្តែអ្វីដែលៗគួរឱ្យរន្ធត់នោះគឺ ថា លុបរូបិយប័ណ្ណចោល។ <ហេតុអ្វីបានជាគេមិនចាយលុយ?> ដោយសារគេយល់ឃើញថា លុយ ហ្នឹងវាស្រួលទិញអីក៏បាន ហើយអ៊ីចឹងគេយល់ថាបើសិនជាអត់មានលុយហ្នឹងទេ វាអត់មានសេរីភាពអី ច្រើនទៀតទេ។ អ៊ីចឹង<គឺបាត់បង់សេរីភាពទាំងអស់ ហើយ>ធ្វើឱ្យប្រជាជនហ្នឹងអាស្រ័យទៅអាជ្ញាធរ នៅទីនោះ ដែលពួកគេចែកបាយ ចែកសម្លៀកបំពាក់អីឱ្យ។ នេះជាដំណើរការដែលធ្វើបន្តិចម្តងៗនៃលទ្ធិ ផ្តាច់ការ។ ហើយបន្ទាប់មកទៀត គឺថាជម្លៀសយកតែមែនទែនតែម្តង។ ដល់ពេលហ្នឹងហើយ គឺថា យើងបាត់អ្វីទាំងអស់ គឺថាបាត់ទាំងទ្រព្យសម្បត្តិ បាត់ទាំងសិទ្ធិសេរីភាព។

[១១:១៧:១៧]

**ស៖** តើការដាក់រួមនេះ<>បាន<លេចរូបរាងពេញលេញ>នៅពេលណា? តើឥទ្ធិពលនៃការ ដាក់រួមនេះ ឬក៏ធ្វើសមូហភាពនេះ ការហូបចុករួមនេះវាជះឥទ្ធិពលអីខ្លះទៅលើប្រជាជន?

**ឆ៖** ឥឡូវខ្ញុំនិយាយពី មឿង សុន ហើយនិងប្រពន្ធរបស់គាត់ ផល្លី ហ្នឹង។ នេះគឺជាការចាប់ផ្តើម នៃការបង្កើតគុក ពិភពគុកហើយ គឺថានៅឆ្នាំ១៩៧៥ គឺថាពីខែមេសា ទៅដល់ចុង៧៥នេះ គឺថាយើង ទើបតែនឹងចេញពីសង្គ្រាមស៊ីវិលដែលបង្កមហន្តរាយ ដោយការទម្លាក់គ្រាប់បែក មានមនុស្សរាប់ម៉ឺន នាក់ដែលភៀសខ្លួន។ ហើយមានចម្ការជាច្រើនដែលអត់មានដំណាំដាំដុះ។ <ដូច្នេះគឺវាច្បាស់ណាស់ថា គឺមូលហេតុស្រូវអង្ករ ដែលផ្ទុយពីអ្វីដែល>ខ្មែរក្រហម<និយាយថា ពួកគេមិនមានផែនការជម្លៀស ប្រជាជនទេ ពួកគេមិនមានស្រូវអង្ករបម្រុងទុកនៅកន្លែងណាទេ>។ <មិនមានការសង្ស័យអ្វីទេ នៅក្នុង រយៈពេល>នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យនោះ មិនមានអ្វីហូបចុកអីទេ។ អង្គាល់នោះយើងគួរ ឆ្ងល់ដែរ កាលពីដើម ពីខែមេសា ដល់ឆ្នាំចុង៧៥នោះ អត់មានអ្វី អត់មានអាហារទេ ប៉ុន្តែមនុស្សអត់សូវ ស្លាប់ទេ ដោយសារប្រជាជនគាត់ដើរទៅរកចំណីអាហារអីខ្លួនឯង ចូលព្រៃចូលអីរកទៅ រកត្រី រកអី បានខ្លួនឯង។ អ៊ីចឹងយើងគេអាចបន្តរស់រានបាន ក្នុងឆ្នាំ៧៥នេះ មិនសូវមានមនុស្សស្លាប់ទេ អត់មាន ម្ហូបអាហារអីច្រើនទេ ស្បៀងអីច្រើនទេកាលនោះ។ គេប្រាប់ឱ្យប្រជាជនខំប្រឹងធ្វើការ ឱ្យដាំដុះ ធ្វើស្រែ គេឱ្យឆ្ការព្រៃ ដើម្បីធ្វើស្រែអ្វីជាដើម។ ហើយពេលនុ៎ងគឺលែងបំបាត់មូលធនហើយ គឺថាដាំអ្វី គេប្រាប់ ថាដាំអីបានហ្នឹងមកវិញហើយ។ មនុស្សទាំងអស់ហ្នឹងគេថា គេសប្បាយចិត្តនឹងធ្វើ។ ក៏ប៉ុន្តែនៅពេល ដែលដល់រដូវច្រូតកាត់ហ្នឹង ខែធ្នូអីហ្នឹង គេប្រាប់ថាអត់ទេ កុំយកស្រូវហ្នឹងទៅដាក់ផ្ទះអ្នកឯង យកទៅ ដាក់នៅសហករណ៍ យកទៅដាក់នៅជង្រុកសហករណ៍។ ហើយខ្ញុំមិនដឹងថាគេត្រូវហៅប្រជាជនហ្នឹង

បន្តិច ហៅយ៉ាងម៉េចទេ ព្រោះថាដូចជាអ្នកទោសទៅហើយ។ អ៊ីចឹងគេប្រាប់ប្រជាជនកាលនោះថា ចាប់ពីខែ០១ទៅ យើងហូបចុករួម។ អ៊ីចឹងគឺនៅចុងឆ្នាំ៧៥ហ្នឹងហើយដែលគេបង្កើតសហករណ៍ គឺជាការចាប់ផ្ដើមនៃរបបផ្ដាច់ការនិយមហើយ គឺថាឆ្នាំង ចាន ស្លាបព្រាអីទាំងអស់ហ្នឹង គេប្រមូលអស់ហើយ គេទុកតែស្លាបព្រាឱ្យទេ។ អ៊ីចឹងយើងចេញពីទុរគតមកទុរ្ភិក្សហើយ។

[១១:២០:៣៤]

អ៊ីចឹង៣ឆ្នាំដែលបន្ទាប់មកទៀតហ្នឹង គឺថាមានទិន្នផលស្រូវច្រើនណាស់ សម្បូរហូរហៀរ ច្រើនណាស់។ <មនុស្សគ្រប់គ្នាដែលខ្ញុំបាននិយាយជាមួយ បាននិយាយថា “នៅកម្ពុជា យើងមិនដែលបានផលិតស្រូវច្រើនដូចនៅសម័យនោះទេ”។ ដូច្នេះ ហេតុអ្វីបានជា>មនុស្សស្លាប់ដោយស្រេកឃ្លាន? ដោយសាររដ្ឋាភិបាល -- រដ្ឋផ្ដាច់ការហ្នឹងបង្អត់អាហារប្រជាជន។ ហើយដល់ថ្នាក់កាត់យក៧៥ភាគរយនៃទិន្នផលនុ៎ងទៅនោះ។ ប្រធានាធិបតីបារាំងហ្នឹង <រងការរិះគន់ ដោយសារ>គាត់ថា គាត់ត្រូវយកពន្ធពីអ្នកមាននោះដល់ទៅ៧៥ភាគរយ អ្នកមានត្រូវយកពន្ធ៧៥ភាគរយ <-- ពិតណាស់វាធ្វើទៅមិនរួចទេ> តែប្រទេសខ្មែរវិញយកពីអ្នកក្រហ្នឹងអស់រលីងតែម្ដង ដល់៧៥ភាគរយ។ អ៊ីចឹងហើយបានមនុស្សស្លាប់ដោយអត់ឃ្លាន។

**សៈ** ការបង្កើតលទ្ធិផ្ដាច់ការនេះ តើមានយន្តការនៃការធ្វើឱ្យមនុស្សហ្នឹងក្លាយជាសត្វដែរឬទេ?

**ឆៈ** បាទ ជាការពិតហើយ គឺថាធ្វើឱ្យមនុស្សបាត់ភាពជាមនុស្ស ដោយសារខ្លួនហ្នឹងមិនមានសិទ្ធិអ្វីទាំងអស់ មិនមានម្ចាស់ការអីទាំងអស់ មិនអាចមានសិទ្ធិសម្រេចអ្វីទាំងអស់ ទាក់ទងនឹងប្រពន្ធរបស់ខ្លួន ពីជីវិតមនោសញ្ចេតនារបស់ខ្លួន យើងលែងជាមេគ្រួសារ យើងលែងជាអ្នកគ្រប់គ្រងពេលវេលារបស់យើង គឺថាយើងមិនដឹងថាថ្ងៃហ្នឹងយើងត្រូវធ្វើអីខ្លះ ដោយមានផែនការរបស់ខ្លួនទេ ត្រូវតែគោរពតាមផែនការរបស់មេដឹកនាំខ្មែរក្រហមនៅតាមមូលដ្ឋាន។ គេវាយជួងពីព្រលឹមអ៊ីចឹងទៅ ឱ្យត្រូវងើបក្នុងពេលជាមួយគ្នា ចេញទៅធ្វើការជាមួយគ្នា គឺថាជាទូទៅអត់បានញ៉ាំបាយទេមុនចេញទៅធ្វើការនោះ ព្រោះថាដឹងញ៉ាំលើកទី១ គឺនៅថ្ងៃត្រង់។ អ៊ីចឹងយើងអត់មានសិទ្ធិទាំងជ្រើសរើសការងាររបស់ខ្លួនផង។ <>នេះគឺជាការបំបាត់សេរីភាពរបស់អ្នកជនបទ ព្រោះថាយើងត្រូវដឹងថាកសិករគាត់មានសេរីភាពណាស់ គាត់ចង់ធ្វើអីធ្វើហ្នឹង គាត់ដឹងការងាររបស់គាត់។ <ប៉ុន្តែដូចគេនិយាយ>អ៊ីចឹង នេះគឺជាការដាក់ប្រជាជនឱ្យក្លាយជាទាសករ <ដូច្នេះអ្វីៗដែលយើង>ធ្វើ <បានបាត់បង់ទៅ ដូចការដាក់ជាទាសករគំនិត និងជំនឿ។ ដូច្នេះ មានការដកតម្លៃមនុស្សជាតិទាំងស្រុងតែម្ដង ហើយមនុស្សមានការលំបាក និង

ឈឺចាប់>។ <វាមិនមែនមនុស្ស មួយ ឬពីរភាគរយទេ ដែលប្រឆាំង>ដូច ប៉ុល ពត <>និយាយ<នៅក្នុងសុន្ទរកថាដ៏ល្បីរបស់គាត់នៅឆ្នាំ១៩៧៧>នោះ<>ថា <>មាន<ប្រជាជន>តែ<មួយ ឬពីរ>ភាគរយទេ ដែលយើងមិនអាចបង្ក្រាបបាន។ <វាផ្ទុយពីនោះឆ្ងាយណាស់។ ប្រហែលជាមានទាហានតិចតួចប៉ុណ្ណោះដែលរីករាយនឹងអំណាចខ្លះៗ ហើយទទួលបានផលពីអំណាចនោះ ដូច្នេះពួកគេហូបចុកគ្រប់គ្រាន់។ ពួកគេមិនមានសិទ្ធិសេរីភាពច្រើនទេ> ក៏ប៉ុន្តែ<យ៉ាងហោចណាស់ ពួកគេមានអំណាច។> គេមានសិទ្ធិអំណាច<>លើប្រជាជន ទុកចង់ឲ្យស្លាប់ៗ ចង់ឲ្យរស់។ <ប៉ុន្តែអ្នកទាំងអស់នេះមានមិនដល់មួយ ឬពីរភាគរយទេ> ហើយ<ប្រជាជន>ដល់ទៅ<៩៨ ឬ>៩៩ភាគរយឯណោះដែល<រស់នៅដូចសត្វធាតុ និងរងទុក្ខវេទនា>។

[១១:២៤:២២]

**សៈ** នៅពេលដែលអ្នកដែលមាន -- ចំពោះអ្នកដែលមិនព្រមចូលទៅក្នុងសហករណ៍ មិនចង់ដាក់រួម ហូបចុករួមនោះ តើមានរឿងអីកើតឡើងចំពោះគាត់?

**ឆៈ** អ្នកណាក៏ដឹងដែរ ចម្លើយ អ្នកណាក៏ដឹងដែរ។ បើយើងមិនសប្បាយចិត្តទេ គឺត្រូវបិទភ្នែក បិទត្រចៀក រន្ធត្រចៀក ហើយបិទមាត់ កុំតវ៉ានឹងគេ ធ្វើការដូចសត្វពាហនៈ ហើយកុំបញ្ចេញមនោសញ្ចេតនា ហើយកុំប្រាប់ឲ្យដឹងដើមកំណើតរបស់ខ្លួន មានមនុស្សមួយចំនួនដែរ ប្រហែលច្រើនគួរសមដែរ ដែលមានសមត្ថភាពធ្វើបែបនេះ អ៊ីចឹងគាត់នៅរស់រាន។ <ទោះយ៉ាងណា បើគេមានការសង្ស័យតិចតួចបំផុតមកលើយើង ឬមួយក៏យើងនិយាយចេញនូវគំនិតរបស់យើង ឬក៏គេដឹងថា យើងមកពីណា> គឺគ្រោះថ្នាក់ហើយ<ត្រូវគេចាប់ខ្លួន>។ មានមនុស្សច្រើនដែលលួចរត់ គឺថាទៅព្រំប្រទល់ថៃ ទៅព្រំប្រទល់វៀតណាម។ ហើយខ្ញុំចង់និយាយថា ច្រើនណាស់ដែលស្លាប់តាមផ្លូវនោះ ក្នុងចំណោមអ្នកលួចរត់នោះ ព្រោះថាតាមព្រំប្រទល់មានអ្នកយាមច្រើន។ គេយាមហ្មត់ចត់ ហើយបើតែកាលណាយើងលួចរត់ហើយ បទល្មើសនេះ គេត្រូវសម្លាប់ចោលហើយ។

**សៈ** មានទស្សនទានមួយដែលលោកបាននិយាយច្រើន នៅក្នុងលទ្ធិផ្តាច់ការហ្នឹង រដ្ឋផ្តាច់ការហ្នឹង លោកនិយាយថា <>អង្គការ<របស់បក្ស>។ ពេលដែលលោកនិយាយហ្នឹង ដែលខ្ញុំសួរថា ម៉េចបានប្រើពាក្យហ្នឹង។ អ្នកដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យប្រើពាក្យ “អង្គការ” ឬក៏ “រដ្ឋ” ហ្នឹងដឹកនាំហ្នឹង ក្នុងបំណងអីដែរ បានប្រយោជន៍ដែរ ហេតុអីបានគាត់ប្រើពាក្យហ្នឹង?

[១១:២៦:៣៥]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** មានសៀវភៅជាច្រើនទាក់ទងនឹងប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជា។ យើងដឹងថា ពីដើមមកនោះ គឺជាបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលបង្កើតដោយហូជីមិញទេ ដូចដែលសៀវភៅ ខាំបូលី ឌី របស់ស៊ី.ឌី.ខេមបានបង្ហាញអ៊ីចឹង ថាបើសិនជាគ្មានបក្សឥណ្ឌូចិន កុម្មុយនីស្តចិនទេ ហើយនិងបក្សកុម្មុយនីស្តវៀតណាមទេ មិនមានបក្សកុម្មុយនីស្តកម្ពុជាទេ។ ហើយក្រោយមកទៀត នៅឆ្នាំ១៩៥១ មានការសម្រេចនៅមូស្គូ ថាត្រូវបំបែកបក្សកុម្មុយនីស្តឥណ្ឌូចិនហ្នឹង។ អង្កាល់នោះមាន តាមពិតកាលនោះមានតែវៀតណាមទេ ក្នុងបក្សនេះមានតែវៀតណាមទេ មិនមានកម្ពុជា ហើយនិងឡាវទេ<>។ ហើយក្រោយមក គេបំបែកមកជាបីបក្សទៅ ហើយបក្សកុម្មុយនីស្តកម្ពុជាព្យាយាមប្តូរឈ្មោះ។ អ៊ីចឹង អ្នកសកម្មជនហ្នឹង គេដូចជាមិនដឹងថា ត្រូវដាក់យ៉ាងម៉េច គេដាក់មកថា ពាក្យ “អង្គការ” ហ្នឹងទៅ។ ឥឡូវនេះ យើងប្រើពាក្យអង្គការហ្នឹង អ្នកណាក៏ស្គាល់ដែរឥឡូវនេះ មិនមែនដូចអង្គការសម័យខ្មែរក្រហមទេ។

សំណួរទី២នោះ គឺថាហេតុអ្វីបានជាអ្នកដឹកនាំនៅលាក់មុខ ហើយមិនដូចជា ឡេនីន, ម៉ៅ សេទុង ហើយនិង គីម អ៊ីលស៊ុង, ហូ ជីមិញ នោះ មិននិយាយប្រាប់គេថា យើងជាអ្នកស្នេហាជាតិ ជាអ្នកដឹកនាំ ឬក៏ជាបងធំនៃប្រទេសហ្នឹង។ អ៊ីចឹងខ្ញុំសូមបកទៅនិយាយពី នួន ជា តែម្តង គឺថាចំពោះ នួន ជា នេះ គឺគាត់ អារម្មណ៍គាត់រវីរក់តែនឹងរឿងអាថ៌កំបាំងលាក់ខ្លួនហើយ។ អ៊ីចឹងបើគេគិតថា បើសិនជាគេអត់ស្គាល់អ្នកដឹកនាំទេ គឺថាអ្នកដឹកនាំហ្នឹង អត់គ្រោះថ្នាក់ទេ មានគេការពារ។ ហើយកាលណាអ្នកដឹកនាំហ្នឹងគ្រោះថ្នាក់ហើយ បដិវត្តន៍ហ្នឹងក៏គ្រោះថ្នាក់ដែរ។ អ៊ីចឹងអង្កាល់នុ៎ង ខ្ញុំគិតថា នៅសម័យសង្គ្រាមស៊ីវិលនោះ វា១ត្រឹមត្រូវ។ ទោះជាគិតយ៉ាងដូច្នេះ ដែល ប៉ុល ពត គាត់ដើរតាំងពីរតនគិរីមកស្ទឹងជីនិតនេះ កាលនៅឆ្នាំ១៩៧០នោះ គឺថាកាលណោះខែឧសភា មិថុនា កក្កដា ដែល ប៉ុល ពត នោះ គាត់ដើរមក ហើយខ្ញុំបានសម្ភាស ភី ភួន បានខ្ញុំដឹងនោះ <ព្រោះ ភី ភួន ដើរជាមួយគាត់>។ អ៊ីចឹងគាត់ដើរមកដល់ស្ទឹងជីនិត ហើយកាលណោះ កុយ ធួន បានរៀបចំមូលដ្ឋានសម្ងាត់មួយនៅមាត់ស្ទឹងជីនិត -- នៅព្រំដែនកំពង់ធំ ហើយនិងកំពង់ចាម។ អ៊ីចឹងគាត់ស្ថិតនៅទីនោះ១ សឹងតែថា សឹងតែ<ពេញមួយរបបនោះ។ ចាប់>ពីដើមឆ្នាំ<១៩៧៥> ប៉ុល ពត ហើយនិង ខៀវ សំផន នោះគាត់ចូលមកភ្នំពេញបន្តិចម្តង១ ដើម្បីដណ្តើមយកទីក្រុងភ្នំពេញ។ ហើយតាំងពីឆ្នាំ៧១, ៧២, ៧៣, ៧៤ បីបួនឆ្នាំហ្នឹងគឺគាត់លាក់ គាត់នៅកន្លែងនោះ ហើយគាត់បានរៀបចំសមាជមួយនៅឆ្នាំ១៩៧១។ ហើយកាលនោះ អាមេរិកាំងទម្លាក់គ្រាប់បែក ហើយមិនដែលបានទម្លាក់គ្រាប់បែកត្រូវកន្លែងថ្នាក់ដឹកនាំខ្មែរក្រហមទេ។ អង្កាល់នោះបើ

សិនជាទម្លាក់គ្រាប់បែកនៅស្ទឹងជីនិតវិញនោះ ប្រហែលជាមិនមានលទ្ធិកុម្មុយនីស្តនៅប្រទេសកម្ពុជាទេ។ អ៊ីចឹងអាមេរិកាំងហ្នឹងស៊ើបការណ៍អន់។ អ៊ីចឹងយុទ្ធវិធីនៃការសម្លាប់នេះគឺវាមានសារប្រយោជន៍ណាស់នៅពេលនោះ។ ក៏ប៉ុន្តែដល់ក្រោយមកនៅពេលដែលចូលមកឡើងកាន់អំណាចហើយ នៅតែលាក់មុខអង្គការដដែលហ្នឹងគឺមិនត្រូវទេ ព្រោះវាមិនមែនជានិមិត្តរូបនៃសេចក្តីស្នេហា នៃស្រឡាញ់ប្រជាជនទេ ទៅជាសាបព្រោះអំពើភ័យរន្ធត់ទៅប្រជាជនទៅវិញ។ <ដូច្នេះវាជាយុទ្ធសាស្ត្រដ៏ខ្សោយមួយ ហើយចិនបានប្រាប់រឿងនេះទៅពួកគេ ហេតុដូច្នេះហើយបានជា ប៉ុល ពត បានបង្ហាញខ្លួននៅចុងឆ្នាំ១៩៧៧។>

[១១:៣១:០៥]

**ស៖** យើងបាននិយាយថា មានការលុបបំបាត់សាសនា។ លោកបាននិយាយនៅក្នុងសៀវភៅរបស់លោកហ្នឹងគឺថា អង្គការបានជំនួសព្រះ។ អ៊ីចឹងលោកមានមូលដ្ឋានអ្វីដែរ ដែលអាចឲ្យលោកនិយាយថា អះអាងថា អង្គការហ្នឹងដើរតួជាព្រះ?

**ឆ៖** ព្រះហ្នឹងនៅសាសនាគ្រិស្តហ្នឹង គឺជាអ្នកហៅថា ស្រឡាញ់មនុស្ស សេចក្តីស្រឡាញ់ជាអមតៈចំពោះមនុស្សជាតិ <ហើយមិនមានអ្នកណាមើលឃើញទេ>។ ហើយអង្គការនេះ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង ក៏មានតួនាទីដូចគ្នាអ៊ីចឹងដែរ គឺថាមានអំណាច គឺអំណាចល្អ ត្រូវផ្តល់សុភមង្គល អភិវឌ្ឍន៍ និងដល់ប្រជាជនដែលជាមាតាបិតានៃប្រជាជន។ ហើយអ៊ីចឹងនៅសម័យនោះ បើអត់មានអ្នកណាដឹងថា អង្គការជាអ្នកណាផងនោះ នួន ជា គ្មានអ្នកណាដឹងថា គាត់ជាអ្នកដឹកនាំសម័យនោះផង។ ហើយអ្នកដែលដឹងនោះ ទាល់តែអ្នកដែលមករៀនសូត្រនៅភ្នំពេញទេ។ ហើយ ប៉ុល ពត គេដឹងកាលនៅឆ្នាំ១៩៧៧ហើយទេ ដែលគេដឹងថា គាត់ជានាយករដ្ឋមន្ត្រី លេខាបក្ស។ កាលនោះប្រជាជនកម្ពុជា ដល់៩០ភាគរយឯណោះ មិនទាំងស្គាល់ថា ប៉ុល ពត នោះថាជាអ្នកណាផង។ គាត់ស្គាល់តែអង្គការទេ។ អ៊ីចឹងគឺថា ជាអត្តសញ្ញាណមួយ ជាទីអាថ៌កំបាំង ចំពោះស្ទើរតែប្រជាជនខ្មែរទាំងអស់តែម្តង។ អ៊ីចឹងហេតុអីបានខ្ញុំនិយាយពាក់ព័ន្ធនឹងសាសនា? ពីព្រោះថា <នៅក្នុងបក្ស -- ហើយខ្ញុំគិតថា ខ្ញុំបានសរសេរពីរឿងនេះ -- ជាពិសេសក្នុង> ការដណ្តើមបានអំណាចនៅថ្ងៃទី១៧ មេសា <ឬមួយក៏នៅពេលប្រារព្ធទិវា>បង្កើតកងទ័ពបដិវត្តន៍ <ឬថ្ងៃសម្រាកបក្ស>នៅ<ចុង>ខែ<កញ្ញា ដើមខែតុលា> គឺថាមានពិធីសាសនាដែលស្រដៀងនឹងពិធីសាសនាដែរ។ គេធ្វើបុណ្យប្រារព្ធពិធីបុណ្យនេះសម្រាប់អង្គការ។ ហើយគេដាក់មានឧទ្ទិសទៅដល់អ្នកស្លាប់<ដើម្បី>អង្គការ ពលីជីវិត<ដើម្បី>អង្គការ។ គេដាក់នៅលើ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឆាកមួយ មានរូបភាពមួយដែលជានិមិត្តរូបសម្រាប់អ្នកដែលស្លាប់ទៅដើម្បីមាតុភូមិ ដូចជា<រូបភាពរបស់អ្នកដែលបានលះបង់ជីវិតដើម្បីបដិវត្តន៍>។ អ៊ីចឹងវាហាក់ដូចជា គេធ្វើពិធីមួយសម្រាប់អ្នកដឹកនាំអង្គការ អ្នកដែលបម្រើអង្គការ ហើយច្រៀងអីក៏ច្រៀងដូចច្រៀងបែបលក្ខណៈសាសនាដែរ ហើយសុន្ទរកថាហ្នឹង ក៏ដូចគេសូត្រធម៌ដែរ ដូចរបៀបលោកសូត្រធម៌ដែរ។ ហ្វីលីព ស្បូត ក៏បាននិយាយអ៊ីចឹងដែរ។ អៀន ហារីស ក៏គាត់បានលើកឡើងចំណុចនេះដែរ។ គាត់បាននិយាយថា ខ្មែរក្រហមហ្នឹងនិយាយដូចលោកទេសអ៊ីចឹងដែរ។ អ៊ីចឹងវាមាន គេហៅថា "សាសនារបស់បក្ស" ហើយនិងសាសនាដែលយើងប្រតិបត្តិជាទូទៅ។ អ៊ីចឹងវាមានចំណុចពីរហ្នឹង ដែលអាចធៀបគ្នាបាន។

[១១:៣៥:០៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោកអ្នកជំនាញ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីជំនាញរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយកន្លះរសៀល។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៥ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការកិច្ចនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ អង្គជំនុំជម្រះមានបំណង

ស្តាប់នូវសារណាផ្ទាល់មាត់របស់ភាគីជុំវិញសំណើសុំរបស់ក្រុមមេធាវីការពារក្តី នួន ជា អនុលោមតាម វិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។

កាលពីព្រឹកមិញ មេធាវីការពារក្តីផ្ញើអ៊ីម៉ែលមួយជូនមកអង្គជំនុំជម្រះ និងភាគីនានា ដើម្បីឲ្យ អង្គជំនុំជម្រះទទួលយកធ្វើជាភស្តុតាងនូវមាតិកានៃនិក្ខេបបទបណ្ឌិតរបស់អ្នកជំនាញ ហង់រី ឡូកា ដែល មានចំណងជើងថា“ទស្សនវិស័យនៃសម្លាប់រង្គាល និងមនោគមន៍វិជ្ជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី១៧ មេសា ឆ្នាំ១០៧៥*(ស៊ិក)* ដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ៧៩” និងអត្ថបទមួយដែលគាត់បាននិពន្ធ ដែលមានតែភាសាអង់គ្លេសចាប់ពី ERN01307962 ដល់01307971 ដើម្បីអាចប្រើប្រាស់ជាឯកសារ ទាំងនេះ ក្នុងការសួរដេញដោលអ្នកជំនាញ។

ហើយជាដំបូងនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវី នួន ជា ដើម្បីឡើងធ្វើបទបង្ហាញអំពី សំណើសុំរបស់ខ្លួន។

[១៣:៣២:២៧]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំសុំលើកឡើងដោយសង្ខេបទេ។ ពិតណាស់ថា វាជាឯកសារ តូចមួយដែលត្រូវបានផ្តល់ជូនភាគីនានាតាំងពី៣ថ្ងៃមុនមកម្ល៉េះ។ ទី១ គឺជាឯកសារបួនទំព័រ ដែលជា ភាសាបារាំង គឺមានន័យថា *“គាប្លេត ម៉ាដែ”* ហើយខ្លឹមសារហ្នឹងគឺជាសារណាបណ្ឌិត។ ខ្ញុំជឿជាក់ថា លោក ហង់រី ឡូកា ជាអ្នកផ្តល់ឯកសារនេះមកអង្គជំនុំជម្រះ។ ហើយ<នៅថ្ងៃចន្ទ>ខ្ញុំអាចនឹងសំណួរ មួយចំនួនទាក់ទងទៅនឹងទំព័រចុងក្រោយនៃឯកសារនេះ។ ហេតុដូច្នេះហើយទើបខ្ញុំស្នើសុំដាក់ឯកសារ នេះចូលជាភស្តុតាង។ ឯកសារនេះគឺជា ឯកសារទី២ គឺជាឯកសារដែលជាសេចក្តីព្រាងរបស់លោក ហ ង់រី ឡូកា ដែលជាការប្រៀបធៀបកុម្មុយនីស្តនៅក្នុងកម្ពុជា ជាមួយនឹងប្រទេសដទៃ។ <វាជាឯកសារ ដែលមានចំនួន១០ទំព័រ> ហើយឯកសារនេះគឺត្រូវបានដាក់ដោយក្រឡាបញ្ជីនៅក្នុងឃ្លាំងផ្ទុកឯកសាររួ ម។ <ដូច្នេះឯកសារទាំងពីរនេះ>បានផ្តល់ទៅដល់ភាគីនានាប៉ុន្មានថ្ងៃកន្លងមកហើយ។ ហេតុដូច្នេះខ្ញុំ សូមស្នើសុំដាក់ឯកសារនេះផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយបន្តទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវី -- សហព្រះរាជអាជ្ញា ដើម្បី ធ្វើការកត់សម្គាល់ ឬឆ្លើយតបទៅនឹងសំណើសុំដែលលើកឡើងដោយមេធាវីការពារក្តី នួន ជា។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ យើងមិនមានការកត់សម្គាល់អីជាក់លាក់នោះទេ។ អ៊ីចឹង យើងអាស្រ័យទៅលើការគិតរបស់អង្គជំនុំជម្រះ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចុះខាងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

[១៣:៣៤:២៩]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខាងមេធាវីនាំមុខក៏មិនមានអ្វីជំទាស់ទៅនឹងការស្នើដោយមេធាវីការពារក្ដីដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចុះក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន មានមតិយោបល់អ្វីដែរទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ យើងគាំទ្រសំណើរបស់មេធាវី នួន ជា លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណហើយនូវមតិយោបល់របស់ភាគីពាក់ព័ន្ធលើសំណើសុំរបស់សហមេធាវីការពារក្ដី នួន ជា លើបញ្ហានេះ ហើយអង្គជំនុំជម្រះនឹងចេញសេចក្ដីសម្រេចឆាប់ៗលើសំណើសុំនេះ ធ្វើយ៉ាងណាឱ្យបានមុនការផ្ដើមសួរដេញដោលអ្នកជំនាញរបស់ក្រុមសហមេធាវីការពារក្ដីលោក នួន ជា។

ជាបន្តទៅនេះផ្ដល់វេទិកាជូនសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

[១៣:៣៥:៣៥]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ជម្រាបសួរលោកអ្នកជំនាញ។ ខ្ញុំចង់និយាយអំពីសហករណ៍ ដែលយើងហៅនៅទីនេះភាសាបារាំងគេហៅ "កូហ្សប៉េរ៉ាទីវ"។ ខ្ញុំចង់អានសម្រង់ពីសៀវភៅរបស់លោកមួយដែលមានចំណង

ដើងថា *"ពួគ័រ ឡៅ ខ្មែររូស៍"* ដែលមានលេខកូដ E3/10640 នៅជំពូករដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ នៅទំព័រជាភាសាបារាំងគឺទំព័រ១៣៦, ERN គឺ 01303602។ លោកនិយាយអំពីការបោសសម្អាតនៅឆ្នាំ <១៩៧៧> លោកនិយាយដូចតទៅនេះ៖ "ចាប់ពីឆ្នាំ១៩៧៧មក ក្រោយពីការបោសសម្អាតទ្រង់ទ្រាយធំ ដែលបានធ្វើនៅក្នុងជួរបក្សផ្ទាល់នោះ ប៉ុល ពត និងក្រុមរបស់ពួកគាត់យល់ឃើញថា មិនត្រូវបញ្ចូល សមាជិកផ្សេងទៀតក្រៅពីអ្នកដែលមានវណ្ណភាពជាកសិករក្រីក្រនោះទេ។ ជាពិសេសមិនត្រូវយកអ្នក ចេះដឹងឬក៏អនុធនឡើយ។ នេះជា<ការ>ពន្យល់ថា ហេតុអ្វីបានជានៅពេលដែលមានការបោសសម្អាត ទ្រង់ទ្រាយធំទៅ មេនៅតាមមូលដ្ឋានមួយៗត្រូវបានដំឡើងឲ្យឡើងកាន់អំណាចនៅតាមសហករណ៍ ជា ពិសេសពួកអ្នកដែលមិនចេះអក្សរ ហើយឃោរឃៅ។ អ៊ីចឹងសម្រាប់អ្នកដឹកនាំ <អ្នកទាំងអស់នោះគឺ> ស្អាតស្អំ<បរិសុទ្ធ> ហើយគឺបានន័យថា <ពួកគេងាយស្រួលបញ្ចុះ>បញ្ចូល <ជា>អ្នកដែលអាចបង្វិល ក្បាលបាន"<>។ អ៊ីចឹង<ខ្ញុំមានសំណួរមួយអំពីពាក្យថា "អនក្ខរជន" ហើយនិងការតែងតាំងអនក្ខរជន ទាំងអស់នេះ>នៅក្នុងថ្នាក់ដឹកនាំសហករណ៍<> តើជាការគ្រោះថ្នាក់ដែរឬទេ ក្នុងការផ្តល់ឲ្យអនក្ខរជន ឬអ្នកមិនចេះអក្សរនេះឡើងធ្វើជាអ្នកដឹកនាំថ្នាក់មូលដ្ឋាននោះ? គឺថាដោយសារចំណេះដឹងតិចតួចនោះ តើគាត់មានការវិភាគពិចារណាយ៉ាងម៉េចក្នុងការធ្វើសេចក្តីសម្រេចផ្សេងៗនោះ?

[១៣:៣៨:២៤]

**ផ៖** នេះជាបញ្ហា<ពេញមួយ>របបនេះទាំងស្រុងតែម្តង។ ថ្នាក់ដឹកនាំចេញសេចក្តីសម្រេច គ្មានន័យ ហើយដែលបង្កទៅជាលទ្ធផលដែលផ្ទុយអំពីគោលបំណងដែលខ្លួនចង់បាន។ <ខ្ញុំគិតថា> ខ្ញុំ បានអានសៀវភៅ ថេត សម្បត្តិ នោះថា នួន ជា ហើយនិងថ្នាក់ដឹកនាំខ្មែរក្រហមនោះ គាត់ព្យាយាមគិត ខុសអំពីការកាប់សម្លាប់នៅតាមថ្នាក់មូលដ្ឋាននោះ។ ហើយគាត់ថា គឺគាត់នៅខាងកំពូលនេះ គាត់មិន ដឹងការចាប់ខ្លួននិងការសម្លាប់ខ្លួននៅថ្នាក់មូលដ្ឋាននោះទេ។ ក៏ប៉ុន្តែខ្ញុំឆ្លើយតបទៅនឹងអំណះអំណាងនេះ វិញថា ប្រហែលជាគាត់មិនដឹងមែន ក៏ប៉ុន្តែអ្វីដែលច្បាស់នោះគឺថា លោកជាអ្នកតែងតាំងអ្នកដែលជា អនុ ហៅថា វណ្ណៈអធននោះ ជាកសិករ ដើមកំណើតជាកសិករ ឬក៏កម្មករ ជាពិសេសនោះកសិករតែ ម្តង អ្នកដែលសឹងតែមិនចេះអានផងនោះ។ តើហេតុអីបានយើងដឹងថា គាត់ជ្រើសរើសយ៉ាងដូច្នេះ ព្រោះថា មាន ហ្វីលីព ស្បូត បានគូសបញ្ជាក់ថា គាត់បានសិក្សាស្រាវជ្រាវពីចំណុចនេះ។ គាត់ចោទ បញ្ហាថា ក្រោយពីការបោសសម្អាតទ្រង់ទ្រាយធំនៅដំណាក់កាលទី២ នៃរបបខ្មែរក្រហមនោះ តើយើង <មិនបាន>ទៅ<ដល់ចំណុចមួយ ដែលចំនួនសមាជិកបក្ស បានធ្លាក់ចុះយ៉ាងខ្លាំងរួចទៅហើយ> បើ

ធៀបនឹងបក្សកុម្មុយនីស្តផ្សេងៗទៀតនៅលើពិភពលោក <កាន់តែតិចទៅៗទេឬ? ខ្ញុំមិនចាំពីចំនួនឃុំល្បីៗនោះទេ ប៉ុន្តែមានជាងមួយពាន់នៅពេលដំបូង។>។ អ៊ីចឹងដោយសារចំនួនមនុស្សកម្មាភិបាល<> ដែលត្រូវប្រើនេះ តិចនោះ អ៊ីចឹងគឺខ្វះហើយដើម្បីបម្រើតាមសហករណ៍នានានោះ។ អ៊ីចឹងក៏យកយោធាដែលគេរំសាយហើយនោះជាដើមនេះ<មកដាក់ឲ្យកាន់តួនាទីទាំងនោះ>។ អ៊ីចឹងៗ នេះជាការសម្រេចរបស់អ្នកដឹកនាំមួយខុស គ្មានន័យ។ <ដូច្នេះប្រភពនៃព័ត៌មាននេះ> មាន ហ្វីលីព ស្សូត ហ្នឹងមួយប្រភព ហើយនិងមួយទៀតគឺការស្រាវជ្រាវផ្ទាល់របស់ខ្លួនខ្ញុំ។ ខ្ញុំឮគ្រប់ទិសទី គេនិយាយថា ថ្នាក់ដឹកនាំមូលដ្ឋាន<>មិនសឹងហ្នឹងចេះអាន<ចេះសរសេរ>ផងទេ។ ហើយអ្នកដែលចង់លួចរត់នោះ គ្រាន់តែកៃច្នៃក្រដាសមួយ សរសេរក្លែងក្រដាសហ្នឹងមួយទៅ ក្រដាសដើរហើរហ្នឹងមួយទៅ ហើយថ្នាក់មេដឹកនាំតាមមូលដ្ឋាននោះ គាត់ជឿថាជាលិខិតហ្នឹង ចេញមកពីថ្នាក់លើមែន។ អ៊ីចឹងដោយសារអី ដោយសារគាត់ហ្នឹង សឹងតែមិនចេះអានផង មិនចេះអក្សរផងអ៊ីចឹង។ <ពួកគេមិនចេះអាន ហើយមិនយល់ ហើយគិតថា ជាលិខិតដើរផ្លូវពិតប្រាកដ។ ពួកគេមិនចេះអាន ហើយមិនអាចកំណត់អត្តសញ្ញាណលិខិតនោះបាន។ ហើយខ្ញុំគិតថា នេះជាបញ្ហាពិតប្រាកដ ហើយវាជាស្ថានភាពជាក់ស្តែង។> អ៊ីចឹង គឺអត់មានហេតុផលសមស្របអីទាល់តែសោះ។ ប៉ុល ពត ហ្នឹងចង់ឲ្យប្រជាជនកម្ពុជាហ្នឹងកើនឡើងមួយទ្វេជាពីរ <ក្នុងរយៈពេល១៥ឆ្នាំ។ ដូច្នេះទី១ យើងត្រូវការយ៉ាងហោចណាស់មួយជំនាន់ក៏>រយៈពេល៣០ឆ្នាំ <ដែរ ដើម្បីឲ្យចំនួនប្រជាជនកើនឡើងទ្វេដង។ ដូច្នេះ> បើត្រូវគិតតាមគណិតវិទ្យា វាមិនអាចទៅរួចទេ។ ហើយ<ទី២>បើយើងបង្អត់អាហារ ហើយសម្លាប់យ៉ាងច្រើនហើយ ៗក្នុងពេលជាមួយគ្នានេះ ចង់ឲ្យប្រជាជនកើនឡើងមួយទ្វេជាពីរនោះ វាមិនកើត មិនត្រូវទេ។ អ៊ីចឹងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យហ្នឹងវាពោរពេញទៅដោយភាពផ្ទុយគ្នា។

[១៣:៤២:២១]

**ស៖** ទាក់ទងនឹងកម្មាភិបាលទាំងអស់នោះ តើអ្នកដឹកនាំបក្សហ្នឹង គាត់ចង់បានកម្មាភិបាលដែលស្មោះស្ម័គ្រចំពោះគាត់ជាងកម្មាភិបាលដែលមានសមត្ថភាព ឬក៏យ៉ាងណា?

**ឆ៖** គេមើលមនុស្ស គឺគេយកតែអ្នកណាដែលចេះគោរព ហើយស្មោះត្រង់ចំពោះថ្នាក់លើតែប៉ុណ្ណឹងទេ។

**ស៖** អម្បាញ់មិញហ្នឹង យើងបាននិយាយអំពី ពេលដែលលោកនិយាយថា ពាក្យថា "៣តោនក្នុង១ហិកតា" តើមានការបង្ខំឲ្យសហករណ៍ទាំងអស់ហ្នឹង ទូទាំងប្រទេសទាំងមូលតែម្តងហ្នឹង ឲ្យ

ផលិតឲ្យបាន៣តោនក្នុង១ហិកតា ដោយមិនប្រកាន់ថាដីហ្នឹងមានជីជាតិ ឬក៏គ្មានជីជាតិទេ?

**ឆ៖** បើតាមអ្វីដែលយើងដឹងនោះ គឺថាពាក្យស្លោកហ្នឹង ពាក្យបញ្ញាដែលថា "មហាលោតផ្លោះ មហាអស្ចារ្យ" គេហ្នឹង ត្រូវអនុវត្តដូចគ្នានៅទូទាំងប្រទេសតែម្តង ទោះបីជាដីមានជាតិក៏ដោយ គ្មានជាតិក៏ដោយ មានជីជាតិក៏ដោយ។ អ៊ីចឹងនេះ ពាក្យស្លោក ឬក៏ពាក្យបញ្ញានេះ គ្មានន័យទេ ពីព្រោះថានៅក្នុងប្រទេសកម្ពុជា ពីតំបន់មួយទៅតំបន់មួយនោះ វាខុសគ្នាណាស់។ មានផ្ទះនៅតាមមាត់ទន្លេ ដីតាមមាត់ទន្លេអ៊ីចឹង គឺមានជីជាតិជាង ហើយនៅបាត់ដំបង បន្ទាយមានជ័យអីហ្នឹង គឺសុទ្ធតែដីដែលមានជីជាតិ ហើយដីក្រហមនៅរតនគិរី មណ្ឌលគិរី ហ្នឹងក៏មានជីជាតិដែរ។ ក៏ប៉ុន្តែជាទូទៅនោះ នៅខេត្ត ជាពិសេសនៅខេត្តកំពង់ស្ពឺ កំពង់ធំ ដែលដីហ្នឹងមិនសូវមានជីជាតិទេ ដោយសារមានដីឥដ្ឋច្រើន ដីខ្សាច់ច្រើន អ៊ីចឹងទិន្នផលវាអាចទាប វាលើកលែងតែវាមានទឹកច្រើន។ ក៏ប៉ុន្តែទន្ទឹមនឹងនោះ ដើម្បីដាំឲ្យបានច្រើនដងនោះ ត្រូវមានទឹកពេញមួយឆ្នាំតែម្តង ហើយដីនោះមានជីជាតិដែរ។ អ៊ីចឹងនៅតណ្ហនេស៊ី នៅបាលីវិញ ដីមានជីជាតិ នៅទីនោះយើងអាចដាំច្រើនដងបាន។ ហើយអ៊ីចឹងបើយើងគិតមើលទៅលើភាគច្រើននៅប្រទេសកម្ពុជាហ្នឹង គឺថាគោលបំណងកំណត់នោះ គឺគ្មានន័យ <ហើយជាមូលហេតុបណ្តាលឲ្យអត់បាយ ព្រោះ>យើងមិនអាច<ចេញពី១តោន ទៅ>៣តោនក្នុង១ហិកតា<តែមួយយប់បាន>ទេ។ ហើយដោយសារគេមិនព្រម<ទទួលស្គាល់ថា គោលនយោបាយនោះបរាជ័យ ដោយសារតែស្រូវអង្ករយ៉ាងច្រើនត្រូវបានគេដឹកជញ្ជូនយកទៅឲ្យ>រដ្ឋ <មានន័យថា អត់មានអ្វីនៅសល់សម្រាប់ប្រជាជនហូបចុកទេ។ ដូច្នេះពាក្យស្លោកនេះចេញពីភាពអត់ឃ្លាន>។

[១៣:៤៥:៤១]

**ស៖** តើគោលបំណងទៅឲ្យដល់៣តោនក្នុង១ហិកតានោះ មានវិវត្តដែរឬទេ រយៈពេលវែង ថា <តើមានគោលបំណងនៅឆ្នាំបន្តបន្ទាប់ទៀតឲ្យធ្វើដល់>៤ទៅ៥តោន<ទេ? តើលោកបានឮព័ត៌មានប្រភេទនេះពី>ថ្នាក់ដឹកនាំខ្មែរក្រហម<ទេ ពាក់ព័ន្ធនឹង>ផែនការបក្ស<>?

**ឆ៖** បាទ មានផែនការដែលបង្កើតនៅឆ្នាំ១៩៧៦ ដែលថាផែនការ៤ឆ្នាំ ពី៧៦ដល់ឆ្នាំ៨០នោះ ដែលគ្រោងថា ធ្វើយ៉ាងណាបង្កើនផលឲ្យបានច្រើនជាងហ្នឹងទៀត។ អ៊ីចឹងផែនការហ្នឹង ត្រូវបានបកប្រែដោយក្រុមការងារ ដេវីដ ឆេនដ័ល័រ ជាឯកសារដែលគួរតែអាន ហើយខ្ញុំបានអានឯកសារហ្នឹង ហើយខ្ញុំដកស្រង់ជាច្រើនដងនៅក្នុងសៀវភៅរបស់ខ្ញុំ។ ហើយផែនការនេះ គឺជាផែនការស្រមើស្រមៃទាំងស្រុង បើក្នុងតថភាពសង្គមនោះ វាមិនអាចធ្វើទៅរួចទេ។ ប៉ុន្តែអ្វីដែលវាសមស្របនឹងការពិតនោះ

គឺថាមែន យើងផលិតធ្វើស្រូវបានច្រើនមែន ជាងសម័យសាធារណរដ្ឋ<> ហើយនិងជាងសម័យសង្គមរាស្ត្រនិយមទៀត។ <ជាការពិតហើយ ពួកគេមិនបានបង្កើតផលិតផល>ដល់ទៅ៣ដង<នោះទេ ប៉ុន្តែមានការកើនឡើងគួរឲ្យកត់សម្គាល់>។ ផលិតផលកើនមែន ក៏ប៉ុន្តែថាស្រូវហ្នឹង បានហើយទៅឯណាវិញ ក្លាយជាអីវិញ? អ៊ីចឹងដល់ពេលខ្ញុំមើលកំណត់ត្រាខ្ញុំឡើងវិញនោះ ខ្ញុំឃើញថា នៅសហករណ៍នៅខាងភូមិភាគបូព៌ានោះ ក៏ពេលខ្លះគាត់លាក់ទិន្នផលដល់ទៅ៣០ភាគរយ គឺបានន័យថា គាត់មានទម្លាប់កាលពីសង្គ្រាមស៊ីវិលហ្នឹង គាត់<លាក់>ស្បៀង<បម្រុងទុក>។ យើងមានភស្តុតាងពីចំណុចនេះ នៅពេលដែល<ពួកគេត្រូវបានបណ្តេញចេញពីអំណាច>នៅតាមភ្នំក្រវាញ នៅតាមព្រៃ ហើយបើនៅបាត់ដំបងអីនោះ គឺមានកន្លែងគេស្តុកស្រូវ គេលាក់ស្រូវធ្វើស្បៀង។ ស្រូវភាគច្រើនហ្នឹង ដឹកចេញទៅបាត់ហើយ ដូចខ្ញុំនិយាយពីព្រឹកមិញអ៊ីចឹង គឺថាទៅដល់៧៥ភាគរយ។ <ប៉ុន្តែ> វា<អាចថាមាននៅសល់>ច្រើន<ដែលគេទុកនៅក្នុងឃ្លាំងក្នុងទីក្រុង នៅ>ទីរួមខេត្តហើយ <និងជាពិសេស>ដឹកមកភ្នំពេញ។ ខៀវ សំផន នៅចំពោះមុខយើងនេះហើយ។ អ៊ីចឹងការងារមួយ ឬក៏បេសកកម្មមួយ<របស់គាត់> គឺត្រូវត្រួតពិនិត្យមើលឃ្លាំងនៅភ្នំពេញ នៅតាមបណ្តោយដងទន្លេសាបហ្នឹង គឺថាមានឃ្លាំងស្រូវ មានឃ្លាំងស្ករ ឃ្លាំង<ពោត>អីជាដើម។ អ៊ីចឹងដើម្បីឲ្យដឹងរឿងហ្នឹងឲ្យច្បាស់ ទាល់តែសួរ ខៀវ សំផន<ដែលមានវត្តមាននៅទីនេះ>។ គាត់អាចមានលទ្ធភាពឆ្លើយច្បាស់លាស់ជាងខ្ញុំ ត្រង់ចំណុចនេះ។

[១៣:៤៨:៥៥]

**ស៖** ទាក់ទងនឹង ខៀវ សំផន កាលពីព្រឹកមិញ លោកបាននិយាយពីចំណុចមួយ គឺថាសុន្ទរកថា<របស់គាត់>និយាយពីកុមារ។<ខ្ញុំសូម>ដកស្រង់ចំណុចនេះ។ <លោកបាននិយាយ>នៅក្នុងសៀវភៅរបស់លោក ចំណងជើងថា *"ពួត់ វ ឡៅ ខ្មែររូស"* គឺសៀវភៅដែលមានលេខ ERN គឺE3/10640, ទំព័រជាភាសាបារាំងគឺ១៧៦, ERN <01303622>។ នេះគឺជាសុន្ទរកថា ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៧។ ភាគីអាចរកឃើញឯកសារនេះ នៅក្នុងសារហ្វីប៊ីសផងដែរ។ <នេះគឺជាអ្វីដែលលោក>ដកស្រង់ដែលពីសុន្ទរកថារបស់ ខៀវ សំផន នេះ។ "កុមារៗរបស់យើង លេងជាមួយកូនឡាន កូនកប៉ាល់ កូនកាំភ្លើង ដែលពីដើមមកគឺនាំចូលមក ហើយខាតលុយច្រើនណាស់។ ក្មេងៗរបស់យើងហ្នឹង គឺសប្បាយចិត្តនឹងដេញចាបនៅពេលច្រូតស្រូវ ហើយនិងមើលគោមើលក្របី ហើយនិងធ្វើជី ហើយនិងជួយលើកទំនប់ ជីក លើកទំនប់ ហើយនិងជីកអាងទឹក ហើយនិងរណ្តៅជាច្រើន។ កុមារៗរបស់យើងបានរីកចម្រើនខ្លាំង ហើយមានវិន័យខ្លាំងរៀសរវៃ មានភាពប៉ិនប្រសប់ មិនឈ្លើយ មិនខូចខិល ហើយពួកគាត់

ចូលចិត្តធ្វើការងារ និងបង្កបង្កើនផល។" សូមបញ្ចប់ការដកស្រង់។

ដូច្នេះនៅកន្លែងនេះយើងឃើញអ្នកដឹកនាំនិយាយជួសមុខឱ្យអ្នកដទៃ គឺថានិយាយថាក្មេងៗហ្នឹងសប្បាយរីករាយ។ តើតាមរយៈការសម្ភាសរបស់លោកនោះ តើលោកមានឮថាក្មេងៗហ្នឹងសប្បាយចិត្តនឹងធ្វើការឱ្យអង្គការដែរឬទេ?

**ឆ៖** ខ្ញុំអត់បានកត់លេខទំព័រនៅការបោះពុម្ពផ្សាយជាភាសាបារាំងទេ។ អ៊ីចឹង ខ្ញុំសួរលោកជាទំព័រជាភាសាបារាំងហ្នឹងនៅទំព័រលេខប៉ុន្មាន?

[១៣:៥១:៣០]

**សៈ** យើងមាន<តែឯកសារជាភាសាបារាំងទេ> លេខទំព័រគឺ១៧៦ លោកអ្នកជំនាញ។ ជាភាសាបារាំង គឺការបោះពុម្ពផ្សាយថ្មី ខែកក្កដា ឆ្នាំ២០១៦ -- ២០០៦ សូមទោស ១៦ <គឺសៀវភៅ *"ពួកវ័រឡូ ខ្មែរក្រហម"* មិនមែន "កូនសៀវភៅក្រហមរបស់ ប៉ុល ពត" ទេ>។

**ឆ៖** <វាពិតជាបានដកស្រង់ចេញពីសៀវភៅ "កូនសៀវភៅក្រហម" ផងដែរ។ ខ្ញុំមិនមានសម្រង់ជាភាសាបារាំងទេ ប៉ុន្តែមាន>ជាភាសាអង់គ្លេស។<> ផ្នែកដើមនៃសម្រង់ហ្នឹង គឺថាគួរឱ្យចាប់អារម្មណ៍ណាស់។ វាទាក់ត្រង់វាស៊ីគ្នាទៅនឹងប្រពៃណីខ្មែរ។ <នៅជនបទ> គឺថាក្មេងៗតាមធម្មតាយើងឱ្យវាដេញចាបនៅតាមវាលស្រែអីអ៊ីចឹងទៅ មើលគោ មើលក្របី។ ដេញចាប មើលគោល មើលក្របី មើលពេលជួយការងារពេលច្រូតស្រូវហ្នឹង។ អ៊ីចឹងយើងអាចបន្ថែមទៀតបាន<> ដូចថាចាប់កង្កែប <និងរកបន្លែព្រៃ>អីអ៊ីចឹងទៅ។ នេះគឺជាការងាររបស់ក្មេងៗនៅស្រុកស្រែ។ ក៏ប៉ុន្តែប្រមូលជីអាចម៍គោអីនេះ អានេះថ្មីហើយ ហើយ<កាន់តែអាក្រក់ទៅទៀតនោះ គឺ>ជួយលើកទំនប់ ជីកប្រឡាយអីនេះ។ ខ្ញុំរកនឹកពាក្យបារាំងមិនឃើញ ពាក្យទំនប់នេះណ៎ា ការងារនេះពិបាកណាស់សម្រាប់មនុស្សធំ។ អ៊ីចឹងយើងចាប់ផ្ដើមនិយាយការងារស្រាលៗ ដល់ឥឡូវចូលដល់ការងារធ្ងន់ទៅវិញ គឺថាជីកប្រឡាយលើកទំនប់អីនេះការងារធ្ងន់។ ហើយថាក្មេងៗហ្នឹងរីកចម្រើនមានគោរពវិន័យ ហើយការប៉ិនប្រសប់ ហើយមិនល្ហើយ មិនខ្ជិលអ៊ីចឹង មិនច្រឡើសបើស មិនខូច។ អ៊ីចឹងបានន័យថាម៉េច គាត់ចង់និយាយថា អើ! គេឱ្យអាក្មេងៗអស់ហ្នឹងក្លាយជាគោ ជាក្របី ទៅបិទមាត់ទៅ អត់ហ៊ានតវ៉ាអីអ៊ីចឹងទៅ គោរពអង្គការ។ អ៊ីចឹងអានេះគួរឱ្យស្អប់ខ្ពើមដែរគំនិតបែបហ្នឹង។ ការងារកុមារហ្នឹងគេហាមឃាត់ គេមិនឱ្យធ្វើទេ <នៅក្នុងគ្រប់>អនុសញ្ញាអន្តរជាតិគេមិនឱ្យក្មេងៗធ្វើការងារបែបហ្នឹងទេ <ហើយនៅទីនេះពួកគេនិយាយថា កុមារសប្បាយនឹងធ្វើការ>។ អ៊ីចឹងដល់ពេលគាត់និយាយថា ក្មេងៗ ហ្នឹងផ្ដត់គំនិតគាត់ដូរ

ហើយ មានវិន័យ មានអីហ្នឹង ហើយចូលចិត្តការងារធ្ងន់ៗអីអ៊ីចឹង<>វាខុសស្រឡះតែម្តង ហើយជាការស្រមើស្រមៃមួយ។ <សម្រាប់ខ្ញុំ> នេះគឺជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតនៃរបបហ្នឹង ដែលថាគឺជាឧក្រិដ្ឋកម្មកម្ទេច<កុមារភាព>ចោល គឺថាក្មេងៗមិនអាចលេងបាន មិនអាចបង្កើតថ្មីបាន មិនអាចស្រមើស្រមៃបាននេះ។ វាបានន័យថា ដាក់ឲ្យគាត់ ឲ្យក្មេងៗទាំងអស់នោះឈឺចាប់ ស្ថិតនៅក្នុងវិន័យមួយតឹងរ៉ឹង។ ហើយយើងបើសិនជាមានក្មេងនៅទីនេះៗដែលនៅឆ្លងកាត់សម័យខ្មែរក្រហមនោះ សួរគាត់ទៅយើងដឹងហើយ។ <សម្រាប់កូនៗរបស់កម្មាភិបាលប្រាកដជាមានជីវិតងាយស្រួលជាងកុមារទូទៅ។>

[១៣:៥៥:១៤]

**ស៖** លោកបានសួរមនុស្សរាប់រយនាក់ រាប់ពាន់នាក់ឯណោះ សម្ភាស អ៊ីចឹងគាត់អង្កាល់សម័យខ្មែរក្រហមនោះ ប្រហែលគាត់ជាកុមារ ឬជាក្មេងជំទង់។ អ៊ីចឹងតើ<ពួកគេបាននិយាយប្រាប់លោកទេថា> ការងារដែលគេកំណត់ឲ្យពួកគាត់ធ្វើនោះ <>វាជះឥទ្ធិពលយ៉ាងម៉េចខ្លះទៅលើពួកគាត់នោះ? ហើយតាមរយៈការសម្ភាសរបស់លោកជាមួយប្រជាជនជាទូទៅនៅប្រទេសកម្ពុជានោះ តើលោកបានឮអ្វីខ្លះទាក់ទងនឹងឥទ្ធិពលដែលជះទៅលើកុមារៗ និងពួកក្មេងជំទង់នៅសម័យនោះ<ទេ>?

**ឆ៖** ការងាររបស់ខ្ញុំនោះ គឺផ្តោតទៅលើគុក។ ខ្ញុំព្យាយាមពិចារណាគិតពីបរិបទ <ដូច្នេះជាការពិតណាស់ ខ្ញុំបានចាប់អារម្មណ៍នឹងបរិស្ថាន។> ក៏ប៉ុន្តែឥទ្ធិពលផ្លូវចិត្តទាក់ទងទៅលើ<កុមារ ដែលគេបានធ្វើឲ្យខូចដល់>កុមារភាពហ្នឹង <ហើយ>ដែល<>តុលាការកំពូល<ទទួលស្គាល់ពីការខូចខាតកុមារភាពហ្នឹង ខ្ញុំមិនបានធ្វើការស្រាវជ្រាវលើបញ្ហានេះទេ។> ប៉ុន្តែ<ខ្ញុំអាចមើលឃើញថា> នៅក្នុងសង្គម<>ដែល<ពួកគេរស់នៅនោះ> មានការអំពើហិង្សានៅក្នុងគ្រួសារច្រើន ការលែងលះគ្នាហ្នឹងក៏ច្រើន។ ឥឡូវនេះយើងឃើញក្មេងកាលនោះវាធំហើយ អ៊ីចឹងកាលនោះគាត់រងទុក្ខខ្លាំងនៅសម័យខ្មែរក្រហម។ ដូចគេនិយាយគ្រប់គ្នាហើយ តែកាលណាយើងនៅតូចៗហ្នឹង ជីវិតយើងមានទុក្ខវេទនាច្រើន គឺពេលក្រោយមកគឺបើឥទ្ធិពលហ្នឹងវានៅតែមានរហូត។

[១៣:៥៧:០៨]

**ស៖** <សំណួរចុងក្រោយពាក់ព័ន្ធនឹង>សហករណ៍ បើតាមការស្រាវជ្រាវរបស់លោកគ្រប់ទិសទីនោះ តើមានរបៀបដំណើរការស្រដៀងគ្នាទាំងអស់នៅក្នុងទូទាំងប្រទេសតែម្តង ឬក៏ដំណើរការសហករណ៍នីមួយៗនេះ វាខុសគ្នា? ឧទាហរណ៍ដូចជាជីវភាពរស់នៅក៏ដោយ លក្ខខណ្ឌការងារក៏ដោយនោះ តើពីតំបន់មួយទៅតំបន់ ពីសហករណ៍មួយទៅសហករណ៍មួយនោះ មានលក្ខណៈខុសគ្នាទេ ឬក៏ដូចគ្នា

ទាំងអស់តែម្តង?

**ឆ៖** ទាក់ទងនឹងការចាត់ចែងទូទៅនោះ ខុសគ្នា -- ដូចគ្នា សូមទោស។ ការចេញបញ្ជាមកហ្នឹងគឺត្រូវធ្វើតាមទាំងអស់ គឺថាត្រូវធ្វើការច្រើនម៉ោង។ មានសាក្សីមួយចំនួននោះ គាត់បំផ្លើសដែរ ទាក់ទងរយៈពេលម៉ោងធ្វើការងារនេះ។ ក៏ប៉ុន្តែមានពេលមួយចំនួន គឺថាមុនពេលច្រូតកាត់ ពេលអីអ៊ីចឹង ឬក៏ពេលជិតធ្វើការដ្ឋានមួយចប់អ៊ីចឹង គឺថាត្រូវធ្វើការរហូតដល់១២, ១៣, ១៤, <១៦>ម៉ោង<> ក៏ប៉ុន្តែវាមិនអាចធ្វើការរបៀបហ្នឹងពេញមួយឆ្នាំនោះទេ <ព្រោះបើមិនដូច្នោះទេ ពួកគេនឹងស្លាប់។ វាមិនអាចទៅរួចទេ>។ ក៏ប៉ុន្តែទោះយ៉ាងណាក្តី <ពួកគេធ្វើការ>លើសប្រាំបីម៉ោងក្នុងមួយថ្ងៃ។ ក៏ប៉ុន្តែមានកន្លែងខ្លះជាករណីលើកលែងដែរ ពេលដែលខ្ញុំមើលកំណត់ត្រារបស់ខ្ញុំនៅលើភូមិភាគបូព៌ានោះ គឺមានដំណាំកៅស៊ូច្រើន។ ហើយនៅក្នុងចម្ការកៅស៊ូនោះ ការរស់នៅទីនោះសឹងតែធម្មតា គឺអ្នកធ្វើការនោះដែលចំនួនម៉ោងនោះធម្មតា ការធ្វើកៅស៊ូក្រេបនៅចម្ការជប់នោះធម្មតាដែរ មានអ្នកបច្ចេកទេសខ្មែរ ហើយចិនគាត់មកមើលម្តងម្កាល។ ហើយកៅស៊ូក្រេបហ្នឹង ដាក់ចូលឡានចិនទៅ ហើយបញ្ជូនមកលើកប៉ាល់តាមទន្លេមេគង្គ។ ហើយកៅស៊ូក្រេបទាំងអស់ហ្នឹង ដឹកតាមរទេះភ្លើងទៅកំពង់សោម ហើយក្រោយមកបន្តទៅប្រទេសចិន។ អ៊ីចឹងខ្ញុំមិនអាចឲ្យតួលេខបានទេ ប្រហែលជា១២.០០០ហិកតា <> នៅជប់ <ហើយ៨.០០០ នៅក្រោមរបបខ្មែរក្រហម។ តួនាទីរបស់ចម្ការភាគច្រើនគឺសឹងតែធម្មតា> ហើយដំណើរការទាំងអស់ ហើយលក្ខខណ្ឌជីវិតនោះត្រឹមត្រូវ បើអ្នកធ្វើការនៅទីនោះគឺហូបចុកគ្រប់គ្រាន់។ នេះគឺថាជីវភាពនៅទីនោះធម្មតា។

[១៣:៥៩:៥៨]

នៅក្នុងឯកសាររបស់ខ្ញុំចំណងជើងថា *"ខ្មែររូស ហ្គូឡាក់"* នៅសហករណ៍មួយ -- អ៊ំ! នៅកំពង់សោម នៅកំពង់ផែហ្នឹង គឺការរស់នៅដូចធម្មតា។ គេបញ្ជូនអ្នកជំនាញចិនទៅមើលនៅទីនោះ គេទៅកំសាន្តនៅឆ្នេរសមុទ្រអីជាដើម។ គេថា ដូចធម្មតា ការរស់នៅធម្មតា គេអាចទៅងូតទឹកបាន អ្នកបច្ចេកទេសដែលធ្វើការនៅកំពង់ផែនោះ មានជីវភាពគួរទទួលយកបាន។ ក៏ប៉ុន្តែយូរៗម្តង គេចាប់ដាក់គុកក៏មានដែរ។ ក៏ប៉ុន្តែជីវិតប្រចាំថ្ងៃនោះ ធម្មតាទេ។ ប៉ុន្តែទាក់ទងនឹងសហករណ៍ដាំដុះវិញ គឺច្បាប់ដូចគ្នា វិន័យដូចគ្នា ប៉ុន្តែភាពតឹងតែងនៃថ្នាក់ដឹកនាំវាខុសគ្នាពីឃុំមួយទៅឃុំមួយ។ បានន័យថា ការអនុវត្តវិន័យហ្នឹង វាខុសគ្នាពីកន្លែងមួយទៅកន្លែងមួយ គឺថានៅភូមិភាគបូព៌ាហ្នឹង វាងធូរជាងនៅភូមិភាគផ្សេងៗទៀត។ ខ្ញុំមិនគិតថាអ៊ីចឹងទេ ខ្ញុំគិតថា ប្រហែលជាតាមកន្លែងទេ ព្រោះថានៅភូមិភាគបូព៌ានេះ ក៏វា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មានអ្នកខ្លះអត់ឃ្លាន ស្លាប់នឹងអត់ឃ្លានដែរ។ ហើយមានគុកក៏ច្រើនដូចគ្នាដែរ។ <មានគុកមួយធំជាងគេបង្អស់>នៅភូមិភាគបូព៌ានេះ។ ក៏ប៉ុន្តែអ្វីដែលខុសគ្នានោះ គឺភាពសាហាវឃោរឃៅ ឬក៏ភាពតឹងរ៉ឹងរបស់ប្រធានសហករណ៍។<>នៅបាត់ដំបង<>មានសហករណ៍ខ្លះហ្នឹង គឺមនុស្សស្លាប់ដោយអត់ឃ្លាន ហើយសហករណ៍ក្បែរហ្នឹង ដោយប្រធានសហករណ៍ហ្នឹង គាត់ចិត្តទូលាយជាង គាត់មនុស្សធម៌ជាង គាត់ឲ្យប្រជាជនហូបចុកគ្រប់គ្រាន់ទៅ។ មានបារាំងម្នាក់ឈ្មោះ សោមនស្ស ស ឈ្មោះនោះប្រហាក់ប្រហែលអ៊ីចឹងហើយ ខ្ញុំភ្លេចហើយ។ កាលនោះគាត់ជាក្មេងជំទង់នៅរបបខ្មែរក្រហមនោះ ឪពុកម្តាយគាត់ស្លាប់អស់ហើយ ដោយសារគាត់មិនមានអាហារហូបចុកគ្រប់គ្រាន់ ហើយគាត់ទៅនៅសហករណ៍ផ្សេងទៀតទៅ លួចរត់ទៅៗ ដោយសារគាត់នៅក្មេង គេមិនសូវប្រកាន់ អ៊ីចឹងគាត់រស់ដល់សព្វថ្ងៃទៅ។ អ៊ីចឹងការអនុវត្តវិន័យដែលកំណត់មកហ្នឹង វាខុសគ្នា។ បើថាប្រធាន -- ប៉ុន្តែជួនកាលប្រធានសហករណ៍ដែលចិត្តល្អពេកទៅ គេចោទថា គាត់ក្បត់ ហើយក្រោយមក គេចាប់គាត់ទៅដាក់គុកវិញទៅ។

[១៤:០២:៤១]

**ស៖** ឥឡូវខ្ញុំសូមចូលមកនិយាយពីតួនាទី នួន ជា វិញម្តង។ តើលោកធ្លាប់ជួប នួន ជា ហើយមានសម្ភាសគាត់ដោយផ្ទាល់ដែរឬទេ?

**ឆ៖** អត់ទេ។ ដូចដែលលោកដឹងហើយ នួន ជា មិនដែលចង់ឲ្យអ្នកណាសម្ភាសគាត់ទេ។ ថេត សម្បត្តិ ហ្នឹងគឺករណីលើកលែងហើយ។ ទី១ គាត់ជាជនជាតិខ្មែរ ហើយគាត់ទៅណែនាំឲ្យស្គាល់ ទម្រាំតែ <នួន ជា ទុកចិត្ត>ហ្នឹង គាត់ចំណាយ<ពេល>រាប់<ខែ>ឯណោះ ដើម្បីឲ្យ នួន ជា ទុកចិត្តគាត់នោះ។ អ៊ីចឹងសឹងតែគ្មានអ្នកណាអាចសម្ភាសគាត់បានទេ សូម្បីតែ ហ្វីលីព ស្សូត ហ្នឹងក៏មិនបានសម្ភាសគាត់ដែរ។ ដោយសារគាត់បានសិក្សានៅសាលាបឋមសិក្សា ហើយនិងនៅសាកលវិទ្យាល័យនៅប្រទេសថៃ នួន ជា នេះនិយាយថៃច្បាស់ណាស់។ ខ្ញុំគិតថា មានអ្នកសម្ភាសគាត់ជាភាសាថៃ។ ក៏ប៉ុន្តែដូចខ្ញុំបានលើកឡើងអ៊ីចឹង គឺថាខ្ញុំបានសម្ភាស ខៀវ សំផន ពេញមួយថ្ងៃ ហើយគាត់ទទួលខ្ញុំដោយរួសរាយរាក់ទាក់ ហើយខ្ញុំសង្កេតឃើញថា ផ្ទះគាត់ហ្នឹង គឺផ្ទះមិនជាអ្នកមានទ្រព្យសម្បត្តិអីច្រើនទេ។ ឃើញថា ខៀវ សំផន មិនបានឆ្លៀតឱកាសកេងប្រវ័ញ្ច<ពី>សម័យខ្មែរក្រហម<ដើម្បីក្លាយជាអ្នកមាន>នោះទេ។ <ដូច្នេះ អ្វីដែលគាត់ប្រាប់ខ្ញុំ គឺដូចគ្នាទាំងស្រុងទៅនឹងអ្វីដែលគាត់ប្រាប់ ហ្វីលីព ស្សូតដែរ។> ខ្ញុំនៅចាំដែរ គឺថាគាត់បាននិយាយថា យើងបានជម្លៀសមនុស្សចេញពីទីក្រុងនោះ ព្រោះថាវាជាការចាំបាច់ ត្រូវធ្វើយ៉ាងម៉េចចូលទៅកាន់លទ្ធិកុម្មុយនីស្តឲ្យលឿន កុំឲ្យវៀតណាមដើរលឿនជាងយើង។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក៏ប៉ុន្តែ ខៀវ សំផន គាត់កាលណោះ គាត់ទទួលខ្ញុំដោយគួរសមណាស់ ហើយគាត់និយាយភាសាបារាំងនោះ ល្អណាស់។

[១៤:០៥:០០]

**សៈ** ខ្ញុំនឹងត្រឡប់មកនិយាយពីចំណុចនេះ ម្តងទៀត។ ប៉ុន្តែឥឡូវទាក់ទងនឹង នួន ជា តើនៅក្នុងអតីតកាល ទោះបីនៅប្រទេសកម្ពុជាក៏ដោយ នៅប្រទេសថៃក៏ដោយ នៅពេលដែលគាត់សិក្សានៅទីនោះ ឬក៏នៅពេលដែលគាត់រៀនសូត្រនៅប្រទេសវៀតណាម តើមានកត្តាអ្វីខ្លះដែល<អាចផ្តល់ដល់ទស្សន-វិស័យ ឬភាព>ជាអ្នកដឹកនាំ<របស់គាត់ ក្នុងការ>កាន់អំណាច <ដូចដែល>គាត់កាន់អំណាច<>នៅសម័យខ្មែរក្រហមនោះ កម្ពុជាប្រជាធិបតេយ្យនោះ? តើមានចំណុចណា ឬក៏កត្តាណាមួយ<នៅក្នុងប្រវត្តិផ្ទាល់ខ្លួនរបស់គាត់> ដែលអាចឲ្យលោកសន្និដ្ឋានថា គាត់កាន់អំណាច របៀបដែលគាត់កាន់អំណាចនៅសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង ដោយសារគាត់ទទួលឥទ្ធិពលពីវៀតណាម ពីថៃ ពីកន្លែងណាផ្សេង លោកមានមតិយោបល់អីទេ?

**ផៈ** បាទ នេះជាចំណុចមួយគួរឲ្យឆ្ងល់ណាស់។ យើងមានឯកសារមួយដែលធ្វើដោយជនជាតិជប៉ុន ខ្ញុំភ្លេចឈ្មោះហើយ។ គាត់ហ្នឹង គាត់បានកំណត់ប្រវត្តិ នួន ជា នៅប្រទេសថៃ ហើយនិងឈ្មោះផ្សេងៗដែលគាត់បានប្រើ គឺជាមនុស្សដែលចេះលាក់ខ្លួន។ យើងពិបាករកដានរបស់គាត់ណាស់នៅប្រទេសថៃនោះ។ អ៊ីចឹងហើយដល់មានជនជាតិជប៉ុនម្នាក់ដែលបានរកឈ្មោះគាត់នៅស្រុកថៃហ្នឹង ឃើញគាត់ដូរឈ្មោះច្រើនដង។ ហើយមានចំណុចមួយទៀត គួរឲ្យចាប់អារម្មណ៍ដែរគឺថា យើងដឹងប្រវត្តិនិស្សិតម្នាក់ដែលទៅរៀនពូកែ ហើយនៅក្នុងចំណោមនោះគឺគាត់រៀនបានដល់ជិតបរិញ្ញាប័ត្រច្បាប់ផងកាលនោះ។ ហើយបើ ប៉ុល ពត នោះគ្រាន់តែជាងឈើ ជាងផ្ទះប៉ុណ្ណឹងទេ។ ហើយចូលទៅប្រទេសបារាំងនោះ គឺចូលបក្សកុម្មុយនីស្តបារាំងនោះ មិនជាអស្ចារ្យអីទេ។ ហើយ នួន ជា រៀននៅសាកលវិទ្យាល័យធម្មសាតនោះ ហើយបើឥឡូវនេះ យើងនិយាយថា ជាសាកលវិទ្យាល័យសម្រាប់ពួកឆ្វេងនិយម វាខុសពីសាកលវិទ្យាល័យជូឡាឡុងកន ដែលមាន<លក្ខណ:ប្រពៃណី>។ <ហើយសាកលវិទ្យាល័យធម្មសាតនោះ មានគំនិតទំនើបនិយមជាច្រើន ដើម្បីជួយដល់ការទាមទារឯករាជ្យពីប្រទេសអាណានិគម។ យើងសឹងតែមិនជឿថា គាត់បានចូលបក្ស ប៉ុន្តែគាត់បានចូល>យុវជនកុម្មុយនីស្ត<>។

[១៤:០៧:៥៣]

<នៅក្នុងការសិក្សារបស់ជនជាតិជប៉ុននេះឃើញថា មិនមានអ្វីទាំងអស់នៅក្នុង>ប្រវត្តិរបស់

នួន ជា នៅប្រទេសថៃនោះ <ដែលអាច>ឲ្យយើងសន្និដ្ឋានថា គាត់អាចក្លាយជាអ្នកដឹកនាំនៅកម្ពុជាប្រជាធិបតេយ្យនោះទេ។ ក៏ប៉ុន្តែអ្វីដែលគួរឲ្យចាប់អារម្មណ៍នៅក្នុងប្រវត្តិរបស់គាត់នោះ គឺថា ការសិក្សារបស់គាត់នៅប្រទេសថៃនោះ ជាជោគជ័យមួយ គាត់មានការងារធ្វើនៅក្រសួង។ ពីដំបូងនៅក្រសួងហិរញ្ញវត្ថុ ហើយក្រោយមកក្រសួងការបរទេសទៀត។ <សម្រាប់យុវជនដែលមានមហិច្ឆតាម្នាក់ទោះបីជា>គាត់<ស្ថិតនៅលំដាប់ទាបនៅក្នុងសង្គមក៏ដោយ ក៏>គាត់ទទួលបានសញ្ជាតិថៃ ហើយ<គេចាត់ទុក>គាត់<ថាជាជនជាតិថៃ ដោយសារគាត់នៅបាត់ដំបង> នៅពេលដែលភាគ<ពាយ័ព្យ>នៃប្រទេសកម្ពុជាហ្នឹង បានបញ្ចូលទៅប្រទេសថៃទាំងអស់។ អ៊ីចឹងនៅបាត់ដំបង ក៏ធ្វើជាខេត្តរបស់ថៃ ខ្មែរបន្ទាយមានជ័យនោះក៏ថៃ។ <ដូច្នេះប្រជាជនទាំងអស់នៅបាត់ដំបង បានក្លាយជាជនជាតិថៃដោយស្វ័យប្រវត្តិ។> អ៊ីចឹងគាត់អង្កាល់នោះ បើយើងគិតឲ្យមែនទែនទៅ បើយើងនិយាយលេងទៅថាប្រហែលជាកាលនោះ មិនស្រួលគាត់ចង់ធ្វើជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុថៃផងក៏មិនដឹង។ តែ<ទោះជាយ៉ាងណា វាជាការចាប់ផ្តើមនៃអាជីពដ៏មានកិត្តិយសមួយ ហើយគាត់ខ្វះតែវគ្គសិក្សាខ្លីៗមួយមុខពីរប៉ុណ្ណោះដើម្បីបញ្ចប់ការសិក្សារបស់គាត់។ តែគាត់មិនបានបញ្ចប់ទេ។> កាលសម័យនោះ គឺក្រោយសង្គ្រាមលោកលើកទី២បន្តិច គឺជាការចាប់ផ្តើមសង្គ្រាមត្រជាក់ គេតស៊ូដើម្បីឯករាជ្យអឺជាដើមហ្នឹង។ អ៊ីចឹង នួន ជា កាលគាត់នៅក្មេងហ្នឹង គាត់បាន និយាយទៅគាត់នៅប្រទេសថៃដូចគេដូចឯង ហើយគាត់ក៏ចង់ចូលរួមតស៊ូដើម្បីដណ្តើមយកឯករាជ្យភាពមកប្រទេសកម្ពុជាវិញ។ អ៊ីចឹងគាត់ជាបញ្ញវន្តមួយដែរ គាត់និយាយខ្មែរ ហើយថៃផង ហើយគាត់មានចំណេះដឹងខ្លះដែរខាងភាសាបារាំង។ គាត់រៀននៅសាលាបឋមសិក្សា ឬក៏អនុវិទ្យាល័យអឺជាដើមនោះ។ ដូច្នេះគាត់ជាអ្នកឆ្លាត ហើយកាលនោះវៀតមិញដែលគ្រប់គ្រងបក្សកុម្មុយនីស្តឥណ្ឌូចិនហ្នឹង ក៏បញ្ជូនគាត់ទៅវៀតណាម ហើយគាត់រៀននៅទីនោះពីរឆ្នាំកន្លះពេលនោះគាត់រៀន<ភាសា>វៀតណាមនៅទីនោះ<ដែរ>។ អ៊ីចឹងជាមនុស្សឆ្លាត នួន ជា នេះ។ ដោយហេតុថា គាត់ចេះពីរភាសាច្បាស់ហើយ ១ចូលដល់បីភាសាហើយ។ អ៊ីចឹងគាត់ចេះបារាំងថែមទៀត។ អ៊ីចឹងវាចង់ចូលបួនហើយ។

[១៤:១០:៣៦]

អ៊ីចឹងដោយសារគាត់ចេះវៀតណាមនេះ គឺធ្វើឲ្យគាត់អាចទៅទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកដឹកនាំវៀតណាមគឺដូចជា ឡេ យន់ អឺជាដើមហ្នឹង ហើយធ្វើឲ្យអ្នកដឹកនាំវៀតណាមនោះទុកចិត្តគាត់។ អ៊ីចឹងគេចាត់ទុកគាត់ជាមនុស្សរបស់វៀតមិញ។ ប៉ុន្តែអាថ៌កំបាំងមួយទៀតគឺថា នួន ជា កាលដែលគាត់

នៅប្រទេសថៃនោះ គាត់<តែងតែទៅ>វត្ត<> នៅវត្តមួយឈ្មោះ ដូចវត្តម៉ាបមិនដឹង អីមិនដឹង។ គាត់រស់នៅទីនោះ ដូចជាបីបួនប្រាំឆ្នាំ ប្រាំពីរឆ្នាំអីនោះ នៅក្នុងវត្តហ្នឹង។ អ៊ីចឹងយើងគួរ កាលនោះគួរតែយើងអាចសន្និដ្ឋានថា គាត់ហ្នឹងចេះវប្បធម៌ព្រះពុទ្ធសាសនាហ្នឹងច្បាស់ណាស់។ ស្ទីវិន ហេដឌ័រ គាត់បានទៅផ្ទះ នួន ជា នោះ។ គាត់បានរៀបរាប់ថា នៅផ្ទះ នួន ជា សម្បូរសៀវភៅព្រះពុទ្ធសាសនាណាស់។ ឥឡូវនេះ នួន ជា គាត់ចាស់ហើយហ្នឹង អ៊ីចឹងគាត់ត្រឡប់មកកាន់សាសនាព្រះពុទ្ធវិញ។ អ៊ីចឹងមានសៀវភៅជាភាសាថៃផង និយាយពីពុទ្ធសាសនានេះ។ អ៊ីចឹងជាមនុស្សមួយគួរឲ្យឆ្ងល់ដែរ នួន ជា នេះ។ អ៊ីចឹងបើថា កាលសម័យនោះ លោកសង្ឃរស់នៅធម្មតា គាត់មានអីសព្វបែបយ៉ាង។ លោកសង្ឃឥឡូវនេះក៏គាត់រស់<ក្នុងភាពប្រណិត>មានតាំងពីទូរស័ព្ទ <មានឡានទំនើប និងនាឡិកាល្អៗជាដើម ខណៈដែលគេគិតថា លោកសង្ឃក្រគ្មានអ្វីទាំងអស់ មិនប៉ះពាល់លុយ ប៉ុន្តែនៅពេលនេះ បើតាមព័ត៌មានថា លោកសង្ឃមានទាំងប៉ះពាល់ផ្លូវភេទទៀតផង>។ ហើយកាលសម័យពីមុននោះ គឺអត់មានទេ កាលសម័យ នួន ជា នោះ គឺថាអត់មានអ្វីទាំងអស់ រស់នៅដោយលះបង់សព្វបែបយ៉ាង។ ប្រហែលជាគាត់ឃើញ កាលគាត់នៅក្មេងនោះថា មានលោកសង្ឃមួយចំនួនប្រព្រឹត្តខុសអីអ៊ីចឹងទៅ គាត់ក៏ចង់កែ ពេលដែលគាត់ឡើងកាន់អំណាចក៏ថាបាន។

**ស៖** តើគាត់អាចបង្កើតគោលនយោបាយ<>ពឹងផ្អែកទៅលើហិង្សា<>ប្រដាប់អាវុធនេះ<យ៉ាងម៉េច ហើយនៅកន្លែងណា>?

[១៤:១៣:១០]

**ឆ៖** គឺតាមរយៈវៀតមិញ។ បច្ចេកទេសសង្គ្រាមឈ្លបអីជាដើមអស់ហ្នឹង គឺសុទ្ធតែដកស្រង់ចេញមកពីខាងវៀតមិញហើយ ការប្រព្រឹត្តចំពោះឈ្លើយសឹក ឬក៏អ្នកទោសនយោបាយ ឬយ៉ាងម៉េចហ្នឹង។ គេដាក់ខ្នោះ គេសួរចម្លើយ សួរអីហ្នឹង គឺគេអនុវត្តតាមគំរូរបស់ពួកវៀតមិញហើយ។ យើងឃើញហើយថា មានជនជាតិបារាំងដែលជាឈ្លើយសឹករបស់ពួកវៀតមិញ ត្រូវបានគេដាក់ខ្នោះ គេវាយធ្វើទារុណកម្ម ហើយអ្នកខ្លះក៏ស្លាប់ទៅ។ ដូច្នេះគាត់រៀនបច្ចេកទេសហ្នឹងហើយពីពួកកុម្មុយនីស្តពិតប្រាកដនោះ គឺរៀនពីពួកវៀតមិញហ្នឹងហើយ។ ហើយបក្សកុម្មុយនីស្តកម្ពុជាបាននិយាយថា “យើង<ជ្រើសរើស>មាគ៌ា<ស្របច្បាប់ និងមិនស្របច្បាប់”។ មាគ៌ាស្របច្បាប់ គឺបក្ស>ប្រជាជន <ហើយមាគ៌ាមិនស្របច្បាប់គឺ>ប្រើប្រាស់អំពើហិង្សា <ហើយពួកគេបានជ្រើសរើសមធ្យោបាយហិង្សាតាំងពីដំបូង។ ប៉ុន្តែខ្ញុំគិតថា កាលនោះគឺនៅក្រោមការទំនុកបម្រុងរបស់>បក្សកុម្មុយនីស្តវៀតណាម។

**ស៖** មុននេះលោកបាននិយាយថា ប៉ុល ពត និង នួន ជា ជាអ្នកសម្រេចរួមគ្នា។ ហើយក្នុងសៀវភៅរបស់លោកហ្នឹង លោកនិយាយអំពីពស់ក្បាលពីរ។ តើវិស័យអីខ្លះដែលស្ថិតនៅក្រោមកណ្ដាប់ដៃរបស់ នួន ជា តែមិននៅក្រោមកណ្ដាប់ដៃ ប៉ុល ពត នោះ? ខ្ញុំចង់សំដៅទៅលើវិស័យអីខ្លះដែល នួន ជា គាត់គ្រប់គ្រងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** មានចំណុចជាច្រើនដែលយើងដឹង ហើយចំណុចខ្លះហ្នឹងក៏វាមិនសូវច្បាស់ដែរ។ ទី១ គឺគាត់ទទួលខុសត្រូវខាងអប់រំបណ្ដុះបណ្ដាលកម្មាភិបាលដែលយើងហៅថា <អង្គការ>។ យើងឃើញហើយចាប់ពីមករា ៧៦ ទៅ គឺយើងមានរដ្ឋធម្មនុញ្ញ មានការ<បង្កើតរដ្ឋសភា> ហើយ<>គាត់ក្លាយទៅជាប្រធានសភាព។

[១៤:១៥:៣០]

ប្រសិនបើយើងពិនិត្យមើលមុខងារពិតប្រាកដជាផ្លូវការរបស់គាត់នោះ គឺដូចជាមិន<ច្រើន>ទេ។ ក៏ប៉ុន្តែចំណុចនេះហើយ ដែលខ្ញុំបានពិភាក្សាគ្នាជាមួយ សួង ស៊ីគឿន ហើយចំណុចនេះសំខាន់ណាស់។ ខ្ញុំក៏ពិភាក្សាជាមួយ ភី ភួន, សាឡុត បាន ឬក៏ខ្មែរក្រហមមួយចំនួន។ យើងបានរៀបរាប់អំពីកម្ពុជាប្រជាធិបតេយ្យតាមរបៀបយើង យើងមើលឃើញអំពីការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យយើងឃើញហើយ មានរដ្ឋមន្ត្រីក្រសួងនេះ ក្រសួងនោះ តែអត់មានរដ្ឋមន្ត្រីក្រសួងសង្គ្រាមទេ។ ហើយនៅសម័យនោះ យើងឃើញហើយ គឺថាអ្វីដែលសំខាន់នោះ គឺជាការបង្កើនស្បៀង ការឧបត្ថម្ភស្បៀង។

ឌុច បានពន្យល់ហើយ <កាលពីខែមិថុនាកន្លងមកនេះ គឺមុនសវនាការនេះ ហើយខ្ញុំគិតថា គាត់និយាយត្រូវ គឺវាពិបាកដឹង>ថា អ្នកណាជាបងធំទី១, បងធំទី២, បងធំទី៣, ៤, ៥, ៦, ៧, ៨ <> គ្មានអ្នកណាដឹងទេ គឺមានការប្រែប្រួលរហូត គឺផែនការហ្នឹង គឺដូរទិសដៅរហូត។ យើងមើលហើយ ឃើញថា បើតាមតួនាទីហ្នឹង នួន ជា ដូចជាមិនមានអីសំខាន់ទេ នៅក្នុងរដ្ឋាភិបាល កម្ពុជាប្រជាធិបតេយ្យហ្នឹង ក៏ប៉ុន្តែបើជាក់ស្ដែងវិញនោះ យើងឃើញថា យើងឃើញហើយគាត់នៅក-៣ រហូតជាមួយ ប៉ុល ពត ពីមុននោះ។ គាត់នៅមន្ទីរក-៣ នៅក្បែរ ប៉ុល ពត។ គាត់ហូបបាយហូបទឹកអីហ្នឹងជាមួយ ប៉ុល ពត រួមគ្នា។ ខ្ញុំមិនចាំច្បាស់ប៉ុន្មានដែរ ក៏ប៉ុន្តែយើងដឹងហើយថា ប៉ុល ពត និង នួន ជា ហ្នឹងហូបបាយជាមួយគ្នាទទួលទានអាហារជាមួយគ្នា ហើយជួនកាលទៅ ខៀវ សំផន ក៏ទៅរួមតុជាមួយពួកគាត់ទៀត។ ដូច្នេះពួកគេហ្នឹងហើយ ជាអ្នកសម្រេចរួមក្នុងទិដ្ឋភាពជាក់ស្ដែងនោះ <មិនបាច់គិតពីតួនាទីជាក់ស្ដែងរបស់ពួកគេ>នៅក្នុងក្រដាស<ទេ។ ការទទួលខុសត្រូវមានតែក្នុងក្រដាសប៉ុណ្ណោះ។> ក៏ប៉ុន្តែបើតាមការពិត

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជាក់ស្ដែង គឺវា<ដូច> ស្នួង ស៊ីគឿន <បានពន្យល់ខ្ញុំអ៊ីចឹង> នៅក្រសួងការបរទេស គាត់<>ទទួលខុសត្រូវខាងឃោសនាការ នៅតាមវិទ្យុជាដើមនេះ ក៏ប៉ុន្តែបើជាក់ស្ដែងទៅមិនមែនអ៊ីចឹងទេ គឺ<មានការងារបន្ទាន់ ដែលត្រូវធ្វើឲ្យបានសម្រេច ហើយគ្រប់ៗគ្នាមានការងារចម្រុះ។ គ្រប់ៗគ្នាធ្វើអ្វីដែលត្រូវធ្វើឲ្យបានសម្រេច។ ពួកគេ>ធ្វើការងារច្រើនតែជាបន្ទាន់ៗ ហើយប្រថុចប្រញ៉ុចទៅទៀត។ <>

[១៤:១៨:០៩]

**ស៖** នៅក្នុងសៀវភៅរបស់លោក *"ពូត័រ ឡេ ខ្មែររូស៍"* ឯកសារ E3/10640 គឺផ្នែកដែលមានចំណងជើងថា "អង្គការ" ទំព័រ១០៥ លោកបាននិយាយដូចតទៅ៖ "នួន ជា និង ប៉ុល ពត គឺជាវាគ្មិនដ៏សំខាន់នៃរបបនោះ។ ជាពិសេស នួន ជា ជាអ្នកទទួលខុសត្រូវផ្នែកសន្តិសុខនៃរដ្ឋបដិវត្តន៍ គាត់ទទួលបន្ទុកក្នុងការស្វែងរកខ្មាំង និងជនផ្សំគំនិត។" ដូច្នេះពាក់ព័ន្ធនឹងតួនាទីរបស់ នួន ជា នៅក្នុងវិស័យសន្តិសុខរដ្ឋនេះ ខ្ញុំចង់ដឹងថា លោកមានប្រភពអ្វីខ្លះ? តើលោកមានបានជួបកម្មាភិបាលដូចជា ស្នួង ស៊ីគឿន, សាឡុត បាន, ភី ភួន ពួកគាត់មានបានផ្ដល់ព័ត៌មានអីជូនលោកខ្លះ បន្ថែមពីលើប្រភពផ្សេងទៀតដែលកបានប្រមូលផ្ដុំ ឬក៏បានពិគ្រោះយោបល់នោះ?

**ឆ៖** ប្រភពសំខាន់ពីរ ខ្ញុំអាចនិយាយថាបីផង គឺទី១ ឌុច, ទី២ គឺ <ជួន> សម្បត្តិ ហើយទី៣ គឺ នួន ជា ផ្ទាល់តែម្ដង។ នៅក្នុងបទសម្ភាសន៍របស់ នួន ជា ជូនបក្សកុម្មុយនីស្ដដាណឺម៉ាក នៅឆ្នាំ៧៨ ហើយដែលខ្ញុំមាននៅក្នុងកំណត់ត្រារបស់ខ្ញុំដែរ ហើយខ្ញុំជឿថា តុលាការក៏មានបទសម្ភាសន៍ហ្នឹងដែរ។ ពេលនុ៎ងហើយគាត់ថា ការប្រមាញ់រកខ្មាំងហ្នឹង គឺជាភារកិច្ចចម្បងរបស់បក្ស។ គាត់រៀបរាប់ពីតួនាទីរបស់គាត់ក្នុងការតាមដានស្វែងរកខ្មាំង។ អ៊ីចឹងខ្ញុំចង់ដឹងថា តើតុលាការមានអត្ថបទហ្នឹងឬក៏អត់ អារអត្ថបទសម្ភាសហ្នឹង? ឡូរ៉ា សាំម័រ បានផ្ដល់ឯកសារហ្នឹងឲ្យខ្ញុំ គាត់ជាជនជាតិអង់គ្លេស គាត់ជាអ្នកជំនាញខាងសំណេរ គាត់សរសេរពីកម្ពុជាប្រជាធិបតេយ្យច្រើនណាស់។ ហើយបោះពុម្ពនៅក្នុងខែមីនា <១៩៨៧> នៅក្នុងអត្ថបទរបស់ ឡូរ៉ា សាំម័រ ហ្នឹង។ ហើយបន្ទាប់មកមានអត្ថបទសម្ភាសរបស់ នួន ជា លោកព្រះរាជអាជ្ញាលោកគួរតែមានហើយ ឯកសារទាំងអស់ហ្នឹង។ ខ្ញុំគិតថាក្នុងសំណុំរឿងតុលាការប្រាកដជាមានឯកសារទាំងអស់ហ្នឹងហើយ ខ្ញុំមិនចាំបាច់ដកស្រង់អីបន្ថែមទេ លោកមានឯកសារហ្នឹងអស់ហើយ។

[១៤:២១:០៩]

**ស៖** បើលោកមានអត្ថបទដកស្រង់អាចល្អដែរ។

**ឆ៖** បាទ សូមទោសផង ជាភាសាអង់គ្លេស អ៊ីចឹងសូមប្រាប់អ្នកបកប្រែផងថា ខ្ញុំនឹងអានជាភាសាអង់គ្លេស។ "វៀតណាមព្យាយាមជ្រៀតចូលទៅក្នុងបក្សរបស់យើងផងដែរ។ យើងមិនបារម្ភអំពីការឈ្លានពានពីខាងក្រៅនោះទេ យើងបារម្ភអំពីខ្មាំងផ្ទៃក្នុង។ សំណួរ៖ ហេតុអ្វីបានជាការងារ<ខុស>ច្បាប់ហ្នឹង <នៅតែ>ជា<>ការងារ<ចម្បង ការងារគ្រឹះ>? <ក្នុងរយៈពេលនេះ> គឺថាក្រោយការរំដោះគឺ យើងត្រូវផ្អែកទៅលើការសម្ងាត់ <នេះជាគោលការណ៍សំខាន់។> យើង<លែង>ប្រើប្រាស់ពាក្យស្របច្បាប់ ឬមិនស្របច្បាប់<ទៀតហើយ> គឺយើងប្រើប្រាស់ពាក្យសម្ងាត់ ឬក៏បើកចំហ។ ការងារសម្ងាត់ គឺជាការងារមូលដ្ឋានដែលយើងត្រូវធ្វើទាំងអស់។ ឧទាហរណ៍ ការជិតបោះឆ្នោតជ្រើសរើសកម្មាភិបាលជាដើមនោះ គឺជាការសម្ងាត់។ កន្លែងដែលមេដឹកនាំរស់នៅក៏សម្ងាត់។ យើងរក្សាការសម្ងាត់សម្រាប់ការប្រជុំ ក៏ដូចជាទីកន្លែងនិងម៉ោង។ <ម្យ៉ាង នេះគឺជាបញ្ហាវិន័យ ម្យ៉ាងវាជាបញ្ហា>ការពារខ្លួនយើងពីគ្រោះថ្នាក់របស់ខ្មាំងដែលជ្រៀតចូលផ្ទៃក្នុង។ ទោះបីថាជាការតស៊ូវណ្ណៈ ក៏ដូចជាការប្រឆាំងអាណានិគម។ ទាំងចំពោះការតស៊ូវណ្ណៈ ក៏ដូចជាសក្តិភូមិនិយម យើងត្រូវតែមានការរក្សាការសម្ងាត់។ មានតែការសម្ងាត់ទេ ទើបធ្វើឲ្យយើងអាចគ្រប់គ្រងម្ចាស់ការលើស្ថានការណ៍ ក៏ដូចជ័យជម្នះនិងលើខ្មាំងដែលមិនដឹងថាតើអ្នកណាជាអ្នកណានោះ។"

[១៤:២៣:២០]

**ស៖** ក្រៅពីតួនាទីដែលលោកបានរៀបរាប់ ដូចជាអប់រំ ឃោសនាការ សន្តិសុខ និងជាប្រធានសភាប្រជាជននោះ។ តើគាត់មានតួនាទីជំនួស ប៉ុល ពត នៅពេលដែល ប៉ុល ពត អវត្តមាន ឬក៏ ប៉ុល ពត ឈឺ?

**ឆ៖** <ជាការពិត មាន>ប្រភពសំខាន់មួយ<នៅទីនេះ> ដែលបញ្ជាក់អំពីតួនាទីពិតប្រាកដរបស់ នួន ជា។ ខ្ញុំដូចជាភ្លេចហើយ មិនដឹងថាចុង៧៦ ឬក៏ដើម៧៧ ឬក៏យ៉ាងម៉េចទេ ដែលពេលនុ៎ង ប៉ុល ពត គាត់មានធុរៈ ហើយ នួន ជា ហ្នឹងកាន់តំណែងជាស្វ័យប្រវត្តិតែម្តង ជានាយករដ្ឋមន្ត្រី ជំនួសឲ្យ ប៉ុល ពត។ <ប៉ុន្តែតាមការពិត គឺមានការផ្លាស់វេនគ្នាជាទៀងទាត់។> អ៊ីចឹងគេមានការរៀបចំធ្វើម៉េចដើម្បីកុំឲ្យនៅរួមគ្នាក្នុងឱកាសណាមួយ ដើម្បីឲ្យថា នៅពេលដែល ប៉ុល ពត ទៅប្រជុំ ឬក៏ពេលដែល ប៉ុល ពត ទៅទស្សនកិច្ចនៅចិន ឬក៏ពេលដែល ប៉ុល ពត ទទួលភ្ញៀវអីមួយអ៊ីចឹង គឺ នួន ជា ជាអ្នកកាន់តំណែង កាន់អំណាចទាំងស្រុងនៅភ្នំពេញ។ ឧទាហរណ៍ ដូចជាពេល ហ្សាង ជុនកែវ ដែលជាមេក្រុមជើងកាងទាំងបួន មកកាលពីខែមករា ឆ្នាំ៧៦នោះ យើងឃើញនៅក្នុងរូបថតហ្នឹងមាន ប៉ុល ពត

ហើយនិងមនុស្សមួយចំនួនទៀត គឺអត់មាន នួន ជា ទេ។ ហើយនៅពេលដែល ណោរិន ជាប្រមុខរដ្ឋទី១ ដែលមកកម្ពុជាហ្នឹងមានលោក ខៀវ សំផន ប៉ុន្តែអត់មាន ប៉ុល ពត ទេ។ ពេលនុ៎ងមាន ខៀវ សំផន ជាប្រមុខរដ្ឋ ហើយក៏អត់មាន នួន ជា ដែរ។ នៅពេលដែល សីហនុ សម្តេច សីហនុ មកទស្សនកិច្ចនៅក្នុងម៉ាគី នៅឆ្នាំ៧៣ហ្នឹង យើងត្រូវមើលរូបថត បើតាមខ្ញុំចាំ គឺយើងឃើញមានមេដឹកនាំខ្មែរក្រហមធំៗទាំងអស់ លើកលែងតែ នួន ជា ទេ ពេលនុ៎ង។ អ៊ីចឹង នួន ជា ហ្នឹងគឺជាអ្នកនៅកាន់អំណាច នៅពេលដែល ប៉ុល ពត ជាប់រវល់ ហើយនិងនៅពេលដែល ដូចជាមនុស្សបីផ្សេងទៀត ដូចជាខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ ទៅទទួលស្តេចជាដើមនោះ។ អ៊ីចឹងយើងគិតទៅដូចគាត់ជាឧបរាជអ៊ីចឹង ឧបរាជ គឺគាត់ដូចជាឧបរាជ គឺដូចជាអ្នកអនាគតស្តេច។ ខ្ញុំអាចនិយាយថា គាត់គឺឧបរាជ គឺអ្នកទី២ ហើយបន្ទាប់ពីស្តេច។

[១៤:២៦:២២]

**ស៖** ខ្ញុំចង់ដកស្រង់ពាក់ព័ន្ធទៅនឹង នួន ជា គឺនៅថ្ងៃចុងក្រោយនៃរបបខ្មែរក្រហម មុនពេលវៀតណាមចូលមក គឺដកស្រង់ចេញពីសៀវភៅរបស់ *"ពួគ័រ ឡេ ខ្មែររូស៍"* ទំព័រ២៤០ ជាភាសាបារាំង គឺ ERN ជាភាសាបារាំង 01303654។ លោកបានសរសេរដូចតទៅ ខ្ញុំសូមដកស្រង់៖ "នៅប៉ុន្មានថ្ងៃចុងក្រោយនៃរបបខ្មែរក្រហម គឺនៅថ្ងៃដំបូងៗនៃខែមករា ឆ្នាំ១៩៧៩នេះ គឺជាពេលវេលាសម្លាប់មនុស្សច្រើនបំផុត។ មានការចេញបញ្ជាពីមេដឹកនាំធំៗ ដូចជា នួន ជា ជាដើម ក្នុងការសម្លាប់ចោលទាំងអស់អ្នកដែលត្រូវបានឃុំខ្លួននៅតាមគុកនីមួយៗនៅប្រទេសកម្ពុជា គឺដើម្បីកុំឲ្យវៀតណាមហ្នឹងដឹងអំពីអ្វីដែលអង្គការបានប្រព្រឹត្ត។ បញ្ជាហ្នឹង គឺត្រូវបានអនុវត្តដោយអ្នកដែលគោរពវិន័យបំផុត ដូចជា ឌុច ជាដើមនៅ ស-២១។ ហើយនៅជិតពោធិ៍សាត់អ្នកទោសប្រហែលជា១.០០០នាក់ហ្នឹង ត្រូវបានសម្លាប់ចោលជាបន្តបន្ទាប់ ចាប់ពីម៉ោងប្រាំពីរយប់រហូតទៅដល់ម៉ោងប្រាំព្រឹក គឺការងារហ្នឹង ត្រូវតែធ្វើយ៉ាងម៉េច សម្លាប់ឲ្យអស់មុនពេលព្រលឹម"។ ហើយនៅក្នុងកំណត់សម្គាល់ជើងទំព័រហ្នឹង លោកបានលើកឡើងនូវបុគ្គលម្នាក់ជាប្រភពហ្នឹង ដែលកើតនៅឆ្នាំ៥៦ ហើយដែលលោកបានសម្ភាសនៅពោធិ៍សាត់ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩១។ ពាក់ព័ន្ធទៅនឹងការសម្លាប់នៅនាទីចុងក្រោយមុនពេលវៀតណាមចូលមក នៅតាមមន្ទីរសន្តិសុខនីមួយៗហ្នឹង តើគេរៀបរាប់រឿងនេះប្រាប់លោកច្រើនដង ឬក៏មានតែអ្នកដែលនៅរៀបរាប់ឲ្យលោកស្តាប់ហ្នឹង គឺពាក់ព័ន្ធតែ ស-២១ និងពោធិ៍សាត់ទេ?

[១៤:២៨:៣៦]

**ឆ៖** ខ្ញុំគិតថា សេចក្ដីណែនាំ ឬក៏បញ្ហានេះគឺមានលក្ខណៈជាទូទៅ គេឱ្យអនុវត្តទូទៅ។ ពោធិ៍សាត់នេះ ជាពេលដែលលើកទី១ ដែលខ្ញុំបានធ្វើដំណើរទៅទន្លេសាប ហើយខ្ញុំចាំថា ខ្ញុំជួបមនុស្សម្នាក់ពេលដែលខ្ញុំទៅនុ៎ង កាលពីឆ្នាំ៩០ជាងហ្នឹង គាត់ជាសាក្សីដែលរួចជីវិតពីការសម្លាប់រង្គាលហ្នឹង គឺគាត់កាន់ខាងរោងកុននៅក្រុងពោធិ៍សាត់។ គាត់បានរៀបរាប់លម្អិតជាក់លាក់បំផុត ជូនខ្ញុំពាក់ព័ន្ធទៅនឹងបញ្ហាឱ្យសម្លាប់រង្គាលនេះ ដែលមានរយៈពេលតែមួយយប់តែប៉ុណ្ណោះ។ ក្រោយទៀតហ្នឹងមានការផ្ដល់ចម្លើយពី ឌុច ដែល ឌុច គាត់ឆ្លើយហ្នឹង គឺដូចនឹងអ្វីដែលខ្ញុំបានរកឃើញដែរ។ ពិតណាស់ខ្ញុំ ពេលដែលខ្ញុំសម្ភាសហ្នឹង ខ្ញុំសួរថាតើគុកហ្នឹងគេបើកពេលណា បិទពេលណា ហើយខ្ញុំទៅកន្លែងណា ក៏ខ្ញុំសួរអ៊ីចឹងដែរ ហើយខ្ញុំស្ដាប់ឮពីសាក្សី គាត់ថា បញ្ហាហ្នឹងពីអង្គការមក គឺអ៊ីចឹងដូចគ្នាទាំងអស់។ ហើយក៏ប៉ុន្តែមិនប្រាកដថា គេគោរពតាមទាំងអស់ទេ តាមគុកដែរ។ <ទោះបីជានៅកន្លែងជាក់លាក់ ដូចជានៅពោធិ៍សាត់ ពួកគេបានសម្លាប់មនុស្ស -- មានគុកមួយធំណាស់។> គឺ<>គុកធំ<ជាងគេ>នៅ<ក្នុង>ខេត្ត<នោះ។ ទោះបីជាអ្នកទោសដែលនៅសល់ត្រូវបានគេ>សម្លាប់<>ចោល<នៅពោធិ៍សាត់>មែន ក៏ប៉ុន្តែនៅកន្លែងផ្សេងៗទៀតនោះ អាចមានគេដោះលែងអ្នកទោសដែរ។ ហើយបើយើងពិនិត្យមើលកន្លែងផ្សេងៗនោះ គឺថាយើងឃើញថា ឆ្នាំគុកហ្នឹង <បានរត់គេចខ្លួន ហើយទុកឱ្យ>អ្នកទោស<នៅ>ជាប់ខ្នោះ<ហើយប្រជាជនបានដោះលែងអ្នកទោសទាំងអស់នោះ>។ យើងដឹងថា បញ្ហាហ្នឹងគឺជាបញ្ហាចេញជាលក្ខណៈទូទៅ នៅទូទាំងប្រទេស ក៏ប៉ុន្តែមិនមានការអនុវត្តដូចគ្នាទាំងអស់ទេ។ ហើយយើងដឹងហើយថា នួន ជា បានបន្ទោស ឌុច នៅពេលដែលគាត់ជួបនៅឆ្នាំ៨០ ថា “ម៉េចក៏ ឌុច ឯង មិនកម្ទេចឯកសារចោលឱ្យអស់ទៅ។ បើលោកមិនសម្លាប់អ្នកទោសឱ្យអស់ ក៏គួរតែកម្ទេចឯកសារចោលឱ្យអស់ដែរ មិនត្រូវទុកអ៊ីចឹងទេ។” អ៊ីចឹងគាត់ថាដែរ គាត់ថា “ខ្ញុំដុតមិនទាន់ទេ កម្ទេចមិនទាន់ទេ ពេលនុ៎ង វាទាន់ហាន់ពេក”។

**ស៖** នៅពេលដែលលោកនិយាយថា បញ្ហាហ្នឹង គឺចេញមកពីមេដឹកនាំកំពូល ដូចជា នួន ជា ជាដើម ក្នុងការសម្លាប់អ្នកទោសចោលទាំងអស់នៅទូទាំងប្រទេសហ្នឹង តើលោកបានប្រភពហ្នឹងមកពីណាក្រៅពីការអះអាងរបស់ ឌុច ផ្ទាល់នេះ ដែលនៅស-២១នោះ?

[១៤:៣១:៣៩]

**ឆ៖** ប្រភពមួយទៀតរបស់ខ្ញុំនោះ គឺ នួន ជា ខ្លួនឯងផ្ទាល់។ នៅក្នុងអត្ថបទដដែល អាចឱ្យខ្ញុំដកស្រង់នៅទំព័រ៣១ មានបួនប្រាំបន្ទាត់ដែរ គឺពាក់ព័ន្ធនឹងភាពចាំបាច់ក្នុងការបោសសម្អាត ភាពចាំបាច់

ក្នុងការបោសសម្អាត ដើម្បីរក្សានូវថ្នាក់ដឹកនាំបក្សឱ្យនៅគង់វង្ស។ បាទ សូមអភ័យទោស ខ្ញុំនឹងអានជាភាសាអង់គ្លេសទៀតហើយ "គឺថា<មេដឹកនាំ>យើងត្រូវការពារ<ទោះបីត្រូវចំណាយប៉ុនណាក៏ដោយ> ប្រសិនបើយើងបាត់បង់សមាជិក <>ប៉ុន្តែមេដឹកនាំនៅសល់ យើងនៅតែបន្តជោគជ័យ។" យើងឃើញថាគេ -- បាទសូមអភ័យទោសផង ខ្ញុំដូរភាសាម្តងបារាំង ម្តងអង់គ្លេសអ៊ីចឹង អ្នកបកប្រែ ពិបាកបន្តិចហើយ។ "យើងឃើញថា បើសិនជាយើងរក្សាក្បាលម៉ាស៊ីនដឹកនាំបាន បដិវត្តន៍ក៏យើងអាចរក្សាបានដែរ។ ការការពារក្បាលម៉ាស៊ីនដឹកនាំ គឺយុទ្ធសាស្ត្រមួយសំខាន់ណាស់។ បើកាលណាក្បាលម៉ាស៊ីននៅរស់ហើយ គឺថាបក្សមិនស្លាប់ទេ។" នេះគឺជាឃ្លាប្រយោគមួយសំខាន់ គឺថា "មិនមានការប្រៀបធៀបបានរវាងការបាត់បង់កម្មាភិបាលដឹកនាំពីរបីនាក់ ឬសមាជិកពីរបីរយនាក់ អ៊ីចងសុខចិត្តបាត់សមាជិកបក្សវិញ វាគ្រាន់បើជាងបាត់ក្បាលម៉ាស៊ីនដឹកនាំ"។ អ៊ីចឹងបើយើងយល់<មិនខុសទេ> យើង<អាច> បាត់កម្មាភិបាល បាត់បីបួនរយនាក់ហ្នឹង អត់សំខាន់ទេ ងាប់ប៉ុន្មាន បីបួនរយហ្នឹង អត់សំខាន់ទេ ប៉ុន្តែ <បើយើងបាត់>ក្បាលម៉ាស៊ីនដឹកនាំ<បដិវត្តន៍>ពីរបីនាក់ហ្នឹង <វាគឺជាទីបញ្ចប់នៃអ្វីៗទាំងអស់>។ "<រឿងនេះបានបង្ហាញឱ្យឃើញតាមរយៈបទពិសោធន៍របស់>បក្សកុម្មុយនីស្ត ឥណ្ឌូនេស៊ី គឺថាក្បាលម៉ាស៊ីន<>៩០ភាគរយ ត្រូវបានគេបំផ្លាញចោល"។ បើអ៊ីចឹងគាត់និយាយហ្នឹង គឺថាគួរឱ្យចាប់អារម្មណ៍មែនទែន ពាក់ព័ន្ធទៅនឹងការបោសសម្អាត<បក្សកុម្មុយនីស្តឥណ្ឌូនេស៊ី ដែលបានកើតឡើងមុន>របប <កម្ពុជាប្រជាធិបតេយ្យ>។

[១៤:៣៣:៥៣]

**ស៖** ខ្ញុំសូមបន្តទៅមុខទៀត។ ឥឡូវខ្ញុំនិយាយពីតួនាទីរបស់លោក ខៀវ សំផន ម្តង។ លោកថាលោកបានសម្ភាសគាត់ក្នុងមួយថ្ងៃពេញ។ ហើយលោកបានបញ្ជាក់នៅក្នុងសៀវភៅ *"ពួតស ឡែ ខ្មែររូស"* របស់លោកដែរ នៅទំព័រ២៧៤ជាភាសាបារាំង។ លោកអាចបញ្ជាក់បានទេ លោកជួបគាត់នៅក្នុងក្របខ័ណ្ឌអ្វីដែរ? លោកបានធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ ឬក៏លោកថតសំឡេងគាត់? ហើយក្រោយមកទៀត លោកមានបានចេញជាអត្ថបទអី ពាក់ព័ន្ធនឹងបទសម្ភាសន៍ហ្នឹងទេ? <ឬក៏>លោក <មិន>មានស្លាកស្នាមជាលាយលក្ខណ៍អក្សរនៃខ្លឹមសារនៃបទសម្ភាសន៍ហ្នឹងទេ?

**ឆ៖** សំណួរនេះ ដូចជាខ្ញុំពិបាកឆ្លើយបន្តិច ព្រោះថាដើម្បីរៀចបំបទសម្ភាសន៍ហ្នឹង ខ្ញុំបានពិនិត្យមើលកំណត់ត្រាខ្ញុំច្រើនណាស់ ខ្ញុំមានសៀវភៅច្រើន ហើយខ្ញុំមានឯកសារនៅស្រុកបារាំងដែរ។ ខ្ញុំមិនអាចរកឃើញនៅក្នុងឯកសារនៅទីនេះទេ ព្រោះថាខ្ញុំមិនអាចរកឃើញបទសម្ភាសន៍ហ្នឹងទេ។ ហើយបើ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តាមការចាំរបស់ខ្ញុំហ្នឹង គឺថា យើងនិយាយគ្នាច្រើនអំពីការអប់រំរបស់គាត់ ពីជីវិតរបស់គាត់នៅស្រុកបារាំង។ ហើយខ្ញុំក៏បានសម្ភាស អៀង សារី ដែរ ដែល អៀង សារី គាត់និយាយអំពីកុមារភាពរបស់គាត់ ហើយគាត់កែអាយុដើម្បីចូលរៀននៅសាលាស៊ីសុវត្ថិជាដើម គាត់កែឈ្មោះ កែអាយុ ដើម្បីទៅរៀន។ ហើយគាត់ទៅរៀននៅស្រុកបារាំង ក៏ប៉ុន្តែ<យើងអត់មានពេលចូលទៅនិយាយដល់កម្ពុជាប្រជាធិបតេយ្យទេ។> ការសម្ភាសហ្នឹងគឺត្រូវបានអាក់ខានដែរ។ ហើយចំពោះ លោក ខៀវ សំផន គឺ សួង ស៊ីគឿន ជាអ្នកណែនាំខ្ញុំឲ្យស្គាល់ លោក ខៀវ សំផន។ ហើយខ្ញុំបានបញ្ជាក់មុនហ្នឹងហើយថា លោក ខៀវ សំផន គាត់ទទួលខ្ញុំដោយរាក់ទាក់មែនទែនពេលនុ៎ង។ ហើយខ្ញុំបានធ្វើជាសំណុំឯកសារមួយធំណាស់ ពាក់ព័ន្ធនឹងគាត់ហ្នឹង។ ហើយខ្ញុំចាំថា ពេលហ្នឹងលោក ខៀវ សំផន គាត់និយាយថា យើងជម្លៀសប្រជាជនចេញពីក្រុងហ្នឹង ដោយសារតែយើងមានការភ័យខ្លាច វៀតណាម។ ហើយខ្ញុំនៅចាំអ្វីដែលខ្ញុំបាននិយាយជាមួយគាត់នៅពេលនុ៎ង។

[១៤:៣៦:២០]

**ស៖** លោកបាននិយាយអំពីកេរ្តិ៍ឈ្មោះល្អរបស់ លោក ខៀវ សំផន នៅក្នុងរបបសង្គមរាស្ត្រនិយម គឺរបបសម្តេច សីហនុ។ <រូបសំណាករបស់គាត់ ឬក៏កេរ្តិ៍ឈ្មោះរបស់គាត់ជាបញ្ញវន្តមួយរូបដែលមិនពុករលួយ> តើ<ទាំងអស់នេះបានផលប្រយោជន៍>អ្វី<ដល់ចលនាបដិវត្តន៍>ខ្មែរក្រហមនោះ?

**ឆ៖** គឺគាត់មនុស្សគួរសម មនុស្សគួរឲ្យស្រឡាញ់ មនុស្សទាក់ទាញ។ ហើយលោក ខៀវ សំផន ហ្នឹងគាត់មានប្រយោជន៍ខ្លាំងមែនទែន សម្រាប់របបខ្មែរក្រហម ដើម្បីទទួលបានអំណាច។ ពីព្រោះថាប្រជាជនភាគច្រើនមិនដែលស្គាល់ ប៉ុល ពត, នួន ជា, តាម៉ុក, សោ ភឹម, កុយ ធួន, សុន សេន អីទេ។ គេស្គាល់តែលោក ខៀវ សំផន ទេ។ អ្នកទាំងអស់ហ្នឹងជាអ្នកដឹកនាំបដិវត្តន៍មែន ជាអ្នកដឹកនាំសង្គ្រាមស៊ីវិលមែន ក៏ប៉ុន្តែគេអត់ស្គាល់អ្នកទាំងអស់ហ្នឹងទេ។ ហើយសម្តេច សីហនុ នៅពេលដែលពាក់ព័ន្ធនឹងខ្មែរក្រហមហ្នឹង គាត់ឃើញថាមាន អៀង សារី ដែលគាត់មានសមានចិត្តច្រើនជាមួយ អៀង សារី។ ក៏ប៉ុន្តែគាត់គិតថាឥស្សរជនសំខាន់របស់កម្ពុជាប្រជាធិបតេយ្យក្នុងសង្គ្រាមស៊ីវិលហ្នឹង គឺជា ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម។ យើងមិនត្រូវភ្លេចទេថា <>ហ៊ូ យន់ គាត់ជាមនុស្សពូកែនិយាយណាស់។ គាត់មនុស្សទឹកមាត់ប្រៃណាស់។ <គាត់ជាអ្នកដែលបានជោគជ័យក្នុងចំណោមកសិករ។> អ៊ីចឹងគាត់ហ្នឹងហើយជាអ្នកចង់ឲ្យមានការធ្វើការនៅក្នុងសហករណ៍អីហ្នឹង។ អ៊ីចឹង<អ្នកទាំងអស់ហ្នឹងហើយជាមនុស្ស>ដែលសម្តេច សីហនុ <បានជួប នៅពេលដែល>គាត់ទៅភ្នំគូលែន ទៅអង្គរវត្តនៅខែ

មីនា ឆ្នាំ៧៦ហ្នឹង។ <ដូច្នេះមនុស្សសំខាន់>គឺ ខៀវ សំផន ហ្នឹងហើយជាអ្នកដែលមានតួនាទីសំខាន់នោះ។ ហើយនៅពេលបង្កើតហ្វុង ហ្វ្រុងហ្នឹង សម្តេច សីហនុ ហ្នឹងគាត់ថានៅក្បាលម៉ាស៊ីនគឺមានលោក ខៀវ សំផន។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ម្តងទៀត លោកថាអំមិញ ខែមីនា ៧៦?

[១៤:៣៩:០០]

**ឆ៖** បាទ ខ្ញុំច្រឡំទេ គឺខែមីនា ៧៣ទេ។

**ស៖** តើលោកមានព័ត៌មានអ្វីខ្លះ ពីការសម្ភាសរបស់លោកជាមួយអតីតកម្មាភិបាលខ្មែរក្រហមដែលធ្វើការនៅក្រសួងការបរទេស ពាក់ព័ន្ធទៅនឹងទំនាក់ទំនងរវាង ខៀវ សំផន និង ចលនាកុម្មុយនីស្តឬក៏បក្សកុម្មុយនីស្តលួចលាក់ ចាប់ពីពេលដែលគាត់ត្រលប់មកពីបារាំងវិញ នៅឆ្នាំ<៥៩> ហើយនិងនៅពេលដែលគាត់រត់ចូលព្រៃនៅឆ្នាំ៦៧នោះ?

**ឆ៖** សំណួរហ្នឹងពិបាកណាស់ អ្នកណាក៏សួរអ៊ីចឹងដែរ។ បើយើងសួរថាតើលោក ខៀវ សំផន មានទំនាក់ទំនងអ្វីខ្លះនៅពេលដែលគាត់ជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម? ហើយតើគាត់ទាក់ទងយ៉ាងម៉េចជាមួយបក្សកុម្មុយនីស្តលួចលាក់នោះ? យើងពិបាកឆ្លើយណាស់។ គ្មានអ្នកណាម្នាក់ជឿទេ ពិបាកជឿមែនទែនត្រង់ចំណុចនេះ។ ប្រហែលជាយើងមានតម្រុយពីរដែលបង្ហាញថា គាត់មានទំនាក់ទំនងមែន។ គឺទី១ គាត់ជាប្រធាន<>រង់ម៉ាក្សស៊ីសនៅប៉ារីស គាត់<ទទួលតំណែងនេះបន្តពី> អៀង សារី នៅ<ពេលគាត់ត្រឡប់ទៅ>បារាំង។ ហើយ រង់ម៉ាក្ស-ឡេនីន នេះ<ជាកន្លែងបង្កាត់ពូជ។> ខ្ញុំ<បាន>ពន្យល់<>ច្បាស់នៅក្នុងសៀវភៅរបស់ខ្ញុំហើយ ហើយ ស្ទួង ស៊ីគឿន ក៏បានពន្យល់ច្បាស់ដែរ នៅក្នុង<>ប្រវត្តិរូបរបស់គាត់ ថាវាជា វាដូចជាបក្សមួយអ៊ីចឹង ព្រោះថាវាធ្វើការដោយសម្ងាត់ ហើយមានជាសាខាតូចៗ ហើយដែលមនុស្សទាំងអស់គ្នាអត់ស្គាល់ទេ អ្នកនៅក្នុងសាខាមួយអត់ស្គាល់អ្នកនៅក្នុងសាខាផ្សេងទៀតទេ គឺការងារគេៗធ្វើជាសម្ងាត់។ ហើយគេបានសន្យាគ្នាថាមិនអាចបង្ហើបពីអត្ថិភាពនៃបក្សសម្ងាត់ហ្នឹងទេ។ អ៊ីចឹងគ្មានអ្នកណាដឹងថាហ្នឹងជាបក្សកុម្មុយនីស្តកម្ពុជាទេ។ ខ្ញុំភ្ញាក់ផ្អើលដែរតាំងពីនៅទីក្រុងប៉ារីសហ្នឹង គាត់<មិន>មានទំនាក់ទំនងជាមួយនឹង ប៉ុល ពត ហើយនិងឥស្សរជនផ្សេងៗផង<ទេ>។

[១៤:៤១:៤៥]

ចំណុចទី២ នៅពេលដែលគាត់ចូលព្រៃម៉ាគី តស៊ូនៅក្នុងឆ្នាំ៦៧ ពីព្រោះថាគាត់ស្ថិតនៅក្នុងបញ្ជី

អ្នកសង្ស័យទាំង៣៤រូប ដូច្នេះយើងគិតថា កាលណាអ្នកដែលមានឈ្មោះនៅក្នុងបញ្ជីហ្នឹង គឺថាត្រូវតែចាប់ខ្លួន ហើយសម្លាប់ចោលហើយ។ <ដូច្នេះវាមិនមែនធម្មតាទេ ដែលមនុស្សម្នាក់ត្រូវបានគេដាក់គុកមួយខែ ឬតិចជាងនោះចំពោះការលាបពណ៌ដ៏>មានគ្រោះថ្នាក់។<វាអាចគ្រោះថ្នាក់ជាងនោះទៅទៀត។ ដូច្នេះវាពិតជាគួរឲ្យចង់ដឹងខ្លាំងណាស់ ដែលគាត់ប្រាប់យើងថាមានមនុស្សរំដោះគាត់ ប៉ុន្តែគាត់មិនបានប្រាប់យើងទេថា គាត់ទាក់ទងជាមួយអ្នកដែលរំដោះគាត់នោះតាមរបៀបណា ហើយនរណា ក្នុងហេតុផលសន្តិសុខ មិនបញ្ជូនគាត់>ទៅរតនគិរី <ខណៈដែលគ្រប់ៗគ្នាទៅទីនោះ ព្រោះ> ប៉ុល ពត កំពុងតែបង្កើតមូលដ្ឋានរបស់គាត់នៅទីនោះ។ ខ្ញុំមិនដឹងថាតើ ខៀវ សំផន ចេញពីភ្នំពេញនៅខែណាទេ ដូចជាខែកក្កដាក៏មិនដឹង ខ្ញុំភ្លេចទៅហើយ។ ខ្ញុំដឹងថានៅចុងឆ្នាំ៦៧ ចុង៦៧ ដែល ប៉ុល ពត បង្កើតមូលដ្ឋានគាត់។ អ៊ីចឹងគាត់ថាគាត់ទៅភាគខាងត្បូង ព្រោះថាអត់មានត្រួតត្រាពីប៉ូលិសទេ។ <បើគាត់ទៅ>កំពង់ចាម <គឺ>មានប៉ូលិស<ដាក់ប៉ុស្តិ៍ត្រួតពិនិត្យ ហើយអាចមានគ្រោះថ្នាក់ខ្លាំង>។ ខ្ញុំពិបាកជឿមែនទែនថាគាត់<គ្មានការ>ទាក់ទង<គ្នា។> អ្នកដែលយើងអាចសួរបានមានតែ សាឡុត បាន មួយតែប៉ុណ្ណោះ។ សាឡុត បាន ឬ សួរ ហុង ពេលហ្នឹងគាត់ជាក្មេងជំទង់ដែរ គាត់រស់នៅជាមួយ ប៉ុល ពត រហូតទៅដល់ឆ្នាំ៦៣នោះ។ ហើយដូច សួរ ហុង ហ្នឹងដូចជាកូន ប៉ុល ពត អ៊ីចឹង។ គាត់ជិះកង់នាំសារ <>ពី នួន ជា ទៅឲ្យ ប៉ុល ពត។ <តើ>គាត់<នាំសារ>ទៅលោក ខៀវ សំផន ដែរ<ទេ?> អ៊ីចឹងគួរតែសួរសំណួរទៅលោក ខៀវ សំផន ផ្ទាល់។ យើងដឹងហើយ គាត់ប្រហែលជាមិនឆ្លើយទេ ប៉ុន្តែខ្ញុំគិតថានៅតែជារឿងអាថ៌កំបាំង មិនដឹងថាគាត់អាចទាក់ទងជាមួយអ្នកកុម្មុយនីស្តទាំងអស់នោះបានដោយរបៀបណា។

**ប្រធានអង្គជំនុំ៖**

បាទអរគុណអ្នកជំនាញ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី ប្រាំនាទីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីជំនាញរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី និងប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ឥឡូវនេះខ្ញុំសូមបន្តនិយាយអំពីតួនាទីរបស់លោក ខៀវ សំផន។ លោកអ្នកជំនាញ លោកបាននិយាយនៅក្នុងសៀវភៅ *"ពួកវ៉ុ ឡេ ខ្មែរក្រហម"* របស់លោក ឯកសារ E3/10640 ជំពូក១ មានចំណងជើងថា "អង្គការ" នៅទំព័រ១០៧។ លោកសរសេរថា៖ "ខៀវ សំផន ក្នុងឋានៈជាលេខាគណៈ<អចិន្ត្រៃយ៍>បក្ស គេហៅថាមន្ទីរ៨៧០ដែរ គឺស្ថិតនៅចំកណ្តាលអំណាចតែម្តង បេះដូងនៃអំណាចតែម្តង។" នៅក្នុងសម្រង់នេះដែរ លោកនិយាយថា គាត់មានតួនាទីនៅក្នុងកិច្ចការសេដ្ឋកិច្ច ហើយនិងទំនាក់ទំនងជាមួយនឹងសម្តេច សីហនុ ហើយនិងនៅក្នុងការសរសេររដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យផងដែរ។ តើហេតុអ្វីបានជាលោកសន្និដ្ឋានថា គាត់មានតួនាទីលេខមន្ទីរ៨៨០ -- អ៎! ៨៧០ សូមទោស?

[១៥:០៥:៣៧]

**លោក ហង់រី ឡូកា៖**

**ឆ៖** បាទ តាមពិតខ្ញុំដឹងថានេះ ជាកម្មវត្ថុនៃបញ្ហាចម្រូងចម្រាសហើយ <ហើយខ្ញុំជឿថា ខៀវ សំផន ខ្លួនគាត់ក៏គាត់បដិសេធដែរ>។ <>ក្រោយពីការចាប់ខ្លួនរបស់ <ឌុច *(ស៊ីក)*> ហ្នឹងទៅ បើសិនខ្ញុំមិនច្រឡំទេ<>លេខា <--> ក៏ប៉ុន្តែ<ខ្ញុំគិតថា សំណួរប្រភេទ>នេះ មិនមានសារៈសំខាន់អ្វីទេ ពីព្រោះថា ខ្ញុំសូមនិយាយម្តងទៀត អ្វីដែលខ្ញុំនិយាយកាលពីមួយម៉ោងមុននេះ គឺថារបប គឺជាការធ្វើមិនគ្រោងទុករហូត។ ខ្មែរមួយក្រុមតូចដែលដឹកនាំកម្ពុជាប្រជាធិបតេយ្យហ្នឹង មិនមានបទពិសោធន៍អ្វីទាល់តែសោះ ទាំងផ្នែករដ្ឋបាល ទាំងផ្នែកដឹកនាំ និងដឹកនាំរដ្ឋាភិបាល និងការដឹករដ្ឋបាលអីក៏ដោយ ហើយក៏គ្មានបទពិសោធន៍ណាមួយនៃរដ្ឋបាលសហគ្រាសឯកជននោះទេ។ អ៊ីចឹង<ពួកគេនិយាយខ្លួនឯងថា ពួក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គេ>អត់មានបទពិសោធន៍<គ្រប់គ្រាន់ទេ ហើយបាន>ប្រព្រឹត្តកំហុស<ជាច្រើន>។ អ៊ីចឹងគឺធ្វើអីទាំងអស់ គឺសុទ្ធតែអត់គ្រោងទុក។ អ្វីទាំងអស់សុទ្ធតែមិនបានកំណត់ឱ្យបានច្បាស់លាស់។ ហើយអ្វីដែលខ្ញុំដឹងនោះ គឺថាអ្វីដែលយើងដឹងនោះ គឺថា ខៀវ សំផន មាននវត្តមាននៅ “ក-៣” នៅ<ជាមួយ>ថ្នាក់ដឹកនាំនៃបក្ស ហើយតំណែងនេះរហូតដល់ចុងរបបនេះ។ បើសិន<>គាត់<ជាមនុស្សបន្ទាប់បន្សំ> ម៉េច<ក៏គាត់មិនចេញពីបក្សនៅឆ្នាំ១៩៧៩? ហេតុអីបានជាគាត់ក្លាយជាប្រមុខនៃក្រុមអ្នកតស៊ូ ឬក៏មេដឹកនាំក្រុមអ្នកតស៊ូដែលមានតែឈ្មោះ?> ហើយ<>ហេតុអី<បាន>គាត់<ទើប>តែ<ចូលជាមួយរដ្ឋាភិបាលបច្ចុប្បន្ននៅ>ឆ្នាំ១៩៩៨ហ្នឹង <ហើយអមដំណើរ> នួន ជា ផង បើសិនជាគាត់គ្រាន់តែតួចតាច កំប៉ិកកំប៉ុកនោះម៉េចក៏នៅបន្តធ្វើទៀត? អ៊ីចឹង<ចម្លើយរបស់ខ្ញុំគឺថា> យើងដឹងថាគាត់នៅចំបេះដូងនៃអំណាចហ្នឹង ហើយតួនាទីជាក់លាក់របស់បុគ្គលម្នាក់ៗនោះ មិនមានបញ្ជាក់ទេ មិនមានកំណត់ទេ។ <ព្រោះ> យើង<ត្រូវតែចាំ>ទុកថា<ពួកគេមិនបានកំណត់តំណែងមុខងារអីទាំងអស់ ដូច>រដ្ឋាភិបាល<ធម្មតា>មួយ<ដែលយើងដឹងនៅពេលនេះ នៅជុំវិញពិភពលោកនោះទេ>។

[១៥:០៨:០៧]

**ស៖** ខ្ញុំមានសំណួរផ្សេងទៀត ព្រោះថាពេលវេលាទៅមុខហើយ។ ខ្ញុំឃើញនៅក្នុងសៀវភៅរបស់លោកហ្នឹង មានសុន្ទរកថាលោក ខៀវ សំផន នៅពេលបុណ្យខួបជ័យជម្នះ ១៧ មេសា ១៩៧៥។ ខ្ញុំសូមដកស្រង់សុន្ទរកថាមួយដែលគាត់ថ្លែងនៅក្នុងឱកាសនេះ ក្នុង<ខែមេសា> ឆ្នាំ១៩៧៧។ ដើម្បីជាកំណត់ត្រាប្រតិចារឹកនោះ <>សុន្ទរកថានេះ<មាន>នៅឯកសារ E3/286 គឺជាឯកសារអេហ្វប៊ីស ជាអង់គ្លេស 00168205។ ផ្នែកមួយនៃឯកសារនេះ អានមិនដាច់ទេ។ អ៊ីចឹងប្រភពដែលប្រសើរជាងគេ គឺថា E3/200 ហើយនិង <E3/201>។ <នេះគឺ>ប្រតិចារឹក<មួយទៀតនៃសុន្ទរកថានោះ ដែលធ្វើឡើងដោយប៊ីប៊ីស៊ី គឺ>ERN ជាភាសាបារាំងគឺ 00612166, ជាភាសាអង់គ្លេសគឺ S00004165, ជាភាសាខ្មែរ គឺប្រហែលជានៅទំព័រ 00292805 រហូតទៅដល់806។ នៅក្នុងសៀវភៅរបស់លោក គឺនៅទំព័រ ១០៧, ១០៨ លោកនិយាយអំពី ខៀវ សំផន។ ខ្ញុំដកស្រង់៖ “យើងត្រូវតែបន្តភារកិច្ចរបស់យើងតទៅទៀត ការពារកម្ពុជាប្រជាធិបតេយ្យរបស់យើងបន្តទៀត ការពាររដ្ឋាភិបាល<ដែលបង្កើតឡើងដោយ> កម្មករ កសិករ <និង>វណ្ណៈអធន<> ហើយនិងរក្សាផ្លែផ្កានៃបដិវត្តន៍កម្ពុជា ដោយដាច់ខាតកម្ទេចរាល់ប្រភេទខ្មាំង <ដោយ>រាំងស្ទះមិនឱ្យពួកវាឈ្លានពាន ឬធ្វើការជ្រៀតជ្រែក ឬ<ធ្វើវិទ្ធង្សនាប្រឆាំងនឹងយើងឡើយ>។ ដើម្បីបង្ហាញថាយើងគ្រប់គ្រងស្ថានភាពបាន យើងត្រូវតែកម្ទេចខ្មាំង ដោយប្រកាន់

គោលនយោបាយផ្ទៃក្នុង និងការបរទេសយោធានៃអង្គការបដិវត្តន៍របស់យើង។ អ្វីទាំងអស់ត្រូវតែបំពេញឲ្យបានស្អាត ហើយឲ្យបានចប់គ្រប់ជ្រុងជ្រោយ។" សូមបញ្ចប់ការដកស្រង់។

[១៥:១១:០៤]

ការបកប្រែជាភាសាបារាំងនៃឯកសារ E3/200 ខុសគ្នាពីនេះបន្តិច ពីព្រោះថាវាឈរលើមូលដ្ឋាននៃការធ្វើប្រតិចារឹករបស់<ប៊ីប៊ីស៊ី>។ ក៏ប៉ុន្តែមានពាក្យពីរដែលខ្ញុំឆ្ងល់ យ៉ាងហោចណាស់ក៏ពីរពាក្យដែរ។ ប្រហែលជាលោកជួយបកស្រាយពាក្យហ្នឹងបាន គឺថាពាក្យថា "កម្ទេចដាច់ខាតរាល់ប្រភេទខ្មាំង" ហើយនិងពាក្យ "កម្ទេចខ្មាំង"។ តើយើងត្រូវបកស្រាយយ៉ាងម៉េចដែរ ខ្លឹមសារនៃពាក្យទាំងពីរនេះ នៅក្នុងសុន្ទរកថារបស់លោក ខៀវ សំផន គឺថាមាន "កម្ទេចខ្មាំង" ហើយនិងពាក្យមួយទៀតដូច "កម្ចាត់ខ្មាំង"?

**ឆ៖** បាទ ជាសុន្ទរកថាដូចគ្នា <ដូចសុន្ទរកថាមួយដែលគាត់បានបញ្ជាក់>ទាក់ទងនឹងកុមារៗហ្នឹង។ ជាសុន្ទរកថាសំខាន់ណាស់ ពីព្រោះថាគាត់បានថ្លែងសុន្ទរកថានេះ នៅពេលបុណ្យសំខាន់បំផុតនៃក្នុងប្រទេសខ្មែរនោះ។ យើងមិនត្រូវភ្លេចទេថា កម្ពុជាប្រជាធិបតេយ្យបានលុបថ្ងៃទី០៩ វិច្ឆិកា ឆ្នាំ១៩៥៣ ដែលជាថ្ងៃបុណ្យឯករាជ្យនៃប្រទេសកម្ពុជា ពីព្រោះ<ពួកគេ>អះអាងថា <នៅពេលនោះកម្ពុជា>មិនបានទទួលឯករាជ្យពេញលេញនោះទេ។ <បើតាមពួកគេ កម្ពុជាទទួលបានឯករាជ្យពេញលេញ>គឺថ្ងៃ១៧ មេសា ទេ ដែលគេទទួលបានទទួលឯករាជ្យពេញលេញពិតប្រាកដមែន។ អ៊ីចឹងគឺ<សុន្ទរកថានេះធ្វើ>នៅក្នុងបរិបទមួយដ៏អធិកអធម។ តើ ខៀវ សំផន សរសេរសុន្ទរកថានេះដោយខ្លួនឯង ឬក៏យ៉ាងណា? <ខ្ញុំមិនដឹងទេ។> សួង ស៊ីគឿន <ប្រាប់ខ្ញុំ>ថា គាត់គ្រាន់តែអ្នកថ្លែងសុន្ទរកថានេះទេ គឺប៉ុល ពត ជាអ្នកសរសេរ ក៏ប៉ុន្តែគាត់ជាអ្នកទទួលខុសត្រូវលើខ្លឹមសារនៃអ្វីដែលគាត់ថ្លែងដែរ។

[១៥:១៣:១២]

<ពីមុនមកគាត់ថ្លែងថា> យើងមានការលំបាកមែន ក៏ប៉ុន្តែយើង<>អាចឈ្នះលើខ្មាំងបាន។ <ដូច្នេះយើងកំពុងនិយាយអំពី>ខ្មាំងខាងក្រៅ ឬក៏ខ្មាំងក្នុង? <នេះជាសំណួរដំបូង។ ជាការពិតហើយមានប្រភេទពីរ>ខុសគ្នា <ហើយគាត់និយាយថា "នេះគឺជាការផ្តន្ទាទោសដ៏តឹងរ៉ឹង>របស់យើងដែលផ្អែកទៅលើភស្តុតាងជាក់ស្តែង" ដែល<អាចនិយាយបាន>ថា ខ្មាំងទាំងអស់នោះមិនអាចធ្វើអីយើងបានទេ ហៅថាផ្អែកលើភស្តុតាងជាក់ស្តែង និងដែលអាចអនុវត្តបាន។ <វាអស្ចារ្យណាស់ដែលបានស្តាប់>ពាក្យសម្តីនេះ ដែលគាត់និយាយពេលក្រោយដែលរបបហ្នឹងរលំហើយមកនោះ <>ថាគាត់<មិនបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដឹង>ថា <មនុស្សជាច្រើនត្រូវបានគេ>សម្លាប់<នោះទេ>។ <ជាមតិផ្ទុយគ្នាដ៏ប្លែកមួយ ហើយគាត់ប្រាប់យើងពីភាពផ្ទុយគ្នានេះ។ គាត់ប្រាប់យើង>ថា <គាត់មាន>ភស្តុតាងជាក់ស្តែង <និងអាចអនុវត្តបាន>។ <ទាំងអស់នេះជាពាក្យមានអំណាចណាស់។ នៅពេលដែលគាត់និយាយប្រាប់យើងនៅពេលក្រោយមកទៀត នូវអ្វីដែលគាត់បានដកស្រង់ គឺគាត់និយាយអំពីការវាយប្រហារ ថាយើងកំពុងនិយាយនៅទីនេះអំពី>ខ្មាំងមកពីខាងក្រៅ។ <ប៉ុន្តែនៅពេលដែលគាត់និយាយអំពី>វិទ្ធង្សនា<ប្រឆាំងនឹងយើងជាការពិតណាស់ គឺនៅទីនេះគាត់និយាយអំពី>ខ្មាំងនៅខាងក្នុង។ <ដូច្នេះហើយយើងត្រូវតែ> "កម្ចាត់" ឬ "កម្ទេច" <ពួកគេ ហើយនៅក្នុងពាក្យរបស់កម្ពុជាប្រជាធិបតេយ្យ គឺមានន័យថា> សម្លាប់ឲ្យផ្តាច់ពូជ។ <ដូច្នេះអ្វីដែលធ្វើឲ្យខ្ញុំរន្ធត់ អ្វីដែលធ្វើឲ្យខ្ញុំញ័រនោះ មិនមែនជាពាក្យដែលលោកបញ្ជាក់នោះទេ ប៉ុន្តែ>គឺពាក្យ<>ចុងក្រោយ<នៃសុន្ទរកថា>នេះគឺថា <"អ្វីៗត្រូវតែប្រតិបត្តិឲ្យបានច្បាស់លាស់ និងម៉ត់ចត់បំផុត"។ "ម៉ត់ចត់ និងពេញលេញ" តើវា>មានន័យថាយ៉ាងម៉េច<>? គឺមានន័យថា អ្នកដែលគេសង្ស័យថាជាខ្មាំងនោះ ត្រូវតែបោសសម្អាតឲ្យស្អាត។ គឺ<អាចនិយាយ>បាន<>ថា <>នៅពេលយប់ <នៅពេលងងឹត នៅកន្លែងស្ងាត់ ឆ្ងាយពីមនុស្សគ្រប់គ្នា ហើយយើងត្រូវតែធ្វើឲ្យប្រាកដ>ថា ពួកហ្នឹងពិតជាស្លាប់អស់ហើយ បានសម្លាប់ហើយៗ។ អ៊ីចឹងនេះគឺជាគុណកិរិយាមួយ ឃ្លាមួយៗនេះ ដែលគួរឲ្យរន្ធត់មែនទែន។

[១៥:១៥:២០]

**ស៖** បើតាមការ<ស្រាវជ្រាវ>របស់លោក បើតាមតួនាទីរបស់គាត់ជាប្រធានកម្ពុជាប្រជាធិបតេយ្យ <ដែលអាចនិយាយបានថា ជាអ្នកដែលទទួលខុសត្រូវ>ផ្នែកសេដ្ឋកិច្ច <ដូចដែល>លោកបានសរសេរថា <ទទួលខុសត្រូវ>នៅមន្ទីរ៨៧០អីជាដើមនេះ តើ ខៀវ សំផន គាត់មានដឹង ឬក៏គេជូនព័ត៌មានឲ្យគាត់ អំពីគោលនយោបាយសំខាន់ៗដែលកម្ពុជាប្រជាធិបតេយ្យដាក់ចេញដែរឬទេ? ឧទាហរណ៍ដូចជា ផ្នែកសន្តិសុខ ឬក៏ផ្នែកសមូហភាព ឬក៏ការដ្ឋាន ឬការងារសំខាន់ៗ ឬក៏កិច្ចការបរទេសអីជាដើមនោះ គាត់ដឹងទេ ឬក៏គាត់មិនដឹងអ្វីទាល់តែសោះ?

**ឆ៖** បាទ សំណួរនេះហ្នឹងគឺថា យើងអាចឆ្លើយតាមតែអ្វីដែលយើងមើលឃើញប៉ុណ្ណឹងទេ។ ទាល់តែ ខៀវ សំផន ខ្លួនហ្នឹង គាត់បិទភ្នែក ហើយចុកត្រចៀក ហើយបិទមាត់រហូត បានគាត់មិនដឹងមិនឮ តើគាត់នៅហ្នឹងធ្វើអី? <បើ>គាត់<ចង់ធ្វើមិន>ដឹងរឿងអីកើតឡើងសោះ <អ៊ីចឹងគាត់គួរតែស្នើ>សុំឲ្យគេបញ្ជូនគាត់<>ទៅជនបទទៅ។ អ៊ីចឹងការដែលថាមិនដឹងនេះ មិនអាចទៅរួចទេ។

**សៈ** ឥឡូវខ្ញុំសូមចូលនិយាយទៅប្រធានបទមួយទៀត ហើយខ្ញុំទៅលឿន និយាយលឿនបន្តិច នៅពេលនោះ។ ហើយឥឡូវទាក់ទងទៅនឹងគោលនយោបាយពាក់ព័ន្ធនឹងខ្មាំងផ្ទៃក្នុង តាំងពីខ្មាំងពីផ្ទៃខាងក្រៅ។ តើ<មានសារៈសំខាន់អីក្នុង>ការ<ប្រមាញ់>ខ្មាំងនេះ <ក្នុងចំណោមការងាររបស់កម្មាភិបាលខ្មែរក្រហម ដែលមានតួនាទីនៅ>ភូមិភាគ ឬក៏<តំបន់ភាគច្រើន>អីជាដើមនេះ? តើ<នោះជាការងារចម្បងរបស់ពួកគេ> ឬក៏<ការងារនេះ>កាន់តែ<រីកធំទៅ ឬក៏ផ្ទុយមកវិញ កាន់តែរួមតូចទៅ>?

[១៥:១៧:៥៥]

**ឆៈ** បាទ យើងនិយាយអំពីបញ្ហានេះហើយ នៅពេលដែលលោកសួរខ្ញុំពីដើមនោះ ខ្ញុំបាននិយាយអំពីពាក្យស្លោកមួយចំនួនទាក់ទងនឹងការកម្ចាត់ខ្មាំង គឺដៃម្ខាងកាន់កាំភ្លើង កាន់អាវុធ ម្ខាងទៀតកាន់ចប។ អ៊ីចឹងគឺថាមានគោលនយោបាយសំខាន់ពីរ គឺថាទី១ គឺថាត្រូវតែបង្កបង្កើនផលឲ្យបានច្រើនបំផុត ហើយទី២ ត្រូវកម្ចាត់ខ្មាំង<> វែកមុខខ្មាំង <>ចាប់ខ្មាំង ដើម្បីធ្វើយ៉ាងណាឲ្យបដិវត្តន៍ហ្នឹងស្អាតស្អំ ហើយទៅដល់គោលបំណងរបស់ខ្លួន។ <វាជាការពិតដែលថា>កាលណារបបហ្នឹងកាន់តែទៅមុខ <វា>កាន់តែ<ច្បាស់ថាបដិវត្តន៍នោះកាន់តែចេញឆ្ងាយពីបំណងរបស់ខ្លួន។ ជំនួសឲ្យការសួរខ្លួនគេ ថាតើ>គោលនយោបាយ<ធំៗ>របស់<>បដិវត្តន៍ <ឬក៏គោលនយោបាយរបស់បក្ស>ហ្នឹង <មាន>ខុស<អីទេ ពួកគេ>បែរ<ជា>មកធ្វើបាបជនរងគ្រោះទៀត។ ចង់និយាយថា បើយើងមិនអាចបង្កបង្កើនផលតាមផែនការទេនោះ បែរទៅជាគិតថា មានអ្នកធ្វើវិទ្ធង្សនា អ្នកខ្ជិល អ្នកជនក្បត់ដែលលាក់ខ្លួននៅតាមសហករណ៍។ អ៊ីចឹងបានន័យថា អានេះជំងឺត្រដេវវិចទៅវិញទេ គឺថាការចេះតែស្រមើស្រមៃថាមានគេក្បត់ខ្លួនរហូតហ្នឹង អ៊ីចឹងការកម្ចាត់ខ្មាំងហ្នឹង កាន់តែកើនឡើងៗ គុកហ្នឹងកាន់តែមានមនុស្សច្រើនទៅមនុស្សច្រើនទៅ មនុស្សច្រើនទៅ រហូតដល់ពេលមួយគេមិនមានពេលសួរចម្លើយអ្នកទោសផង។ <យើងបានឃើញបញ្ហានេះនៅ ស-២១ ព្រោះដល់ទីបញ្ចប់ទៅ មនុស្សត្រូវបានគេសម្លាប់ដោយផ្ទាល់នៅ>ជើងឯក មិនបាច់សួរចម្លើយផង។ នេះគឺជាបាតុភូតមួយដែលកើតមានឡើងទូទាំងប្រទេសនៅក្រោមរបបហ្នឹង។ អ៊ីចឹងបានន័យថា វិធានការកម្ចាត់ខ្មាំងនេះ វាគ្របដណ្ដប់លើវិធានការបង្កបង្កើនផលទៀត។

**សៈ** នៅក្នុងសៀវភៅលោកថា មានប្រភេទខ្មាំងបី<ប្រភេទ> គឺប្រភេទ<ខ្មាំង>ពីមុន <ខ្មាំង>ឥឡូវ ហើយនិងពេលក្រោយ។ <ទាក់ទងនឹងខ្មាំងពីមុន> ខ្ញុំសួរលោក ថាតើនាយទាហាន លន់ នល់ ហើយនិងមន្ត្រីរដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរហ្នឹង គាត់ទទួលជោគវាសនាយ៉ាងម៉េចដែរ ក្រោយពេលដែលខ្មែរក្រហមឡើងកាន់អំណាចភ្លាមហ្នឹង?

[១៥:២០:៣៩]

**ឆ៖** យើងមានសក្ខីកម្មច្រើនណាស់<អំពីរឿងនេះ ហើយ>ខ្ញុំ<សោកស្ដាយ ដែល>តុលាការយើងហ្នឹងបានជ្រើសរើស<តែ>ទួលពោធិ៍ជ្រៃ <ដែលជាកន្លែងមួយ>មានការសម្លាប់រង្គាល<>នាយទាហានជាន់ខ្ពស់នៃរបបសាធារណរដ្ឋ។ <កន្លែងនេះមិនសូវសំខាន់ទេ តុលាការគួរតែយកចិត្តទុកដាក់លើ>ភ្នំពេញ <និង>ខេត្តបាត់ដំបង<> ក៏ប៉ុន្តែតុលាការយកទួលពោធិ៍ជ្រៃ។ ចំពោះខ្ញុំផ្ទាល់នោះ កាលខ្ញុំនៅស្រុកខ្មែរទសវត្សរ៍៦០ហ្នឹង ខ្ញុំនៅ<ផ្ទះ>លោកស័ក្តិ៥ ស្រី មាស ហើយប្រពន្ធគាត់ហ្នឹងមានកូនបួន<នាក់> ហើយ<នៅពេល>ខ្ញុំត្រឡប់មកប្រទេស<កម្ពុជានៅ>ឆ្នាំ១៩៨៩វិញនោះ ខ្ញុំដឹងថា ស្រី មាស ហ្នឹងក្លាយជា កាលណោះដោយគេដឹងថា គាត់ហ្នឹងជា អង្គាល់គាត់ជាផ្កាយ១ អ៊ីចឹងក៏គេសម្លាប់គាត់ទាំងកូន ទាំងចៅ ទាំងប្រពន្ធអីទាំងអស់<តាំងពីដើមដំបូងនៃរបបនោះម្ល៉េះ។ ខ្ញុំដឹងរឿងនេះ តាមរយៈជីដូនមួយរបស់គាត់ ដែលបានរស់នៅក្នុងផ្ទះដែលខ្ញុំបានស្នាក់នៅនោះ>។ អ៊ីចឹងខ្ញុំ<>ក្តុលក្តួលណាស់។ ឧទាហរណ៍នេះ ហើយអ្វីដែលកើតនៅបាត់ដំបងនេះ យើងត្រូវដឹងថា នៅភាគខាងលិចនៃប្រទេសខ្មែរហ្នឹងត្រូវចាត់ទុកថា ជាតំបន់ដែលមានខ្មែរក្រហមច្រើនគ្របដណ្តប់ដោយខ្មែរក្រហម <ប៉ុន្តែបាត់ដំបងជាតំបន់តែមួយគត់ក្នុងប្រទេសកម្ពុជា ដែលស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់សាធារណរដ្ឋខ្មែរ>។ អ៊ីចឹងការបង្ក្រាបនៅភូមិភាគពាយ័ព្យនៅខាងលិចនេះ គឺធ្ងន់ណាស់។ អ៊ីចឹងពួកដែលនៅខាងណោះហ្នឹងមានតែពួក១៧មេសាទាំងអស់ ប្រជាជនថ្មីទាំងអស់ ដែលគេជម្លៀសទៅៗហ្នឹង ប្រជាជនចាស់មិនមានទេនៅខាងបាត់ដំបងនោះ។ នៅបាត់ដំបងនោះ គេបែងចែកកងទ័ពសាធារណរដ្ឋជាបី។ អ្នកនាយជាន់ខ្ពស់គេឲ្យស្លៀកពាក់សម្លៀកបំពាក់ឯកសណ្ឋានរបស់ខ្លួន ឲ្យមកភ្នំពេញទទួល សីហនុ នៅពោធិ៍ចិនតុង។ ហើយអ្នកនាយទាហានរងនោះ គេប្រមូលផ្តុំដាក់មួយម៉ុទៅ បញ្ជូនទៅថ្មគោល ហើយនៅទីនោះៗគេសម្លាប់គាត់ចោលទាំងអស់នៅថ្មគោលហ្នឹង។ ហើយកូនទាហានតូចតាចហ្នឹង ហើយជាមួយក្រុមគ្រួសារនោះ គេបញ្ជូនទៅខាងត្បូងនៃខេត្តបាត់ដំបងទៅភ្នំសំពៅ។ ហើយក្រោយមក គឺយើងឃើញមានកំពឹងពួយហ្នឹង គឺពួកនុ៎ងហើយដែលអ្នកចាប់ផ្តើមធ្វើការលើការដ្ឋានហ្នឹង ការដ្ឋានដ៏ធំល្បីងល្បើយហ្នឹង អាងកំពឹងពួយនោះ។ ព្រោះខ្ញុំគិតថា មនុស្សភាគច្រើនធ្លាប់ទៅលេងនៅទីហ្នឹងហើយ គឺជាសមិទ្ធផលដ៏សម្បើមរបស់របបខ្មែរក្រហម ហើយមានមនុស្សជាច្រើនស្លាប់ ក្នុងចំណោមកូនទាហានទាំងអស់នុ៎ង<ហើយអ្នកខ្លះបានទៅនៅតាមសហករណ៍>។

[១៥:២៣:៣៩]

ហើយទាក់ទងនឹងនាយទាហានជាន់ខ្ពស់នោះ ពេលដែលពួកគាត់មកដល់ស្រុកមោង ដែលនៅខាងកើតនៃខេត្តបាត់ដំបងហ្នឹង គេឲ្យគាត់បត់ទៅភ្នំធិបតី។ ដែលទៅដល់ភ្នំធិបតីហ្នឹង គឺភ្នំធិបតីជាកន្លែងមួយដែលមានវត្តមួយ ហើយមានរ៉ាវទេះភ្លើង រ៉ាមោងនៅស្រុកមោង ប្រហែលជាមាន<ចម្ងាយ១០> ឬ ២០គីឡូម៉ែត្រពីផ្លូវជាតិ។ អ៊ីចឹងក្រោយពីចេញបានពីរបីគីឡូម៉ែត្រពីផ្លូវជាតិហ្នឹង គេឲ្យពួកនាយទាហានទាំងអស់ហ្នឹងចុះពីលើឡាន ហើយបាញ់ចោលទាំងអស់។ អ៊ីចឹងការកាប់សម្លាប់រង្គាលនៅភ្នំធិបតីនេះ គឺជារឿងមួយដែលនរណាក៏ដឹងដែរ គឺថាសម្លាប់នាយទាហានជាន់ខ្ពស់នៃរបបសាធារណរដ្ឋ។ ហើយ<ខ្ញុំសោកស្ដាយ ដែល>កន្លែងហ្នឹង តុលាការយើងអត់បានជ្រើសរើសយកកន្លែងហ្នឹងទេ ហើយកន្លែងនោះយើងដឹងថាមានសាក្សីច្រើន។ ខ្ញុំមានសាក្សី ដែលគាត់ពុតធ្វើជាស្លាប់ទៅ ហើយក្រោយមកក៏រស់រានមានជីវិតទៅ។ <ពួកគេបានទុកសាកសពនៅទីនោះជាយូរ ដើម្បីបំភិតបំភ័យប្រជាជន។>

**ស៖** ក្រោយពីចូលមកកាន់កាប់ភ្នំពេញ ហើយនិងទីរួមខេត្តផ្សេងៗទៀតហើយ តើមានការចាប់មនុស្សអតីតទាហាន លន់ នល់ ទ្រង់ទ្រាយធំទៀតទេ ឧទាហរណ៍ដូចជានាយទាហានជាន់ខ្ពស់ ឬក៏នាយទាហានរង ឬក៏កូនទាហានតូចតាចនោះ? តើបើសិនជាមានចាប់មែននោះ តើគ្រួសាររបស់គាត់ហ្នឹង<ត្រូវបានគេយកទៅជាមួយដែរទេ>?

[១៥:២៥:៣៨]

**ឆ៖** ការបន្តសម្លាប់ទាហាន លន់ នល់ នោះបន្តរហូត។ <វាបានកើតឡើងជាពិសេសនៅដើម>ដំបូង<នៃរបប>ហ្នឹង<> នៅពេលដែលគុក គេចាប់ផ្ដើមបើកហើយហ្នឹង។ យើងដឹងថា មានគុក<រួចទៅហើយ>នៅ<អំឡុងពេលសង្គ្រាមស៊ីវិល នៅភូមិភាគដែលគ្រប់គ្រងដោយពួកខ្មែរក្រហម>។ ក៏ប៉ុន្តែនៅក្នុងឆ្នាំ១៩៧៥នេះ គេបង្កើតគុកគ្រប់កន្លែង បង្កើតបណ្ដាញ។ <គុកទាំងអស់នោះ>ជួនកាលនៅតាមវត្តហើយនិងសាលា <ឬក៏គុកដែល>គេធ្វើ<ឡើងភ្លាមៗ។ ចង់និយាយថា ផ្ទះវែង ចង្អៀតដូចដែលយើងឃើញ>នៅ<ខេត្ត>កំពង់ឆ្នាំងអ៊ីចឹង យើងឃើញមានច្រើន ហើយវាមានទូទាំងប្រទេសតែម្ដង។ អ៊ីចឹងការចាប់ហ្នឹង គឺថា<ប្រព្រឹត្តទៅ>នៅក្នុងឆ្នាំ៧៥ <ប៉ុន្តែជាពិសេសនោះគឺនៅចុងបញ្ចប់។ ដូច្នេះ>អ្នកទោស<ដំបូង នៅ>ពេលដែល មឿង សុន ហើយនិង ផល្លី គេចាប់គាត់នៅខែធ្នូ ឆ្នាំ១៩៧៥ នោះគឺថា <ក្នុងចំណោម>អ្នកទោស<ទាំងអស់នេះ មានមន្ត្រី>រដ្ឋបាលនៃរបបសាធារណរដ្ឋ ហើយ <និងអ្នកដែល>មិនត្រូវបានគេសម្លាប់ភ្លាមទេ ពីដើមនៃរបបខ្មែរក្រហមនោះ <ហើយនិងទាហានសាធារណរដ្ឋ>។ ចំពោះស្ត្រីវិញហ្នឹង គឺដំណាក់កាលទី២ហើយ គឺថានៅខេត្តពោធិ៍សាត់ គឺនៅដល់ឆ្នាំ

១៩៧៨ហើយ គឺឆ្នាំចុងក្រោយនៃរបបខ្មែរក្រហមហើយ ដែលគេទៅចាប់ប្រពន្ធទាហានខ្មែរក្រហម ដែលគេសម្លាប់ពីឆ្នាំ៧៦, ៧៧ កន្លងមកហើយនោះ។ អ៊ីចឹងការកម្ចាត់ឃោឆាកងទ័ព លន់ នល់ នេះ គឺថាបន្តរហូតពេញមួយរបបខ្មែរក្រហម។ <យើងត្រូវយល់ថា មានការចលាចល និង>អំពើអាណាធិបតេយ្យ <ដូច្នេះ>ហើយ<>ទាហានលន់ នល់ <មួយចំនួន>នោះគាត់<បាន>លាក់ខ្លួន លាក់អីទៅអ៊ីចឹងមិនអាចចាប់សម្លាប់បានទាំងអស់ទេ។ ទាហាន លន់ នល់ នោះវាច្រើនជាងខ្មែរក្រហមទៀតផង។

[១៥:២៨:០៥]

**ស៖** កាលពីម្សិលមិញលោកបាននិយាយអំពីបណ្ណសារ ឯកសារទាក់ទងទៅនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ ស្រុកត្រាំកក់។ តើលោកមាននៅចាំថាបានឃើញឯកសារដែលទាក់ទងទៅនឹងបញ្ជីឃោឆា ឬក៏នាយទាហានជាន់ខ្ពស់ លន់ នល់ ដែរឬទេ នៅក្នុងស្រុក<នេះ ជាពិសេសនៅ>មន្ទីរសន្តិសុខ<ក្រាំងតាចាន់>ហ្នឹង លោកមានចាំទេ?

**ឆ៖** ខ្ញុំគិតថា តុលាការមានអត្ថបទរបស់ខ្ញុំហើយ ដែលខ្ញុំសរសេរនៅលើមន្ទីរសន្តិសុខស្រុកត្រាំកក់នោះ។ គឺថាមានអ្នកទោស៤៧៧នាក់នៅមន្ទីរសន្តិសុខហ្នឹង។ ម្សិលមិញខ្ញុំបានអានដែរ ខ្ញុំដូចចាំថា ឃើញថាមានទាហាន លន់ នល់ តិចទេ។ ឯកសារហ្នឹង វាមានដោយផ្នែកទេ <គឺឯកសារនោះចុះកាលបរិច្ឆេទ>នៅចុងឆ្នាំ១៩៧៧-៧៨ ហ្នឹង <ដូច្នេះនៅពេលនោះ>គឺថាទាហាន លន់ នល់ ហ្នឹងនៅសល់តិចណាស់ ដែលត្រូវសម្លាប់នោះ។ ក៏ប៉ុន្តែ លើចំណោមអ្នកទោស៤៧៧នាក់ហ្នឹង គឺថាភាគច្រើនអ្នកទោសទាំងអស់ហ្នឹងព្យាយាមរត់ទៅវៀតណាម។ អ៊ីចឹងទាហាន លន់ នល់ តិចណាស់ ក្នុងចំណោមអ្នកទោសទាំង៤៧៧ នាក់ហ្នឹង។

[១៥:២៩:៣៥]

**ស៖** ខ្ញុំចង់អានការវិភាគរបស់លោកទាក់ទងទៅនឹងស្រុកត្រាំកក់ហ្នឹង។ ឯកសារ E3/8299 ចំណងជើងគឺ "ឯកសារនៅមន្ទីរសន្តិសុខក្រាំងតាចាន់" ទំព័រជាភាសាបារាំងគឺទំព័រទី៣, ជាភាសាអង់គ្លេស ERN គឺ 00217693។ ខ្ញុំអត់មានលេខ ERN ជាភាសាខ្មែរទេ។ លោកនិយាយអំពីឯកសារនៅមន្ទីរក្រាំងតាចាន់ ដូចតទៅ លោកបានឃើញនៅទីនោះ មានលោកនិយាយអ៊ីចេះថា៖ "មានឯកសារពីរប្រភេទ គឺថា<ច្រើនតែ>របាយការណ៍ដែលសរសេរនៅមន្ទីរក្រាំងតាចាន់ហ្នឹងតែម្តង។ ហើយដែលគេនាំអ្នកទោសទៅក្រាំងតាចាន់ ហើយនិងសេចក្តីសង្ខេបការសួរចម្លើយនៅមន្ទីរក្រាំងតាចាន់ហ្នឹង។ <ក្រៅពីនោះ>មានបញ្ជីប្រាំមួយ ដែលក្នុងនោះមានឈ្មោះមនុស្ស១៨៦នាក់ ដែលគេមិនដឹងថា មានរឿង

អីកើតឡើងចំពោះមនុស្សទាំង១៨៦នាក់ហ្នឹងទេ។ បញ្ជីដែលមានឈ្មោះមនុស្ស៣៧ហ្នឹង គឺសុទ្ធតែជាយោធា។ បញ្ជីហ្នឹងចុះនៅថ្ងៃទី២៧ មេសា ឆ្នាំ១៩៧៧ គឺនៅពេលដែលប្រហែលជាមានការណែនាំជាទូទៅ ដើម្បីឲ្យចាប់ទាហាន លន់ នល់ ដែលនៅសេសសល់ទាំងប៉ុន្មាន។" សូមបញ្ចប់ការដកស្រង់។ តើលោកនឹកឃើញទេថា មានឯកសារចុះនៅឆ្នាំ១៩៧៧ ហើយនិងបញ្ជីអតីតទាហាន លន់ នល់នោះ? ប្រហែលជាមិនមែនជាឯកសារមន្ទីរក្រាំងតាចាន់ផ្ទាល់ទេ ប្រហែលជាឯកសាររចនាសម្ព័ន្ធរដ្ឋបាលនៅស្រុកត្រាំកក់?

[១៥:៣១:៤១]

**ឆះ** ខ្ញុំភ្លេចភ្លាំងច្រើន។ អ៊ីចឹងចំនួន៣៧នាក់ហ្នឹង ក្នុងចំណោម៤៧៧នាក់ហ្នឹង គឺថាវាមានតិចណាស់ តិចជាងអ្នកលួចរត់ទៅវៀតណាមច្រើន។ ក៏ប៉ុន្តែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងទាំងមូលតែម្តងហ្នឹង គេតាមចាប់ទាហាន លន់ នល់ ក៏ប៉ុន្តែអ្វីដែលគួរឲ្យចាប់អារម្មណ៍ លើអ្វីដែលលោកទើបនឹងនិយាយហ្នឹង។ ហើយយើងក៏ត្រូវចោទសំណួរហ្នឹងដូចគ្នាហ្នឹងដែរ ចំពោះករណីមន្ទីរស-២១ គឺត្រូវសួរថា តើអ្នកទោសដែលមកមន្ទីរក្រាំងតាចាន់ ឬក៏មកមន្ទីរស-២១នុ៎ងមកហ្នឹង គឺមានឯកសារមួយហើយ គឺថាប្រវត្តិរូបរបស់ខ្លួន ដែលគេបានធ្វើរួចហើយស្រេចទៅហើយ ធ្វើដោយអ្នកសួរចម្លើយពីមុនៗមក ឬក៏ជាពិសេសសម្រាប់ប្រជាជនថ្មីហ្នឹង គឺថាត្រូវតែសរសេរប្រវត្តិរូបរបស់ខ្លួន។ <អ្វីដែលខ្ញុំយល់គឺថា នេះ>ជារបបមួយដែលគេផ្សព្វផ្សាយពីមាត់មួយទៅមាត់មួយ <ដែលជារបបការិយាធិបតេយ្យតឹងតែងខ្លាំង ដូច្នេះមានក្រដាសច្រើនណាស់ ហើយខ្ញុំមិនដឹងថាតើ "កម្មាភិបាល" ឬក៏មេដឹកនាំដែលជាអនក្ខរជន ឬក៏អ្នកដែលស្ទើរតែមិនចេះអាន សរសេរនោះ អាចបំពេញភារកិច្ចយ៉ាង>ម៉េចនៅ<ក្នុងប្រភេទដែលមានឯកសារក្រហមច្រើនយ៉ាងនេះ>។ អ៊ីចឹងអ្វីដែលខ្ញុំយល់នោះ គឺថាគេសុំឲ្យប្រជាជន១៧មេសាទាំងអស់ សរសេរប្រវត្តិរូបរបស់ខ្លួនដែលប្រវត្តិរូបនេះ ត្រូវទុកនៅតាមសហករណ៍។ ហើយករណីមួយទៀត ពេលដែលមានការចាប់ខ្លួនអីអ៊ីចឹង គេមិននាំទៅមន្ទីរសន្តិសុខភ្លាមទេ គេទៅកន្លែងមន្ទីរសន្តិសុខនៅមូលដ្ឋានហ្នឹង គេសួរ<ពីរបីថ្ងៃ> ហើយគេដាក់ខ្នោះដាក់អី សួរចម្លើយអ៊ីចឹងទៅ។ ជួនកាលគំរាមកំហែង ហើយជួនកាលធ្វើទារុណកម្មអីជាដើម។ អ៊ីចឹងគឺថា មានសំណុំឯកសារមួយហើយស្រេចហើយ។ ហើយបន្ទាប់មកទៀត ប្រហែលជាពេលគេបញ្ជូនមកគុកហ្នឹង គឺមកមានសំណុំឯកសាររួចហើយ ស្រេចទៅហើយ។ ត្រង់ចំណុចនេះគឺ ឌុច ក៏គាត់និយាយមិនច្បាស់ទេ។ ខ្ញុំមិនយល់ច្បាស់ទេ។ ខ្ញុំមិនដឹងថា តើដំណើរការនៅមន្ទីរស-២១នោះ យ៉ាងណាទេ ក៏ប៉ុន្តែនៅគុកតាមខេត្តវិញ គឺថាជនរងគ្រោះ

គាត់ពេលគាត់ទៅដល់គុកតាមខេត្តនោះ គឺមានឯកសារមកជាមួយហើយគាត់ទៅជាមួយ។ នៅគុកក្រាំងតាចាន់អីអ៊ីចឹង គឺថាមានឯកសារ មានអីអ៊ីចឹង មានសេចក្តីសង្ខេបនៃការសួរចម្លើយនៅក្នុងសៀវភៅ គេសរសេរហើយស្រេច។

[១៥:៣៤:១០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារមួយទៅអ្នកជំនាញ គឺឯកសារ E3/2048 គឺជាសេចក្តីសង្ខេបដែលមកពីស្រុកត្រាំកក់ ដែលទាក់ទងនឹងការចាប់ខ្លួន នៅក្នុងឆ្នាំ១៩៧៧ ចំពោះយោធាលន់ នល់។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារនេះ ទៅលោកអ្នកជំនាញ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីតុលាការទទួលឯកសារជាក្រដាសពីសហព្រះរាជអាជ្ញារងអន្តរជាតិ យកជូនអ្នកជំនាញ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ឯកសារនេះមានច្រើនទំព័រ ខ្ញុំដកស្រង់បីទំព័រ ជាភាសាបារាំងគឺទំព័រ២ ទៅដល់៤ គឺ ERN 00311659 ទៅដល់ 61, ជាភាសាខ្មែរគឺ 00079089 ទៅដល់ 91, ជាភាសាអង់គ្លេសគឺ 00376562 ទៅដល់ 64។ នេះជាសារបីដែលផ្ញើចេញជាបន្តបន្ទាប់។ សារទី១ ចេញមកពីឈ្មោះ មឿន ឃុំជាងទង ដែលរាយការណ៍នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ ជូនស្រុកត្រាំកក់។ ពេលនោះគាត់រាយការណ៍ដូចតទៅ ខ្ញុំសូមដកស្រង់៖ "ពាក់ព័ន្ធនឹងបញ្ហាខ្មាំងដែលនៅក្នុងមូលដ្ឋានរបស់ខ្ញុំ ក្រោយពីទទួលសេចក្តីណែនាំជាបន្តបន្ទាប់របស់អង្គការពាក់ព័ន្ធនឹងការប្រុងប្រយ័ត្នចំពោះខ្មាំង និងការបោសសម្អាតទាហានខ្មាំង ដែលជាអ្នកមានឋានៈ យើងបានតាមដានពិនិត្យ និងកំណត់អត្តសញ្ញាណបុគ្គលដូចខាងក្រោម។" ពេលនុំងគាត់រៀបរាប់ឈ្មោះមនុស្សពីរនាក់ មួយជាអតីតទាហានដែលមានស័ក្តិ២។

[១៥:៣៦:៣៣]

ហើយខ្ញុំសូមអានឯកសារមួយទៀតគឺ ជាសាររបស់ឈ្មោះ ជន ក៏ប៉ុន្តែនៅក្នុងឯកសារ<បកប្រែមួយ>ផ្សេង<ទៀត>គេនិយាយ<អំពី> ផាន ទៅវិញ ប៉ុន្តែគាត់ហ្នឹងនៅឃុំពពេល។ គាត់រាយការណ៍នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៧៧ ជូនអង្គការ <មកពី>ស្រុក។ ចំណុចទី២ ខ្ញុំសូមដកស្រង់៖ "១០៦ គ្រួសារនៃទាហាន លន់ នល់ <ឬស្មើនឹងមនុស្ស៣៩៣នាក់> ត្រូវបានអង្គការកម្ទេច ហើយពួកនេះគឺ

ស្លាប់អស់ហើយ។ ចំណុចទី៣ នៅសល់៦៣១គ្រួសារទៀតនៃរបបចាស់ ប្រហែលជាត្រូវ៨៩៦នាក់ សរុបទៅគឺ១.៥១៣នាក់។ ខ្ញុំសូមបញ្ជាក់ជូនបក្សថា នៅសល់គ្រួសារមួយចំនួនដែលយើងមិនទាន់បានពិនិត្យ ដើម្បីចង់ដឹងថាពួកហ្នឹងជាប់ពាក់ព័ន្ធនឹងអតីតទាហាន លន់ នល់ ឬក៏អត់។"

និងជាចុងក្រោយឯកសារទី៣ ចេញមកពីឈ្មោះ គិត ប្រធានសហករណ៍តាភេម ចុះនៅថ្ងៃដូចគ្នា គឺ<២០> មេសា ឆ្នាំ៧៧។ ឯកសារនេះរៀបរាប់ថា៖ "ក្រោយពីទទួលសេចក្ដីណែនាំពីបក្ស ខ្ញុំបានពិនិត្យ និងបោសសម្អាតខ្មាំងដែលជាអ្នកមានបណ្ដាស័ក្តិ។ ខ្ញុំចុះទៅមូលដ្ឋានផ្ទាល់ ដើម្បីពិនិត្យមើលឋានៈរបស់អ្នកទាំងអស់ហ្នឹង។ ហើយខ្ញុំឃើញថានៅសល់ប្រាំមួយនាក់ ដែលជាអ្នកមានឋានៈខ្ពស់នៅក្នុងរបប<ចាស់>។" ពេលនោះគាត់រៀបរាប់ឈ្មោះ ហើយនិងឋានន្តរសក្ដិដែលជាអ្នកស័ក្តិ២ ឬក៏ស័ក្តិ១ជាទូទៅនោះ។ លោកសាក្សី តើលោកអាចធ្វើការវិភាគ ឬក៏អត្ថាធិប្បាយទៅលើឯកសារទាំងបីនេះដែលចុះទៅ រយៈកាលដូចគ្នា ដែលនិយាយអំពីសេចក្ដីណែនាំរបស់អង្គការ ឬក៏បក្សឲ្យបោសសម្អាតទាហាន លន់ នល់?

[១៥:៣៩:០៥]

**លោក ហង់រី ឡូកា៖**

**ឆ៖** ឯកសារទាំងអស់ហ្នឹង ខ្ញុំមិន<ដឹង>ថាខ្ញុំមាន ឬក៏ខ្ញុំបានថតចម្លង ឬក៏អត់ទេ។ ខ្ញុំអត់នឹកឃើញអីទាំងអស់។ ក៏ប៉ុន្តែឯកសារទាំងបីហ្នឹង ហាក់ដូចជាឯកសារសំខាន់ និងគួរឲ្យចាប់អារម្មណ៍ណាស់ ក្នុងការស្វែងរកការពិតពាក់ព័ន្ធនឹងការសម្លាប់អតីតទាហាន លន់ នល់ នោះ។ វាបង្ហាញអំពីរបៀបនៃការធ្វើការរបស់របបនោះ។ យើងឃើញថា ទាហានដើរតួនាទីជាប៉ូលិស គឺមិនមែនជាទាហានទេជាអ្នកសម្រេចចាប់មនុស្សនោះ គឺជាជនស៊ីវិល។ យើងឃើញហើយថា អ្នកដែលចុះហត្ថលេខានៅទីនេះមានអ្នកមកពីឃុំជាងទង គឺឈ្មោះ មឿន ក៏ដូចជា ជន។ ខ្មែរគឺ "<ឈុន>" មិនមែន "<ជន>" ទេ។ ពួកគាត់ហ្នឹងគឺជាប្រធានសហករណ៍ សុទ្ធតែជាកម្មាភិបាលខ្មែរក្រហម គឺជាជនស៊ីវិល។ ដូច្នេះជនស៊ីវិលហ្នឹង<គឺជាសមាជិកបក្ស ហើយពួកគេ>ទទួលសេចក្ដីណែនាំពីបក្ស ក្នុងការស្វែងរកខ្មាំង កំណត់អត្តសញ្ញាណខ្មាំង។ គេប្រាប់ពួកគាត់ថាត្រូវតែរកឲ្យឃើញ រែកមុខឲ្យបាននូវអ្នកដែលធ្វើជាទាហាន លន់ នល់។ អ៊ីចឹងយើងឃើញហើយថា ដូចជាស្ទើរតែប្រជាជនទាំងអស់ហើយជាទាហានពេលហ្នឹង ពីសម័យ លន់ នល់ គេចាប់ឲ្យចូលធ្វើទាហាន។ អ៊ីចឹងវាបង្ហាញច្បាស់ ថាតើម៉ាស៊ីនសម្លាប់មនុស្សនោះដំណើរការយ៉ាងម៉េច គឺមានបញ្ជាចេញពីមជ្ឈិមបក្ស ហើយមានប្រភេទមួយចំនួនដែលគេកំណត់ជាមុខ

សញ្ញា យើងមើលឃើញហើយថាមានខ្មាំង។ <ប្រជាជនល្អ គឺគេជឿថា ផលិតស្រូវ និងរកខ្មាំង។ ដូច្នេះ គេរកខ្មាំង ហើយអ្នកដែលមានសំណាងអាក្រក់>ទោះបីជាអ្នកខ្លះធ្វើទាហានបានតែមួយខែពីរខែក៏ដោយ ក៏គេចាត់ទុកថាជាខ្មាំងដែរ ទោះបីជាពួកគាត់មិនបានធ្វើអីឲ្យបានធំដុំក៏ដោយ គេចាត់ទុកថាជាក្រុមមនុស្សដែលត្រូវបញ្ជូនទៅក្រាំងតាចាន់ដើម្បីសម្លាប់ចោល។ ហើយខ្ញុំ<គិតថា>មិន<មាន>នៅសល់ទាហានប៉ុន្មាន<>ទេនៅ<ពេលនោះ>។

[១៥:៤១:៣០]

**ស៖** ខ្ញុំជិតចប់ហើយ ខ្ញុំបន្តិចទៀតផ្តល់វេទិកាជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរពីរបីចុងក្រោយពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខនិងគុក។ លោកបាននិយាយនៅក្នុងសៀវភៅរបស់លោក *"ពូគ័រ ឡេ ខ្មែររូស"* ឯកសារE3/10640 នៅទំព័រ២៣១ ទៅដល់២៣២ គឺរបបដែលបង្កើតគុកប្រមូលផ្តុំ។ "ផ្អែកពីការរំពឹងទុករបស់ខ្ញុំ ដោយបានអានការវិភាគអំពីការប្រែប្រួលផ្សេងៗនៅតាមភូមិភាគនីមួយៗ ក្នុងការបង្ក្រាបមនុស្សនៅកម្ពុជាប្រជាធិបតេយ្យ ខ្ញុំភ្ញាក់ផ្អើលមែនទែនក្នុងការរកឃើញនូវរបៀបដូចគ្នានឹងវិធីដូចគ្នាក្នុងការសម្លាប់មនុស្សនៅទូទាំងប្រទេស។ លើកលែងតែនៅក្នុងភូមិភាគដាច់ស្រយាល ជាពិសេសនៅភូមិភាគពាយ័ព្យដែលជាកន្លែងដើមកំណើតនៃបដិវត្តន៍នោះ។ ខ្ញុំបានឃើញបណ្តាញគុកដែលមានទំនាក់ទំនងគ្នា ហើយដែលមាននៅស្ទើរតែទូទាំងប្រទេស។" លោកបាននិយាយអំពីភាពដូចគ្នាខ្លាំងនៅក្នុងរបៀបនៃការសម្លាប់មនុស្ស។ ដូច្នេះខ្ញុំចង់ដឹងថាតើចរិតលក្ខណៈដូចគ្នាហ្នឹងយ៉ាងម៉េចខ្លះនៅក្នុងមន្ទីរសន្តិសុខ ឬក៏គុកទាំងអស់ហ្នឹង? ដូចជាការរៀបចំ ឬក៏ដំណើរប្រព្រឹត្តទៅនៃគុកទាំងអស់ហ្នឹង ការសួរចម្លើយ លក្ខខណ្ឌនៃការឃុំខ្លួន ហើយនិងការប្រើប្រាស់ទារុណកម្មនោះ សូមលោករៀបរាប់បន្តិចទៅមើល?

[១៥:៤៣:១៥]

**ឆ៖** ខ្ញុំគិតថាងាយស្រួលណាស់ក្នុងការឆ្លើយ។ ដូចគ្នាទាំងអស់ គឺការចាប់ស្ទើរតែទាំងអស់គឺធ្វើឡើងនៅពេលយប់ គឺពេលយប់ទើបគេនាំមនុស្សទៅ។ ហើយទី២ គេនាំទៅកាន់ស្នងការសន្តិបាលថ្នាក់មូលដ្ឋាន គេអត់នាំទៅថ្នាក់ស្រុកទេ។ ហើយបន្ទាប់មកគេសួរសំណួរ ហេតុអីបានជាអ្នកឯងនៅទីហ្នឹង។ មិនមានការចោទប្រកាន់អីត្រឹមត្រូវទេ គឺគេចោទសួរអ៊ីចឹងតែម្តង។ ហើយបន្ទាប់មកទៀត គេចាត់ទុកអ្នកទាំងអស់ហ្នឹងគឺជាពិរុទ្ធជនតែម្តង ជាអ្នកទោសតែម្តង ដូចជាអ្នកដែលលោកបានរៀបរាប់ឈ្មោះហ្នឹង មឿន, ជន ហើយនិង ឃីត ហ្នឹងគឺជាបក្ខជន គាត់ដឹងច្បាស់ការពិត។ អ៊ីចឹងបើគេសង្ស័យ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អ្នកឯង គឺអ្នកឯងជាជនដែលត្រូវគេសង្ស័យហើយ អត់មានអីប្រកែកទេ។ ប៉ុន្មានថ្ងៃក្រោយមកគេនាំមនុស្សជាច្រើនក្នុងពេលតែមួយទៅមន្ទីរសន្តិសុខ គឺដូចគ្នា។ ជួនកាលគេបណ្ដើរឲ្យដើរទៅ ជួនកាលគេដឹកតាមម៉ូតូ ជួនកាលគេដឹកតាមរទេះគោ ជួនកាលគេដឹកតាមឡាន គឺដឹកទៅដាក់នៅក្នុងគុក។ ហើយទៅដល់ហ្នឹង គឺទៅដល់ពេលយប់ទៀត ទៅដល់គុកហ្នឹង។ ហើយពេលទៅដល់ហ្នឹង គេដាក់ខ្នោះភ្លាម គឺខ្នោះហ្នឹងធ្វើពីដែក។ ហើយយើងពេលនោះ អត់មានឃើញអីទេ ព្រោះពេលហ្នឹងយប់ងងឹតណាស់។ ហើយពេលព្រលឹមឡើងហ្នឹង ភ្ញាក់ឡើងហ្នឹង អ្នកទោសហ្នឹងឃើញ<មានមនុស្សបួន ឬប្រាំនាក់ ឬក៏រហូតដល់២០នាក់។ ដូច្នេះមានន័យថា ដើម្បីដោះយកអ្នកណាម្នាក់ចេញ គេត្រូវដក>រនុកដែក<ចេញតែម្តង>។ <ដូច្នេះនៅ>តាមវត្ត <នៅតាមសាលា មានរន្ធដើម្បីស៊ករនុកដែក ដាក់>កង <ហើយកងនោះ>គេដាក់ជើងទាំងពីរទៅ ជួនកាលគេដាក់ជើងតែមួយទេ។ ហើយតាមគុកខ្លះទៀតហ្នឹង គេចងដៃចងស្លាកសេកទៅក្រោយទៀត។ ហើយអ្នកដេកហ្នឹង គឺអត់មានដេកលើកន្ទេល ដេកអីទេ គឺអត់មានអីទាំងអស់ ដេកនៅលើដីផ្ទាល់តែម្តង។

[១៥:៤៥:៥៧]

ហើយជួនកាលអ្នកទោសហ្នឹង គេចែកបបរាវឲ្យទៅ ដែលមានសុទ្ធតែទឹករាវកក្លកគឺមួយវែក។ គេសួរចម្លើយអ្នកទោសមួយថ្ងៃពីរថ្ងៃអ៊ីចឹងទៅ។ គឺគេសួរលឿនណាស់ គេអត់ទុកយូរទេ ហើយការសួរចម្លើយហ្នឹង អត់ដូចនៅទួលស្លែងទេ គឺតែមួយថ្ងៃ ពីរថ្ងៃ បីថ្ងៃ បួនថ្ងៃអីតែប៉ុណ្ណឹង អត់យូរដូចនៅទួលស្លែងទេ។ ហើយអ្នកខ្លះទៅ ស្លាប់នៅក្នុងពេលសួរចម្លើយហ្នឹង។ ហើយមានការធ្វើទារុណកម្ម ឬក៏ពេលខ្លះទៅ គេគ្រាន់តែគំរាមធ្វើទារុណកម្មទេ។ អ៊ីចឹងវាអាចមានលក្ខណៈខុសគ្នាខ្លះដែរ ពីគុកមួយទៅគុកមួយ។ អ្នកខ្លះនិយាយថា បើគេសួរអី ឲ្យឆ្លើយ "បាទ" ៗទៅ។ បើយើងឆ្លើយ "បាទ"ៗអ៊ីចឹង យើងមានសំណាងថាអាចរស់។ បើគេសួរអីអ៊ីចឹង ឆ្លើយតាមហ្នឹងទៅ ឆ្លើយ "បាទ"ៗ។ បើយើងមិនបានប្រព្រឹត្តឧក្រិដ្ឋកម្មអីក៏ដោយ យើងឆ្លើយថា "បាទ" ទៅ ហើយបើយើងប្រកែកទៅ គឺវានាំឲ្យគ្រោះថ្នាក់ដល់ខ្លួន។ <ខ្ញុំ>អាចពន្យល់រហូតទៅដល់ម៉ោងបួន <អំពី>របៀបនៃការសម្លាប់មនុស្សនេះ គឺដូចគ្នាទាំងអស់ វិធីនៃការធ្វើហ្នឹង គឺវាអនុវត្តដូចៗគ្នា នៅគ្រប់គុកទាំងអស់។

**សៈ** ការដកស្រង់ចុងក្រោយ លោកបាននិយាយនៅក្នុង *"ឌី ហ្គូឡាក់ ខ្មែររូស"*។ ខ្ញុំដូចជាភ្លេចកត់លេខឯកសារE3ទៅហើយ។ ខ្ញុំនឹងអាចផ្ដល់នៅពេលបន្តិចទៀតនេះ ជាភាសាបារាំង គឺ00796291, អង់គ្លេស 00394614, ជាភាសាខ្មែរ 00822607 ទៅដល់08។ ខ្ញុំសូមអានតែមួយឃ្លា ពីរឃ្លាទៅដើម្បី

ឲ្យខ្លី។ លោកបានសរសេរថា៖ “សម្រាប់ថ្នាក់ដឹកនាំខ្មែរក្រហម ជីវិតមនុស្សលែងមានន័យអីទៀតហើយ គឺមនុស្សហ្នឹងគឺថាលែងដឹងការពិត លែងដឹងអីហើយ ហើយគ្មានភាពមនុស្សធម៌ទៀតទេ នៅក្នុងរបបនោះ។” លោកថា មេដឹកនាំហ្នឹង គឺថាបាត់បង់នូវការពិតហ្នឹងយ៉ាងម៉េច មានន័យថា គេលាក់មិនឲ្យពួកគាត់ដឹងការពិត ឬក៏យ៉ាងម៉េច ឬក៏មេដឹកនាំនោះ មិនចង់មើលឃើញការពិត?

[១៥:៤៨:៥០]

**ឆ៖** ចំពោះខ្លួនខ្ញុំ ខ្ញុំគិតថា ឃ្លាដែលខ្ញុំសរសេរនេះ ខ្ញុំនៅតែប្រកាន់ដដែល។ ឃ្លានេះគឺមានខ្លឹម-សារបង្ហាញការពិត ពាក់ព័ន្ធនឹងបញ្ហាចោទសំណួរបែបទស្សនវិជ្ជាថា ហេតុអ្វីហ្នឹង? ខ្ញុំពិបាកឆ្លើយណាស់។ ខ្ញុំអាចរំឭកនូវការដកស្រង់ដែលចេញពីសម្ដី នួន ជា បាន។ គាត់ថា “សម្លាប់កម្មាភិបាល<ពីរ>បី<រយ>នាក់ចោលក៏បានដែរ ទោះបីខុស មិនខុសក៏ដោយ ច្រឡំ ឬក៏មិនច្រឡំក៏ដោយ គឺថាក៏អត់បញ្ហាអីដែរ ឲ្យតែធ្វើម៉េចរក្សាទុកមេដឹកនាំ<ពីរ>បី<>នាក់បាននោះ។” អ៊ីចឹងមានន័យថា ដូចជាគ្មានតម្លៃជាមនុស្សអីទេ កម្មាភិបាលធម្មតានោះ បីបួនរយនាក់ក៏គេសម្លាប់ចោលបានដែរ ធ្វើម៉េចទុកតែមេធំៗបីបួននាក់ហ្នឹង។ យើងឃើញ មនុស្សយើងដូចជាគ្មានតម្លៃអីជាមនុស្សទៀតទេ គេអាចសម្លាប់ចោលពេលណាក៏បាន។ <តើពួកគេឆ្កួតហើយឬ? ខ្ញុំគិតថា ខាងការពារក្ដីគួរតែប្ដឹងលើរឿងនេះ។ ប៉ុន្តែខ្ញុំគិតថា ពួកគេមិនបានប្ដឹងទេក្នុងរយៈពេលកន្លងមកនេះ។ ពួកគេបានបដិសេធមិនឲ្យពេទ្យព្យាបាលរោគវិកលចិរតពិសោធន៍ពួកគេទេ ដែលខុសគ្នាយ៉ាងខ្លាំងពី ឌុច។ ចំណុចនេះមិនល្អទេ។> នេត ថាយ័រក្រោយពីគាត់សម្ភាស ប៉ុល ពត ហ្នឹង គាត់និយាយថា <“នៅក្នុងប្រទេសខ្ញុំយើងនិយាយថា មនុស្សទាំងអស់នេះត្រូវបានធ្វើឲ្យឡប់”។ ជាការពិតណាស់ ដែល>មេដឹកនាំទាំងអស់ហ្នឹង គឺថាកាត់ផ្ដាច់ពីការពិត គឺដូចជាពិភពពីរដាច់ពីគ្នា។ <ពួកគេមានជំងឺខួរក្បាល។ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃជាមួយគ្រួសារ>ប្រពន្ធ<>កូន <របស់ពួកគេ ពួកគេគឺជាឪពុក និងជាប្ដីគំរូ>។ ដូចជាលោក ខៀវ សំផន ហ្នឹងគាត់មានប្រពន្ធ មានកូនបួន ហើយគាត់ជាប្ដីគំរូ ហើយ ប៉ុល ពត គាត់ជាឪពុកគំរូ។ អ៊ីចឹង<តើ ប៉ុល ពត មានជំងឺខួរក្បាលឬ ខ្ញុំមិនដឹងទេ>។

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្សាឯល៖**

ឥឡូវនេះខ្ញុំអាចឲ្យឯកសារគឺE3/2811ដែល *“ឌី ហ្គូឡាក់ ខ្មែររូស៍”*។ សូមអរគុណលោកប្រធាន ខ្ញុំសូមអនុញ្ញាតប្រគល់វេទិកានេះជូនសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

[១៥:៥១:១០]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី ដើមបណ្ដឹងរដ្ឋប្បវេណី និងសាធារណជន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមជម្រាបសួរលោកអ្នកជំនាញ ខ្ញុំមានសំណួរមួយចំនួនសម្រាប់សួរលោកនៅរយៈពេលមិនច្រើនប៉ុន្មានទេ សម្រាប់សំណួររបស់ខ្ញុំ។ ជាបឋមពាក់ព័ន្ធទៅនឹងសំណួរដំបូងដែលមនុស្សជាច្រើនពិសេសយុវជនឥឡូវគេតែងតែចោទសួរអំពីការស្លាប់របស់មនុស្សនៅក្នុងសម័យខ្មែរក្រហម។ គេសួរថាតើមូលហេតុអ្វីបានជានៅសម័យខ្មែរក្រហមមានមនុស្សស្លាប់ច្រើនម្ល៉េះ? តើលោកអាចពន្យល់អំពីបញ្ហាហ្នឹងបានទេ?

**លោក ហង់រី ឡូកា៖**

**ឆ៖** ខ្ញុំសូមឆ្លើយជាអង់គ្លេសទៅ ព្រោះមនុស្សភាគច្រើនចេះអង់គ្លេស។ ប៉ុន្តែតើខ្ញុំគួរឆ្លើយជាអង់គ្លេស ឬក៏បារាំង ខ្ញុំឆ្លើយបារាំងចុះអ៊ីចឹង។

[១៥:៥២:៤៤]

**ស៖** លោកអាចជ្រើសរើសភាសាណាដែលលោកអាចឆ្លើយបាន តែទោះយ៉ាងណាខ្ញុំស្ដាប់ជាភាសាខ្មែរ។

**ឆ៖** ខ្ញុំគិតថា ខ្ញុំគួរប្រើភាសាអង់គ្លេសទៅចុះ ព្រោះថានៅក្នុងតុលាការនេះមនុស្សភាគច្រើននិយាយភាសាអង់គ្លេស។ លោកបានលើកនូវសំណួរដែលមានលក្ខណៈជាមនោគមន៍វិជ្ជា ហើយសំណួរនេះគឺខ្ញុំគិតថា ដើមបណ្ដឹងរដ្ឋប្បវេណីដែលនៅអង្គុយក្រោយលោកនោះ គាត់ចូលចិត្តសួរដែរ។ គេតែងតែសួរថាហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្សច្រើនម្ល៉េះ។ នេះគឺជាកម្មវត្ថុនៃសៀវភៅទាំងអស់របស់ខ្ញុំ ហើយចម្លើយដែលសាមញ្ញគឺថា ព្រោះថាមានគម្លាតខុសគ្នារវាងសង្គមអស្ចារ្យ សង្គមឥតខ្ចោះ ជាមួយនឹងសង្គមទូទៅមួយ។ ហើយដូចដែលយើងឃើញហើយថា ខៀវ សំផន និង នួន ជា ដែលនៅទីនេះ គឺថាពួកគាត់ចង់ឲ្យមានសង្គមមួយដែលរីករាយ មានការវិវត្តន៍ មានវឌ្ឍនភាពទៅមុខ។ ហើយគាត់ចង់

មានឋានសួគ៌កុម្មុយនីស្តមួយ គឺជាឋានសួគ៌មួយដែលក្រោយមកក្លាយទៅជាឋាននរកវិញ។ ព្រោះថាអ្វីៗទាំងអស់នៅក្នុងទីកន្លែងនោះ គឺវាមានគោលបំណងខុស ឧទាហរណ៍ដូចជានៅពេលដំបូង គេប្រើប្រាស់មធ្យោបាយទាំងស្របច្បាប់ ទាំងខុសច្បាប់ ឬក៏មធ្យោបាយដែលស្លូតបូត ឬក៏ហិង្សា ដើម្បីដណ្តើមយកឯករាជ្យនោះ គឺថាគ្រប់ប្រជាជនកម្ពុជាទាំងអស់ នៅពេលដែលមានសង្គ្រាមលោកលើកទី២ គឺថាពួកគាត់ទាំងអស់ស្នើសុំឱ្យមានចំណុចទាំងអស់នេះ រួមទាំងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត ផងដែរ។ គាត់ចង់បានបែបនេះ ហេតុដូច្នេះហើយទើបគេមិនជ្រើសរើសគាត់ធ្វើជាមហាក្សត្រនោះ។ ប៉ុន្តែសួរថាតើពួកគេប្រើប្រាស់មធ្យោបាយសន្តិភាព ដើម្បីចរចាជាមួយបារាំង ទាមទារឯករាជ្យ ឬមួយក៏ប្រើប្រាស់ហិង្សា។ នៅពេលនោះ ខ្មែរឥស្សរៈជ្រើសរើសអំពើហិង្សា ប៉ុន្តែគណបក្សប្រជាធិបតេយ្យប្រើប្រាស់នូវការចរចា ហើយនិងប្រជាធិបតេយ្យវិញ។

[១៥:៥៥:១២]

ជម្រើសទី១ របស់ខ្មែរឥស្សរៈ ក៏ដូចជាបក្សកុម្មុយនីស្តឥណ្ឌូចិន គឺគាត់បានជ្រើសរើសការប្រើប្រាស់ហិង្សាដើម្បីដណ្តើមឯករាជ្យ ហើយគាត់ចង់ឱ្យមាននូវសង្គ្រាមស៊ីវិល។ នៅពេលដំបូង ប្រសិនបើយើង នៅពេលដំបូងយើងចាប់ផ្តើមហិង្សាហើយ គឺវាពិបាកបញ្ឈប់អំពើហិង្សានោះណាស់។ ហេតុផលមួយទៀត គឺថាបក្សកុម្មុយនីស្តកម្ពុជា គឺមានសមាជិកតិចនៅពេលដំបូង ដូច្នេះហើយពួកគេមិនអាចតម្រូវឱ្យមានការឯកភាពជាមូលមតិឡើយ គឺចាំបាច់ត្រូវតែមានការប្រើហិង្សា។ ហើយម្យ៉ាងទៀត ពួកគាត់ត្រូវការធ្វើការងារឱ្យប្រញាប់ប្រញាល់បំផុត ព្រោះថា ពួកគាត់តែងតែគិតថា អរិយធម៌កម្ពុជា គឺអរិយធម៌មួយដ៏អស្ចារ្យ ដែលយើងមានអង្គរ ដែលយើងមានប្រាសាទនានា ដូច្នេះយើងចាំបាច់ត្រូវតែធ្វើឱ្យបានឆាប់រហ័ស។ ហើយម្យ៉ាងវាចាំបាច់ត្រូវតែផ្លាស់ប្តូរឱ្យបានលឿន ពីចក្រពត្តិនិយមទៅជាមូលធននិយម ទៅជាកុម្មុយនីស្តនិយមភ្លាមៗ ហើយឱ្យវាជាកុម្មុយនីស្តមួយដែលវាអស្ចារ្យជាងកុម្មុយនីស្តដទៃទៀត។ ដូច្នេះហើយ គឺថាធ្វើយ៉ាងម៉េចឱ្យវាអស្ចារ្យជាងគេ។ ហេតុដូច្នេះហើយ ទើបវាមានមហន្តរាយបែបនេះ។ ខ្ញុំគិតថា ពួកគេក៏ឃ្លានអំណាចផងដែរ គឺពួកគាត់ស្រេកឃ្លានអំណាច គឺបានន័យថា គឺដណ្តើមអំណាចដោយមិនគិតពីការស្លាប់រស់របស់មនុស្សដទៃទៀតឡើយ។ ខ្ញុំគិតថា មនុស្សទាំងអស់យើងទាំងអស់គ្នាហ្នឹង អ្នកណាក៏សុទ្ធតែស្រេកឃ្លានអំណាចដែរ។

[១៥:៥៧:០១]

**ស៖** សំណួរមួយទៀត អាចស្មុគស្មាញបន្តិចដែរ។ នៅក្នុង -- លោកមានបានពិនិត្យឃើញទេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៅក្នុងការវិភាគរបស់លោក ការដឹកនាំនៅសម័យនោះ សម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង មានបាន យកភាពជាមនុស្ស ៗធម៌ យកមកពិចារណានៅក្នុងការដឹកនាំហ្នឹងដែរឬទេ?

**ឆ៖** បាទខ្ញុំគិតថា វាជាកំហុសដែលយើង ដែលខ្មែរក្រហមជ្រើសរើសមធ្យោបាយកាចសាហាវ អមនុស្សធម៌បែបនេះ។ ក្មេងៗជាច្រើនដែលចូលបដិវត្តន៍ គឺសុទ្ធតែជាមនុស្សដែលមានមនោមគមន៍វិជ្ជា គឺសុទ្ធតែលង់មនោគមន៍វិជ្ជា។ សួង ស៊ីគឿន គឺជាឧទាហរណ៍មួយ។ យុវជនជាច្រើននៅជំនាន់នោះ គឺ សុទ្ធតែជាមនុស្សដែលគិតលម្អិត គឺពួកគេចង់ឲ្យបាននូវអ្វីដែលលម្អិត។ គាត់ចូលចលនានោះ គឺគាត់ចូល តាំងពីអាយុ១៦ឆ្នាំមកម្ល៉េះ ហើយគាត់ជាយុវជនក្មេងមួយ ហើយមានឧត្តមគតិ។ នៅពេលដែលពួកគាត់ ចូលចលនានេះ គឺចលនាដែលពួកគាត់ជ្រើសរើស គឺជាចលនាប្រកបដោយហិង្សា ដែលមានអាវុធ ដែលមានសង្គ្រាមស៊ីវិលទាំងអស់នេះ។ ហើយវាជាអន្ទាក់ដែលទាញពួកគាត់ចូលទៅក្នុងចលនា បាន ន័យថា តែចូលហើយ គឺចេញលែងរួចតែម្តង។ នៅក្នុងរបបទាំងមូលក៏មានឧទាហរណ៍ជាច្រើនដែរ ឧទាហរណ៍ដូចជា កងទ័ពខ្មែរក្រហម ឬក៏កម្មាភិបាលខ្មែរក្រហម ដែលគាត់ដូចថាចិត្តល្អ ជួយជីវិត មនុស្សដទៃទៀតនុ៎ង ឬក៏ថាកម្មាភិបាលដែលផ្តល់អាហារដល់ច្រើន គឺថាពួកគាត់មិនចង់ឲ្យមានអំពើ ហិង្សា។ ប៉ុន្តែវាពិបាកដើម្បីប្រមូលពួកគាត់រួមគ្នា ព្រោះថា យ៉ាងណាក៏ដោយ មាននៅសល់អំពើមនុស្ស ធម៌ដែរ ប៉ុន្តែវាតិចតួចបំផុត។

[១៥:៥៩:៤០]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន ខ្ញុំមានប្រហែលជា ត្រូវការរយៈពេលប្រហែលជា១០នាទី ឬមួយក៏ លោកប្រធានអនុញ្ញាតឲ្យខ្ញុំសួរពេលនេះ ឲ្យចប់ ឬក៏ទុកសម្រាប់ថ្ងៃចន្ទ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមិនអាចបន្តទៀតបានទេ ថ្ងៃនេះថ្ងៃសុក្រ តាមធម្មតាគឺរថយន្តចាកចេញពី ទីនេះទៅភ្នំពេញគឺនៅម៉ោងបួន ឥឡូវយើងពន្យារពេល សូមពន្យារពេលបន្តិចបន្តួច។

បាទ សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរ ការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០១ ខែសីហា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃចន្ទនេះ ដើមសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹង ធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សីអ្នកជំនាញ ហង់រី ឡូកា សូមភាគីជ្រាប អញ្ជើញចូលរួមតាមពេល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

វេលាបានកំណត់នេះ។

សូមអញ្ជើញលោកស្រីមេធាវី អង់តា ហ្គិសសេ។

[១៦:០០:៤១]

**កញ្ញា អង់តា ហ្គិសសេ៖**

សូមអរគុណលោកប្រធាន សូមពេលបន្តិចបន្តួចលោកប្រធាន។ ខ្ញុំចង់ដឹងថា តើឯកសារដែលយើងបានដាក់ជូនសម្រាប់អ្នកជំនាញនោះ ត្រូវបានផ្តល់ជូនហើយឬនៅ? បើមិនអ៊ីចឹងទេ ខ្ញុំអាចផ្តល់ឯកសារមួយចំនួនទៅឲ្យអ្នកជំនាញ ដើម្បីឲ្យគាត់ពិនិត្យមើលនៅក្នុងពេលសម្រាកចុងសប្តាហ៍នេះ ព្រោះថាខ្ញុំបានដាក់បញ្ជីឯកសារហើយ មិនដឹងថាតើអ្នកជំនាញទទួលបានឯកសារទាំងអស់នុំងឬនៅទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ប្រសិនបើមើលតាមប្រតិកម្មរបស់មន្ត្រីច្បាប់ ដូចជាមិនទាន់ទេមើលទៅ។

**កញ្ញា អង់តា ហ្គិសសេ៖**

<ហេតុដូច្នេះហើយ-->

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើនលោកស្រីមេធាវី ដែលមានការយកចិត្តទុកដាក់ខ្ពស់អំពីបញ្ហានេះ។ ហើយដើម្បីឲ្យសវនាការនៅថ្ងៃចន្ទ សប្តាហ៍ប្រព្រឹត្តទៅបានល្អនេះ ហើយដើម្បីឲ្យអ្នកជំនាញមានពេលវេលាសមស្របគ្រប់គ្រាន់សម្រាប់ពិនិត្យឯកសារពាក់ព័ន្ធ មន្ត្រីរដ្ឋបាលតុលាការទទួលយកឯកសារពីលោកស្រីមេធាវីយកជូនទៅអ្នកជំនាញដើម្បីឲ្យគាត់មានពេលវេលាពិនិត្យ និងអានឯកសារនេះមុនពេលផ្តល់សក្ខី-កម្មនៅថ្ងៃចន្ទ។

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនអ្នកជំនាញ)*

**កញ្ញា អង់តា ហ្គិសសេ៖**

ខ្ញុំសូមបញ្ជាក់ជូនលោកប្រធាន និងភាគីផងដែរថា មិនមែនឯកសារទាំងស្រុងទេ គឺគ្រាន់តែជាអត្ថបទមួយចំនួន ហើយនិងឯកសារពីសម័យនោះ ដើម្បីឲ្យគាត់ពិនិត្យមើលនៅចុងសប្តាហ៍នេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោក ហង់រី ឡូកា ការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាអ្នកជំនាញនៅថ្ងៃនេះមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចន្ទ ដើមសប្ដាហ៍ក្រោយទៀត។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកអ្នកជំនាញ ហង់រី ឡូកា ត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃចន្ទ ដើមសប្ដាហ៍ក្រោយ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបចូលរួមសវនាការនៅថ្ងៃចន្ទ ទី០១ ខែសីហា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*